ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Apr-2012, 16:00
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី៤៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោក វ៉ែន ពៅ

លោកស្រី ម៉ារី ហ្គីរ៉ូដ*(Ms.Marie GUIRAUD)*

កញ្ញា ចេននី សុលហ្សេ *(Ms.Jeanne SULZER)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក បាណាបេ ណេគ្វី | បារាំង |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖ លោក ការ៉ែង ហ្គេកអ៊ាវ ហៅ ឌុច**

សួរបន្តដោយលោក ម៉ៃខល ផេសមិន ផ្តើមពី៖ ..........................................................ទំព័រ ០៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅថ្ងៃនេះ គឺនឹងត្រូវតាំងសំណួរដោយក្រុមមេធាវីការពារក្ដីលោក នួន ជា ដែលនឹងបន្តពីការដែលក្រុមមេធាវីបានសួរដេញដោលចំពោះសាក្សីរូបនេះកាលពីម្សិលមិញ។ មុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី-- អ៎! លោក នួន ជា អង្គជំនុំជម្រះសាលាដំបូងសូមរំឭកបន្ថែមនៅលើសេចក្ដីសម្រេចផ្ទាល់មាត់កាលពីម្សិលមិញថា អនុលោមតាមវិធាន២៨ នៃវិធានផ្ទៃក្នុង សាក្សីអាចជំទាស់ទៅនឹងការឆ្លើយ ឬធ្វើសេចក្ដីថ្លែងការណ៍ដែលអាចនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ នេះគ្របដណ្ដប់លើអង្គហេតុទាំងឡាយដែលមិនទាន់ត្រូវបានវិនិច្ឆ័យសេចក្ដីជាស្ថាពរ។

[០៩:០៦:៥១]

ក្នុងករណីដែលសាក្សីកំពុងធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ សាក្សីអាចជំទាស់ទៅនឹងការឆ្លើយទៅនឹងសំណួរដែលពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយ ដែលមិនទាន់វិនិច្ឆ័យសេចក្ដីក្នុងសំណុំរឿង ០០១ ហើយដែលអាចនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដែលអាចនឹងត្រូវចោទប្រកាន់នាពេលអនាគត។ សាក្សីគប្បីនិយាយឲ្យបានច្បាស់ ប្រសិនបើ និងពេលដែលខ្លួនមានបំណងអនុវត្តសិទ្ធិនេះ។

ទន្ទឹមនឹងនេះដែរ ក៏សាក្សីត្រូវមានកាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងសំណួរ នូវការណាដែលខ្លួនបានឃើញ បានដឹង បានឮ ធ្លាប់មានបទពិសោធន៍ឆ្លងកាត់ ឬក៏មានការកត់សម្គាល់កន្លងមក ទៅនឹង-- ពាក់ព័ន្ធទៅនឹងហេតុការណ៍ ព្រឹត្តិហេតុដែលមានការពាក់ព័ន្ធទៅនឹងការតាំងសំណួរចំពោះ-- របស់ភាគីចំពោះខ្លួន។

[០៩:០៨:២០]

អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំបានស្នើកាលពីម្សិលមិញ កូនក្តីរបស់ខ្ញុំសូមសម្តែងមតិដោយសង្ខេបទៅលើអ្វី ដែលលោកសាក្សីទើបបាននិយាយកន្លងមកនេះ។ ហើយគាត់នឹងប្រើពេលតែប្រាំនាទីតែប៉ុណ្ណោះ។ ហើយប្រហែលជាគាត់សូមអនុញ្ញាតមិនចូលរួមផ្ទាល់ទេនៅល្ងាចនេះ។ អ៊ីចឹង គាត់ចង់ឆ្លើយតប ឬក៏មានជាមតិឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សីរហូតមកដល់ពេលនេះ។

[០៩:០៩:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សហព្រះរាជអាជ្ញាមិនមានជំទាស់ទៅនឹងអ្វីដែលបានលើកឡើងនេះទេ ក៏ប៉ុន្តែលក្ខណៈនៃយោបល់នោះនឹងត្រូវធ្វើសក្ខីកម្ម ប៉ុន្តែសហព្រះរាជអាជ្ញាសូមស្នើថា គាត់មាន--- យើងក៏មានសិទ្ធិនៅក្នុងការសួរទៅនឹងចម្លើយរបស់ជនជាប់ចោទនៅពេលនេះ ពេលក្រោយតទៅទៀតដែរ។

[០៩:០៩:៥៧]

ដូច្នេះអ្វីដែលយើងដាក់នៅក្នុងសារណារបស់យើង ប្រសិនជាជនជាប់ចោទនឹងផ្តល់សក្ខីកម្មនោះគាត់នឹងត្រូវរៀបចំខ្លួន ដើម្បីឲ្យខាងយើងខ្ញុំចោទសួរនោះផងដែរ។ នៅទីពីរ ប្រសិនបើគាត់មិនឆ្លើយនឹងសំណួរដែលយើងខ្ញុំនឹងសួរទេ បន្ទាប់ពីគាត់បានផ្តល់សក្ខីកម្មនៅផ្នែកណាមួយ យើងនឹងជ្រាបតុលាការថា ការថ្លឹងថ្លែងទៅនឹងសក្ខីកម្មទាំងអស់នោះ នៅចុងបញ្ចប់នៃរឿងក្តីនោះ អាចនឹងមានលក្ខណៈស្ទួចស្តើង។ ហើយយើងខ្ញុំនឹងស្នើឲ្យមានការបកស្រាយជា-- ប្រឆាំងទៅនឹងអ្វីដែលជនជាប់ចោទបានធ្វើសេចក្តីបដិសេធមិនឆ្លើយតបជាដើមនោះ។ ដូច្នេះ នៅក្នុងថ្ងៃទី១៧ ខែ០២ ទាក់ទងរឿងក្តី លោក ខៀវ សំផន ហ្នឹង គឺទាក់ទងទៅនឹងការជំទាស់របស់លោក នួន ជា ផងដែរ ដែលគាត់បានប្រកាន់ជំហរនោះ។ ហើយយើងសូមប្រកាន់នូវជំហរទាំងនោះ ហើយយើងនឹងសូមឲ្យអង្គជំនុំជម្រះថា ជនជាប់ចោទត្រូវតែឆ្លើយសំណួរអ្វីដែលគាត់ត្រូវផ្តល់សក្ខីកម្ម ប្រសិនបើគាត់បដិសេធ នឹងប្រើការបកស្រាយប្រឆាំងនឹងរូបគាត់។ ដូច្នេះ ហើយនៅចុងបញ្ចប់រឿងក្តី យើងខ្ញុំនឹងប្រើនូវទ្រឹស្តីនេះ។

ដូចដែលយើងបានចង្អុលបង្ហាញ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនឹងត្រូវចេញក្នុងពេលឆាប់ៗ

ទាក់ទងទៅនឹងសំណើរបស់លោក ខៀវ សំផន លោក នួន ជា ហើយយើងខ្ញុំសូមស្នើថា ហើយយើងស្នើករណីនេះ ចំពោះលោក នួន ជា ហើយយើងមិនជំទាស់ទេ ចំពោះការដែលគាត់សម្តែងយោបល់ប៉ុណ្ណោះ។ ប៉ុន្តែយើងនឹងសួរទៅជនជាប់ចោទនៅពេលនេះ ឬនៅពេលក្រោយទាក់ទងទៅនឹងបញ្ហាទាំងឡាយដែលយើងបានស្នើខាងដើមនេះបាទ។

[០៩:១១:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីនាំមុខ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការ។ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធាន អនុញ្ញាតលោកមេធាវី បាណាបេ ណេគ្វី ជាមេធាវីខាង-- មេធាវីគ្មានព្រំដែនដើម្បីឡើងមានមតិចំពោះករណីសំណើសុំធ្វើសេចក្តីថ្លែងការណ៍នេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:១២:៣៥]

**លោក បាណាបេ ណេគ្វី៖**

បាទ សូមអរគុណលោកប្រធាន។ អស់លោក លោកស្រីចៅក្រម ជាទីគោរព។ បន្ទាប់ពីសហព្រះរាជអាជ្ញាបាននិយាយនេះមក ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា ខ្លួនមិនជំទាស់ទៅនឹងសិទ្ធិ ដែលជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀម ឬក៏ចេញពីភាពស្ងៀមស្ងាត់នេះដើម្បីសម្តែងមតិនោះទេ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ យើងត្រូវរំឭកផងដែរ ថាមានគោលការណ៍មូលដ្ឋានដែលអង្គជំនុំជម្រះត្រូវតែធានា ដែលមានចែងនៅក្នុងវិធាន២១(ក) ដែលថានីតិវិធីនៅ អ.វ.ត.ក នេះ ត្រូវតែមានយុត្តិធម៌ ហើយនិងរក្សាសមភាពនៃភាគី ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ហើយយើងគាំពារការពារនេះ ក៏ដូចតែគ្នាដែរ ស្មើគ្នាដែរ។

[០៩:១៣:៣២]

ខាងភាគីការពារក្តីចង់រក្សាសិទ្ធិនៅសភាពស្ងៀមស្ងាត់ ហើយពេលខ្លះចង់ចេញពីភាពស្ងៀម

ស្ងាត់ដើម្បីសេចក្តីថ្លែងការណ៍ ហើយចូលមកភាពស្ងៀមស្ងាត់វិញ។ ខ្ញុំយល់ឃើញ វាហាក់ដូចជាមិនឆ្លើយតបទៅនឹងវិធាន២១(ក) នេះទេ ហើយនិងមិនឆ្លើយតបទៅវិធានផ្សេងៗដែលមាននៅ-- ដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក នេះទេ។ ហើយខ្ញុំសូមរំឮកថា ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងដែរ គឺថានៅក្នុងដំណាក់កាលនៃនីតិវិធីនេះ ខាងជនជាប់ចោទមានសិទ្ធិក្នុងការសេចក្តីថ្លែងការណ៍ហើយជាបឋម ហើយនិងថ្លែងការណ៍នៅទីបញ្ចប់។ អ៊ីចឹងលទ្ធភាពនៃការ-- ហើយក៏មានសិទ្ធិក្នុងការនិយាយស្តីនៅក្នុងដំណើរការនីតិវិធីផងដែរ។

[០៩:១៤:៥៤]

ដូច្នេះ វិធានទាំងឡាយនេះ គឺអាចឲ្យគាត់មានសិទ្ធិចោទសំណួរ មានសិទ្ធិឆ្លើយទៅ-- ចោទសំណួរទៅសាក្សីតាមរយៈប្រធានអង្គជំនុំជម្រះ។ ពុំមានវិធានណាដែលអនុញ្ញាតឲ្យជនជាប់ចោទ គឺថាម្តងម្កាលចេញពីភាពស្ងៀមស្ងាត់ ហើយមកនិយាយ ហើយស្រាប់តែឈប់និយាយវិញ។ ហើយសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីយើងហ្នឹងក៏មានដែរ គឺថាយើង-- អង្គជំនុំជម្រះគួរតែបញ្ជាក់ឲ្យច្បាស់លាស់ ថាតើជនជាប់ចោទនោះមានសិទ្ធិនិយាយស្តីអ្វីខ្លះ? ហើយដែលថាវាអាចប៉ះពាល់ទៅដល់សិទ្ធិរបស់អ្នកដទៃនោះ។ តើនៅពេលដែលគាត់អង្គជំនុំជម្រះចង់ធ្វើសេចក្តីថ្លែងការណ៍បឋម--

[០៩:១៦:០០]

**អ្នកបកប្រែ៖**

លោកៗប្រធានសូមឲ្យគាត់បន្ថយល្បឿនបន្តិចបាទ! សូម!

**ប្រធានអង្គជំនុំ៖**

អត់មានការបកប្រែទេ និយាយឡើងវិញ! ហើយនិយាយខ្លីបានហើយ ពីព្រោះអង្គជំនុំជម្រះបានទទួលព័ត៌មានសព្វគ្រប់ហើយលើបញ្ហានេះ។ ហើយអង្គជំនុំជម្រះបានត្រៀមនូវសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហាទាំងអស់នេះហើយ នៅតែពិនិត្យឲ្យហ្មត់ចត់តែប៉ុណ្ណោះ។ ពីព្រោះវាជាបញ្ហាមួយដ៏ស្មុគស្មាញពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនជាប់ចោទ។ ប៉ុន្តែបញ្ហានេះ គឺអង្គជំនុំជម្រះបានទទួលព័ត៌មានសព្វគ្រប់ចំពោះជនជាប់ចោទទាំងបីរូប ដែលរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបក្នុងស្ថានភាពខុសៗគ្នា។ មិនដូចករណីលោក អៀង សារី ទេ ដែលបានបង្ហាញជំហរច្បាស់លាស់នៅក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសោះរហូតពេញមួយកិច្ចដំណើរការនីតិវិធីនៃសវនាការដេញដោល ចាប់តាំងពីដើមដំបូងរហូតដល់ចប់។ ក្រៅពីនោះនៅមានបញ្ហាខ្លះ ដែលនៅរក្សាសិទ្ធិនឹងការឆ្លើយតបខ្លះក៏ដោយ ក៏អង្គជំនុំ

ជម្រះមានមូលដ្ឋានក្នុងការពិចារណា ហើយចេញសេចក្ដីសម្រេចមួយឆាប់ៗក្នុងពេលឆាប់ខាងមុខនេះ។

[០៩:១៧:២១]

ដូច្នេះបញ្ហានេះ គឺទាក់ទិនជាមួយនឹងសំណើសុំធ្វើសេចក្ដីថ្លែងការណ៍រយៈពេលប្រាំនាទី គួរតែមានបញ្ហាយ៉ាងដូចម្ដេច ប្រសិនបើលោកភាគីដែលមានបញ្ហាពាក់ព័ន្ធនឹងបញ្ហានេះគួរតែលើកស្របគ្នាជាមួយនឹងពេលវេលាដែលក្រុមម្ខាងទៀតបានសម្ដែងនូវការមិនឆ្លើយតប។ ការនោះ គឺមានឱកាសគ្រប់គ្រាន់ ប៉ុន្តែភាគីមិនបានធ្វើសេចក្ដីថ្លែងការណ៍អ្វីជាក់ច្បាស់ វែងអន្លាយដូចពេលនេះទេ។

លោកអាចបន្តដោយខ្លីបានហើយ ហើយនិយាយនូវចំណុចចុងក្រោយឡើងវិញ និយាយយឺតដើម្បីធានាថា ឲ្យអ្នកបកប្រែបានបកប្រែភាសារបស់លោកទៅជាភាសាខ្មែរ និងភាសាអង់គ្លេស ដើម្បីឲ្យភាគីផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងក្នុងដំណើរការ ក៏ដូចជាសាធារណជនដែលចូលរួមស្ដាប់នេះបានស្ដាប់បាននូវខ្លឹមសារដែលលោកនិយាយផង ចៀសវាងលោកនិយាយស្ដាប់តែម្នាក់ឯង។

[០៩:១៨:៤២]

**លោក បាណាបេ ណេគ្វី៖**

បាទ សូមអរគុណលោកប្រធានដែលបានផ្ដល់យោបល់នេះ។ ខ្ញុំ-- អម្បាញ់មិញនេះខ្ញុំជិតបញ្ចប់ទៅហើយ នៅពេលដែលលោកប្រធានបានបញ្ឈប់អម្បាញ់មិញនេះ។ បាទ ឥឡូវគឺខ្ញុំសូមបន្ថយល្បឿន។ អ្វីដែលខ្ញុំបាទចង់លើកឡើង ខ្ញុំនិយាយឡើងវិញ គឺថាចំពោះដើមបណ្ដឹងរដ្ឋប្បវេណីជាការចាំបាច់ណាស់ក្នុងការដឹងថា នួន ជា នោះគាត់និយាយអ្វីទៅពេលបន្ទាប់ពីសក្ខីកម្មរបស់លោក ឌុច នោះ។ ថាតើវាសមស្របទៅនឹងវិធាន៩០ ដែរអត់? ហើយបើក្នុងករណីនេះយើងអាចចោទសំណួរទៅគាត់វិញ បើ ឬក៏ជាសេចក្ដីថ្លែងការណ៍ដែលពុំមានតម្លៃច្បាប់ ហើយនៅក្នុងលក្ខខណ្ឌនេះ ខ្ញុំ-- បើសិនជាអង្គជំនុំជម្រះយល់ស្របទៅជនជាប់ចោទ នេះជារឿងរបស់អង្គជំនុំជម្រះ។ ហើយគ្រាន់-- យើងខ្ញុំគ្រាន់តែចង់រំឭកថាវិធានផ្ទៃយើងក្នុងក៏ត្រូវតែគិតផងដែរ ក្នុងករណីដែលមានកាយវិការបែបនេះ។ ការព្រួយបារម្ភរបស់យើងជាមូលដ្ឋាននោះ គឺថាយើងមិនត្រូវភ្លេចថា អ្វីដែលជាមូលហេតុ ជាបង្កឲ្យមានមូលហេតុនៅក្នុង--

[០៩:២០:០១]

គឺបញ្ហាចម្បងគឺថាមានប្រជាជនកម្ពុជាជា-- រាប់ម៉ឺននាក់ដែលមានការឈឺចាប់ ដែលយើងជាមេធាវីជាអ្នកតំណាងឲ្យ ហើយដែលមានមនុស្សរាប់ម៉ឺននាក់ រាប់លាននាក់ដែលកំពុងតែទ្រហោយំ។ ហើយខាងភាគីការពារក្ដីគេមានសិទ្ធិការពារក្ដីរបស់គេ ហើយក៏គួរតែគិតដល់សិទ្ធិ ដល់ជនរងគ្រោះផង

ដែរ ហើយមិនត្រូវធ្វើឲ្យមនុស្សក្លាយជាមនុស្សយន្តនោះទេ។ ហើយអង្គជំនុំជម្រះសូមរំឭកថា វិធាន៩១ នេះត្រូវតែអនុវត្តនៅចំពោះករណីសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទនេះ។ នេះជាអ្វីដែលយើងខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះ។ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តី នួន ជា មានអ្វីចង់លើកឡើងជំទាស់ ឬក៏តបទៅនឹងអ្វីដែលលើកឡើងដោយភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះទេ?

[០៩:២១:១៤]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំអត់មានទេលោកប្រធាន។ អរគុណបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២១:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ នួន ជា តាមរយៈមេធាវីអន្តរជាតិការពារក្តីរបស់គាត់អម្បាញ់មិញ ដែលគាត់បានស្នើសុំធ្វើសេចក្តីថ្លែងការណ៍ប្រាំនាទី ចំពោះកិច្ចដំណើរការនៃការស្តាប់សក្ខីកម្មរបស់សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ អង្គជំនុំជម្រះយល់ឃើញថា សំណើនេះមិនទាន់សមស្របត្រូវពេលនៅឡើយទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យ ឌុច-- អឺ! ឲ្យលោក នួន ជា ធ្វើសេចក្តីថ្លែងការណ៍នាពេលនេះទេ គឺអនុញ្ញាតឲ្យគាត់ធ្វើសេចក្តីថ្លែងការណ៍តាមសិទ្ធិដែលគាត់មាននៅចុងក្រោយបង្អស់នៃការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។

[០៩:២២:៤២]

សូមប្រគល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា ដើម្បីបន្តការតាំងសំណួរជាក់លាក់ចំពោះសាក្សី។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់សាធារណជន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើ ឌុច លោកចាំឈ្មោះ ណាប់ ស៊ុនប៊ុន ដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សូមលោកមេធាវីអានឈ្មោះនេះឲ្យច្បាស់។ ខ្ញុំស្តាប់មិនច្បាស់ទេ។

[០៩:២៣:៥០]

**ស៖** ខ្ញុំយល់ថា ណាប់ សុនប៊ុន បាទ--

**អ្នកបកប្រែ៖**

អ្នកបកប្រែក៏ស្តាប់គាត់មិនច្បាស់ដែរ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ក៏ប៉ុន្តែខ្ញុំ *ស្ពែល* “N-A-B-S-O-N” ប៊ុន, “B-O-N-D” ប៊ុន បាទ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំនៅចាំឈ្មោះនេះ។

[០៩:២៤:៣០]

**ស៖** លោកបានធ្វើសក្ខីកម្មនៅក្នុងសវនាការនៅការជំនុំជម្រះរបស់លោកនោះ អំពីការសួរចម្លើយ ហើយនិងការធ្វើទារុណកម្មទៅលើជននេះនៅ ម-១៣។ ខ្ញុំសូមដកស្រង់អ្វីដែលលោកបាននិយាយនៅពេលនោះលោកបាននិយាយថា៖ “ខ្ញុំត្រូវប្រើពេលស្ទើរតែមួយខែ ដើម្បីបញ្ចប់។ ដូច្នេះហើយការធ្វើទារុណកម្ម ការវាយដំនៅក្នុងការសួរចម្លើយនោះក៏មានដែរ។ ខ្ញុំបានព្យាយាមយ៉ាងខ្លាំងដើម្បីធ្វើការងារនោះ”។ ចប់សេចក្តីដកស្រង់។ ខ្ញុំចង់សួរលោកដូចតទៅនេះ តើលោកចង់និយាយដូចម្តេច លោកថា ខ្ញុំបានខំប្រឹងអស់ពីសមត្ថភាព ដើម្បីធ្វើការងារនោះ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា បញ្ហានេះវាស្ថិតនៅក្នុងករណីម-១៣។ ដូច្នេះ បញ្ហានេះវាទាក់ទងដល់លោកសួរពីរឿងទារុណកម្ម ច្បាស់ជាសួរខ្ញុំពីរឿងទារុណកម្ម។ ដូច្នេះ ខ្ញុំសូមរក្សាសិទ្ធិមិនឆ្លើយ។

**ស៖** លោកនៅចាំលោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែរឬទេបាទ?

**ឆ៖** អរគុណ។ ខ្ញុំនៅចាំ ឈ្មោះ ហ្វ្រង់ស្វ័រ ប៊ីហ្សូ។

[០៩:២៦:២៩]

**ស៖** គាត់បានសរសេរសៀវភៅមួយ អំពីបទពិសោធន៍ ឬក៏អ្វីដែលគាត់បានឆ្លងកាត់នៅម-១៣ ហើយគាត់និយាយពីការសន្ទនាជាមួយលោកផងដែរ។ ហើយគាត់បានសួរលោកថា "អ្នកណាជាអ្នកវាយ ឬក៏ធ្វើទារុណកម្មនៅម-១៣?" ហើយលោកបានឆ្លើយទៅលោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ (François Bizot)ថា៖ "លោកបានវាយអ្នកទោសរហូតទាល់តែលោកហត់វាយលែងកើត"។ តើ-- ខ្ញុំចង់ដឹងថា លោកមានន័យដូចម្តេច នៅពេលដែលលោកនិយាយថា លោកបានធ្វើការងារហ្នឹងអស់ពីសមត្ថភាព?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សៀវភៅរបស់ឈ្មោះ ប៊ីហ្សូ នេះ ខ្ញុំបានរាយការណ៍ជូនសហចៅក្រម-- អ៎! សូមទោស ខ្ញុំបានរាយការណ៍ជូនលោកចៅក្រម ឡាវែន៍ រួចហើយថា មានលក្ខណៈជាកវីនិពន្ធ។ ខ្ញុំមិនយល់ទេ ខ្ញុំយល់តែក្នុងទំព័រ១៩៩ មួយម៉ាត់ ដែលគាត់និយាយអំពីឡាយ ហើយនិង សុន។ ក្រៅពីនោះវាមានលក្ខណៈជាកវីនិពន្ធ ជាកំណាព្យ ជាការប្រឌិត បំប៉ោងបញ្ហា។ ហ្នឹង ខ្ញុំនិយាយខ្លីជូនលោកចៅក្រម ឡាវែន៍ ថាជាកំណាព្យ។

[០៩:២៨:១៥]

**ស៖** តើលោកបានវាយអ្នកទោសរហូតទាល់តែអស់កម្លាំងហត់វាយលែងកើតឬទេ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីមិនបាច់ឆ្លើយនឹងសំណួរនេះទេ។ ទីមួយ ក្រៅអង្គហេតុ។ ទីពីរ សំណួរដែលមានពិរុទ្ធភាពដាក់បន្ទុកលើលោក អង្គជំនុំជម្រះបានប្រាប់ហើយ។ ហើយលោកមេធាវី ហើយលោកព្យាយាមក្នុងការតាំងសំណួររបៀបនេះជាច្រើន តើភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ ហើយអង្គជំនុំជម្រះកំណត់មកធ្វើសវនាការនៅក្នុងដីកាដំណោះស្រាយ ដែលបានបំបែកមកជាសំណុំរឿង០០២/០១ ហ្នឹង តើពាក់ព័ន្ធនៅត្រង់ចំណុចណាទៅសំណួរព្រឹកនេះ ដែលលោកបានចាប់ផ្តើមសួរប៉ុន្មានសំណួរនេះ? តើលោកអាចបង្ហាញបានទេ ថាពាក់ព័ន្ធយ៉ាងម៉េចជាមួយនឹងអង្គហេតុដែលចោទប្រកាន់ ហើយអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការសម្រាប់សំណុំរឿង០០២/០១។ នេះជាបញ្ហាទីមួយ។

បញ្ហាទីពីរ អង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ ទាំងអនុស្សរណៈ ទាំងពាក្យសម្តីផ្ទាល់មាត់ គឺសូមធានាថា ឲ្យធ្វើការដេញដោលតាមលេខស្ទីត នៃដីកាដំណោះស្រាយ ពីលេខតូចទៅលេខធំចំពោះអង្គហេតុទាំងឡាយ ដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងដីកាបំបែកដំណើរការដេញដោលផង

ហើយនិងសម្រាប់វគ្គមួយ វគ្គពីរផង បន្ទាប់មកទៀតគឺ វគ្គផ្សេងទៀត ពីព្រោះបង្ការក្រែងលោមិនមាននៅឱកាសក្នុងការកោះហៅសាក្សីមកផ្តល់សក្ខីកម្ម ឲ្យតែនៅក្នុងក្របខ័ណ្ឌសំណុំរឿង០០២/០១។

លោកអាចបកស្រាយលើ-- បំភ្លឺបញ្ហានេះបានទេ?

[០៩:៣០:១៧]

**លោក ម៉ៃខល ផេសមិន៖**

បាទ មានបញ្ហាជាច្រើន។ ជាបឋម ខ្ញុំសូមប្រកាន់ជំហរថាខ្ញុំមានសិទ្ធិក្នុងការតាំងសំណួរទៅសាក្សីទាក់ទងទៅនឹង ម-១៣ ប្រសិនបើសាក្សីរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប នោះជាជម្រើសរបស់គាត់ ប៉ុន្តែខ្ញុំនៅតែមានសិទ្ធិសួរ។ បាទ ប៉ុន្តែនៅពេលដែលខ្ញុំសួរសំណួរចុងក្រោយ សាក្សីមិនទាន់ឆ្លើយដូចម្តេចទេ លើកលែងតែអង្គជំនុំជម្រះបានរំឭកសិទ្ធិគាត់។ បន្ថែមលើនេះទៀត ខ្ញុំជឿថាអ្វីបានកើតឡើងមុនឆ្នាំ១៩៧៥ ជាផ្នែកមួយនៃបរិបទប្រវត្តិសាស្ត្រ ហើយពាក់ព័ន្ធទៅនឹងការជំនុំជម្រះ។ ហើយជាពិសេសទៅទៀត ខ្ញុំមកទីនេះដើម្បីខ្ញុំធ្វើតេស្តអំពីភាពអាចជឿជាក់បាន នៃការធ្វើសក្ខីកម្មរបស់សាក្សីរូបនេះ។ ដូច្នេះខ្ញុំគប្បីតែទទួលបានការអនុញ្ញាតឲ្យសួរ ឲ្យបានទូលំទូលាយនូវសំណួរទាំងឡាយដែលកូនក្តីរបស់ខ្ញុំគិតថាអាចនឹងធ្វើតេស្តពិសោធន៍នូវការ-- ភាពអាចជឿជាក់បានរបស់សក្ខីកម្មសាក្សីរូបនេះ។

[០៩:៣១:៣៧]

ហើយនិងចង់ដឹងថា តើកូនក្តីរបស់ខ្ញុំយល់ស្របទៅនឹងអ្វីដែលសាក្សីបានផ្តល់សក្ខីកម្មហ្នឹងដែរឬទេ? អាស្រ័យហេតុនេះតុលាការគប្បីតែអនុញ្ញាតឲ្យខ្ញុំបានសួរសំណួរ។ ជាពិសេសសួរដេញដោលអំពីគុណវុឌ្ឍិ អំពីភាពគួរឲ្យជឿជាក់បានរបស់សាក្សីរូបនេះ។ ជាពិសេសនៅក្នុងការផ្តល់សក្ខីកម្មទាក់ទងនឹងបទចោទប្រកាន់នៅក្នុងសំណុំរឿង០០២ និង០០១ នោះផងដែរ។

**ប្រធានអង្គជំនុំ៖**

លោកអាចតាំងសំណួរផ្សេងទៀតបាន សំណួរអំមិញ អង្គជំនុំជម្រះបានប្រាប់ទៅសាក្សីហើយមិនបាច់ឆ្លើយតបទៅនឹងសំណួរទេ ពីព្រោះសំណួរក្រៅអង្គហេតុ មិនពាក់ព័ន្ធទេ។ ហើយសំណួរនាំឲ្យចម្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង នៅអង្គហេតុដែលមិនទាន់បានវិនិច្ឆ័យសេចក្តីជាស្ថាពរនៅឡើយ។

[០៩:៣២:៤៦]

**លោក ម៉ៃខល ផេសមិន៖**

ដើម្បីក្នុងកំណត់ត្រាគឺថា-- ហើយសាក្សីគឺថាអាចបដិសេធនូវសំណួរណាដែលអាចធ្វើឲ្យគាត់

មានបន្ទុកពិរុទ្ធភាព។

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**សៈ** សំណួរបន្តទៅទៀត សួរថា ឌុច តើលោកបានសរសេរជាសៀវភៅមួយនិយាយថា សិក្សាកថា មេរៀនដកស្រង់ពីពិសោធន៍នៃចាស់ទុំជំនាន់មុន។ តើលោកជាអ្នកសរសេរអត្ថបទហ្នឹងដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវៈ**

**ឆៈ** អរគុណ។ ខ្ញុំសរសេរ។

**សៈ** ហើយគោលបំណងមួយនៃការសរសេរនេះ គឺដើម្បីបម្រើនូវទ្រឹស្តីនៃការបង្រួបបង្រួម និងការផ្សះផ្សាជាតិ។ ខ្ញុំគិតថាលោកសរសេរចំណុចនេះ លោកគិតថា វាមានសារៈសំខាន់ តើលោកអាចពន្យល់បានទេ ថាតើទ្រឹស្តីនៃការបង្រួបបង្រួមជាតិ និងការផ្សះផ្សាជាតិនេះ លោកអាចពន្យល់បានទេ? ខ្ញុំដឹងថាលោកមានសិទ្ធិ រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ទាក់ទងទៅនឹងតួនាទីរបស់លោកនៅ ម-១៣។

[០៩:៣៤:៤៨]

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់ឮសួរមេធាវីសួរខ្ញុំថាម៉េចផង ឮដូចគ្រាន់តែអធិប្បាយ។

**សៈ** នៅក្នុងសៀវភៅដែលលោកសរសេរហ្នឹង គឺថាលោកមានគោលបំណង គឺដើម្បីក្នុងគោលបំណងបម្រើឧត្តមគតិបង្រួបបង្រួមជាតិ និងផ្សះផ្សាជាតិ។ ដូច្នេះ ថាតើលោកអាចឆ្លើយមកខ្ញុំទេ ហេតុអីបានជាលោកមិនឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំទាក់ទងទៅនឹងតួនាទីរបស់លោកនៅម-១៣? ពីព្រោះលោកសរសេរមក លោកថា គឺលោកសរសេរសៀវភៅនេះក្នុងគោលបំណងបម្រើឧត្តមគតិបង្រួបបង្រួមជាតិ និងផ្សះផ្សាជាតិ។

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ សំណួរនេះ បើតាមខ្ញុំយល់ វាទាក់ទងដល់ការតស៊ូមនោគមន៍វិជ្ជា ការតស៊ូខាងផ្នែកឧត្តមគតិ។ ខ្ញុំយល់ថាបង្រួបបង្រួមជាតិ និងផ្សះផ្សាជាតិ វាមានន័យមួយខុសអំពីចាក់រុកធ្វើឲ្យជាតិបែកបាក់ ខ្ញុំយល់ឃើញអ៊ីចឹង។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

**សៈ** ខ្ញុំសូមចូលទៅសំណួរបន្ទាប់ទោះបីជាខ្ញុំមិនយល់នឹងចម្លើយនេះក៏ដោយ។ លោកសាក្សី លោកចាំ សាក្សី KW-30 ដែរឬទេ?

**ឆៈ** ខ្ញុំចាំ ពិតជាចាំ។

[០៩:៣៦:៥៤]

**ស៖** គាត់ឈ្មោះ អ៊ុច ស៊ន បើតាមដែលខ្ញុំដឹង គឺថាជាអ្នកទោសនៅម-១៣ ហើយលោកក៏បានធ្វើការសួរចម្លើយគាត់។ តើលោកចាំទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ បើតាមខ្ញុំចាំ នេះនិយាយតាមខ្ញុំចាំ ហើយការចាំនេះប្រហែលជាច្បាស់លាស់។ អ៊ុច ស៊ន នេះបញ្ជូនមកសម្រាប់បញ្ជូនចេញទៅខាងពោធិ៍សាត់ ទេ ខ្ញុំគ្មានបានសួរចម្លើយអីទេ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ប្រហែលជាខ្ញុំអាចជួយរំឭកការចងចាំដល់លោកបន្តិច ខ្ញុំសួរខ្លី-- ដកស្រង់ខ្លីទេពីចម្លើយរបស់គាត់ដែលអាចរកឃើញនៅក្នុងឯកសារ E1/11.1។ ខ្ញុំមានERN ជាអង់គ្លេស 00316602 ERN ជាភាសាខ្មែរ 00321001។ សូមអភ័យទោស គឺថាមិនមានលេខERN ជាភាសាបារាំងទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:៣៨:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី តើលោកអាចប្រាប់យើងថា យោងទៅសំណុំរឿង០០១ ឬសំណុំរឿង០០២? តើលោកចង់ដាក់ឲ្យដេញដោលឯកសារដែលមិនមែនជាឯកសារនៅក្នុងសំណុំរឿង០០២នេះ ជាឯកសារថ្មី ឬក៏យ៉ាងម៉េច?

**លោក ម៉ៃខល ផេសមិន៖**

វាជាឯកសារនៅក្នុងសំណុំរឿង០០១។ ខ្ញុំលើកមកសួរសាក្សីទេ ខ្ញុំមិនបានដាក់ជូនអង្គជំនុំជម្រះនៅឡើយទេ ក៏ប៉ុន្តែខ្ញុំយកឯកសារនេះ គឺថាមកសួរដេញដោលតទល់ជាមួយនឹងសាក្សីរូបនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំគិតថា ក្នុងករណីនេះលោកត្រូវតែធ្វើសំណើព្រោះថាជាឯកសារថ្មី ដែលយើងយកមកពិភាក្សាដេញដោល ព្រោះថាមិនមែនជាឯកសារដែលយើងដកស្រង់ចេញពីសំណុំរឿង០០២នោះទេ។ ខ្ញុំគិតថាវាមិននៅក្នុងបញ្ជីឯកសារថ្មី ដែលលោកបានដាក់ជូនទៅអង្គជំនុំជម្រះនោះទេ។

[០៩:៤០:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វិល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ឃើញថា ប្រតិចារឹកនៅក្នុងសំណុំរឿង០០១ គឺមាននៅក្នុងសំណុំរឿង០០២ គ្រាន់តែថា លេខដែលមេធាវីការពារក្តីនេះ គឺយើង-- តាមការពិតប្រតិចារឹកនៅក្នុងសំណុំរឿងហើយ គ្រាន់តែសំណួរ គឺបញ្ហាគឺត្រង់ថា តើមេធាវីការពារ នឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែរឬក៏អត់ ប្រតិចារឹកនេះក៏មាននៅក្នុងសំណុំរឿង០០២ ដែរ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាខ្លីទេ។ ប៉ុន្តែយើងខ្ញុំមានជំហរមួយថា នឹងជជីកសួរដេញដោលជាមួយនឹងសាក្សីរូបនេះ មិនចាំបាច់តម្រូវឲ្យមាននៅលើបញ្ជីឯកសារនោះទេ។ គ្រាន់តែជួយរំឭកថា ឧទាហរណ៍សហព្រះរាជអាជ្ញាបានប្រើគេហទំព័រយកមកចោទសួរសាក្សីរូបនេះ។ នៅពេលដែលសួរថា តើយើងខ្ញុំតម្រូវឲ្យដាក់ឯកសារទាំងអស់ ដែលយើងមានបំណងចង់សាកសួរ ទាក់ទងទៅនឹងការសួរដេញដោល ដើម្បីដាក់បញ្ជីឯកសារជូននៅចំពោះមុខអង្គជំនុំជម្រះ។ យើងបានជម្រាបជូនមន្ត្រីច្បាប់ជាន់ខ្ពស់ហើយថា មិនចាំបាច់ដូច្នេះទេ ដាក់នៅក្នុងបញ្ជីឯកសារដែលមិនមែនឯកសារ-- បញ្ជីឯកសារយើងបានដាក់ ក៏ប៉ុន្តែឯកសារសម្រាប់ការចោទសួរសាក្សី គឺថាមិនចាំបាច់ដាក់លើបញ្ជីឯកសារនោះទេ។

[០៩:៤១:៤៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីអន្តរជាតិតំណាង-- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំយល់ដូច-- យល់ឃើញថាប្រតិចារឹកនៃសំណុំរឿង០០១ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង០០២ ក៏ប៉ុន្តែខ្ញុំប្រឆាំងទៅនឹងគំនិតដែលថាយើងអាចប្រើឯកសារថ្មីទាំងឡាយណា ដោយមិនបានគោរពទៅវិធាន ដែលអង្គជំនុំជម្រះកំណត់ គឺថាត្រូវសុំការអនុញ្ញាតជាបឋមមុននឹងបង្ហាញឯកសារ។ ហើយខ្ញុំមិនចង់ឲ្យថា យើងទាញការសន្និដ្ឋានថា យើងអាចបង្ហាញឯកសារគ្រប់ពេលវេលាមិនថាឯកសារនោះទេ។ ខ្ញុំគិតថា ភាគីទាំងអស់ត្រូវតែយល់ឃើញថា វិធានដែលអង្គជំនុំជម្រះបានចេញហើយនោះ យើងត្រូវតែគោរពទាំងអស់គ្នា។

[០៩:៤២:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៤:៣២]

**ប្រធានអង្គជំនុំ៖**

ប្រគល់ភារៈទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសួរបញ្ហាខ្លះទៅមេធាវី ផេសមិន ពាក់ព័ន្ធនឹងឯកសារចុងក្រោយ ដែលគាត់មានបំណងលើកមកសួរដេញដោលចំពោះសាក្សី។

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោក ផេសមិន តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ ថាតើលោកយកឯកសារណាជាមូលដ្ឋានដើម្បីចោទសំណួរទៅសាក្សីនេះ? តើលោក-- តើនេះជាផ្នែកមួយនៃប្រតិចារឹកនៃសំណុំរឿង០០១ ឬក៏ជាឯកសារផ្សេងទៀត ឬក៏ៗកំណត់ហេតុស្ដាប់ចម្លើយនៃក្នុងដំណាក់កាលស៊ើបអង្កេតនៅក្នុងសំណុំរឿង០០១? តើជាអ្វីទៅពិតប្រាកដនោះ? តើមានភាពពាក់ព័ន្ធអ្វីដែរសំណួររបស់លោកនោះ ទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទនៅមន្ទីរម-១៣? យើងចង់ដឹងឲ្យជាក់លាក់ថា សំណួររបស់លោកនោះមានភាពពាក់ព័ន្ធអ្វីទៅនឹងអង្គហេតុ ដែលយើងយកមកពិភាក្សាដេញដោលនៅថ្ងៃនេះនេះ។

[០៩:៤៦:០៤]

**លោក ម៉ៃខល ផេសមិន៖**

នេះគឺជាឯកសារជាក់លាក់មួយដែលខ្ញុំចង់យកមកប្រើប្រាស់ គឺយកពីប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ហើយត្រូវបានដាក់បញ្ចូលមកក្នុងសំណុំរឿ០០២ ហើយ។ ឯកសារនេះមានលេខថ្មី គឺឯកសារ D288/4.11.1 ហើយទាក់ទងទៅនឹងតួនាទីរបស់សាក្សីនៅម-១៣។ ហេតុដូច្នេះឯងបានជាខ្ញុំចង់សួរតទល់ជាមួយនឹងសាក្សីរូបនេះពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម។ ហើយហាក់បីដូចជាគាត់ថាគាត់រីករាយក្នុងការធ្វើទារុណកម្មនេះ។ ប៉ុន្តែប្រសិនបើជាអង្គជំនុំជម្រះថា មិនអនុញ្ញាតឲ្យសាកសួរ គឺថាខ្ញុំនឹងបន្តទៅទៀត។ ប៉ុន្តែខ្ញុំនៅប្រកាន់ជំហរថា យើងខ្ញុំត្រូវតែទទួលបាននូវការអនុញ្ញាតឲ្យជជែកសួរដេញដោលស្វែងរកភាពគួរឲ្យទុកចិត្តបានពីសាក្សីរូបនេះ។

ដូច្នេះ មិនគួរកម្រិតចំពោះការតាំងសំណួររបស់ខ្ញុំនៅក្នុងសវនាការវគ្គទីមួយ នេះទេ។

[០៩:៤៧:២៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកមេធាវីព្យាយាមក្នុងការតាំងសំណួរចំពោះការសាក្សី ដើម្បីឲ្យសាក្សីផ្តល់ចម្លើយ ឬក៏អំណះអំណាងរបស់ខ្លួនបង្ហាញលាតត្រដាងអំពីពិរុទ្ធភាពដាក់បន្ទុកលើខ្លួនឯងទេ ព្រោះនេះជាសិទ្ធិរបស់សាក្សីក្នុងការមិនឆ្លើយផ្តល់ព័ត៌មាន តបទៅនឹងសំណួរដែលនាំឲ្យលទ្ធផលនៃការចម្លើយ ឬអំណះអំណាងនោះដាក់បន្ទុកលើខ្លួនឯង។ ពីព្រោះអង្គហេតុម-១៣ មិនទាន់ត្រូវបានពិនិត្យវិនិច្ឆ័យនៅឡើយទេ។

[០៩:៤៨:០៩]

បញ្ហាទីពីរ គឺអង្គជំនុំជម្រះកំណត់ឲ្យលោកសួរដេញដោលឲ្យអង្គហេតុពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើសវនាការពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។ ភាពពាក់ព័ន្ធនៃសំណួរ និងចម្លើយទៅនឹងអង្គហេតុដែលចោទប្រកាន់ ដើម្បីឈានទៅដល់ការស្វែងរកការពិត។

[០៩:៤៨:៤២]

ដូច្នេះសំណួរអម្បាញ់មិញចុងក្រោយនេះ យើងមិនអនុញ្ញាតឲ្យសួរទេ ឲ្យៗ-- សាក្សីឆ្លើយតបទេ។ បើលោកមានសំណួរផ្សេងទៀត គឺលោកអាចបន្តសំណួរផ្សេងថ្មីទៀតរបស់លោកបាន។

**លោក ម៉ៃខល ផេសមិន៖**

អង្គជំនុំជម្រះ មុននឹងខ្ញុំបន្ត ខ្ញុំសូមលើកថាសំណួររបស់ខ្ញុំទាំងអស់ គឺមានបំណងស្វែងរកនូវភាពគួរឲ្យទុកចិត្តបាននៃសាក្សីនេះ។ តែបើអង្គជំនុំជម្រះយល់ថាមិនអនុញ្ញាតឲ្យខ្ញុំធ្វើទេ ដូច្នេះបើ-- ដូច្នេះមិនអនុញ្ញាតឲ្យខ្ញុំបន្តសំណួរអីតទៅទៀតនោះទេ ពីព្រោះសំណួររបស់ខ្ញុំគឺដើម្បីសួរតទល់នឹងសាក្សីរូបនេះ ស្វែងរកនូវភាពគួរឲ្យជឿជាក់បាន។

[០៩:៤៩:៤១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

យោបល់របស់សហព្រះរាជអាជ្ញា គឺថាមេធាវីការពារក្តី គឺមានសិទ្ធិក្នុងការសួរទៅដល់ភាពគួរឲ្យទុកចិត្ត និងជឿជាក់ទៅលើសាក្សីរូបនេះ។ ប៉ុន្តែជាញឹកញាប់ គឺថាមិនសួរទៅតាមខ្សែចង្វាក់ ឬលំដាប់លំដោយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ។ ក៏ប៉ុន្តែអ្វីដែលយើងខ្ញុំចង់លើកឡើងគឺថា វិធានផ្ទៃ

ក្នុងដែលអនុញ្ញាតឲ្យប្រើប្រាស់ឯកសារ គឺថាត្រូវតែឲ្យវាស៊ីសង្វាក់ជាមួយភាគីដទៃទៀត។ សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យសួរនូវខ្លឹមសារជាក់លាក់មួយចំនួនចំពោះសាក្សីរូបនេះទេ ដែលថា ដោយសារតែសាក្សីរូបនេះមិនបានស្គាល់ឯកសារ ឬក៏-- លោកស្រីចៅក្រម ខាតវ៉ាយថ៍ បាននិយាយថា ការចោទសួរអាចនឹងលើកៗមកចោទសួរបាន។ ប៉ុន្តែមិនមែនខ្លឹមសារជាក់លាក់ណានោះទេ លើកលែងតែសាក្សីបានដឹង ចំពោះឯក-- ធ្លាប់បានឃើញចំពោះឯកសារនោះ។

[០៩:៥០:៥៤]

ទាក់ទងទៅនឹងការប្រើប្រាស់ឯកសារវិញ ដែលមិនបានដាក់នៅក្នុងបញ្ជីរបស់មេធាវីការពារក្តីដែលខ្លួនដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ យើងខ្ញុំយល់ឃើញថា មានលក្ខណៈខុសគ្នារវាងឯកសារខ្លះដែលតម្រូវឲ្យយកមកប្រើប្រាស់ដើម្បីសាកសួរដេញដោលនូវភាពគួរឲ្យទុកចិត្តបាន និងជឿជាក់បាននៃសាក្សីនេះ។

យើងបានពិភាក្សាជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ហើយថា ត្រូវមានការជូនដំណឹងជាមុនដើម្បី--មកដល់ភាគីនូវឯកសារទាំងឡាយណា ដែលភាគីមានបំណងយកមកសាកសួរដេញដោលដើម្បីស្វែងរកភាពគួរឲ្យទុកចិត្តបាន។ ប៉ុន្តែឯកសារនេះគឺត្រូវតែដាក់មកក្នុងចំពោះមុខអង្គជំនុំជម្រះក្នុងសវនាការនេះហើយនិងជម្រាបថាឯកសារមកពីណា ហើយគោលបំណងអីបានជាខ្លួនយកឯកសារនេះមកប្រើប្រាស់។

[០៩:៥១:៥១]

ក្នុងករណីនេះគឺថា មេធាវីការពារក្តីត្រូវតែយកឯកសារ បញ្ជីឯកសារចុះថ្ងៃ១៩ ខែកុម្ភៈ របស់ខ្លួន យកមកប្រើប្រាស់។ ហើយក្នុងពេលផ្តល់សក្ខីកម្មនេះសោតទៀត គឺថា តែយ៉ាងហោចណាស់គឺត្រូវតែ ត្រូវមានការជូនដំណឹងយ៉ាងតិចបំផុត២៤ម៉ោងមុនដែរ ដែល-- ខ្ញុំគិតថា មេធាវីការពារក្តីបានដឹងជាមុនរួចទៅហើយតាំងពីម្សិលមិញមកម្ល៉េះ។ ដូច្នេះ វិធានផ្ទៃក្នុងដូចគ្នា គឺថាត្រូវតែយកមកអនុវត្តដូចៗគ្នាចំពោះការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមបន្ថែមពីរបីម៉ាត់ទៀត។ បន្ទាប់ពីការពិចារណារបស់សហភាគារបស់ខ្ញុំដែលលើកឡើងថា រាល់បញ្ហាដែលទាក់ទងនឹងភាពទុកចិត្តបាននៃសាក្សី ខ្ញុំយល់ឃើញថា សហភាគា

របស់ខ្ញុំ គាត់អម្បាញ់មិញគាត់យល់ឃើញថា បើសិនជាមិនឲ្យគាត់ចោទសំណួរនោះទេ គឺថា បានន័យថាយើងរាំងស្ទះមិនឲ្យគាត់ចោទជាបញ្ហានូវភាពទុកចិត្តរបស់សាក្សី។ ក៏ប៉ុន្តែខ្ញុំយល់ឃើញថា គាត់កំពុងតែរំលោភ គឺថាមិនគិតគូរអំពីសិទ្ធិរបស់សាក្សី។ បើសិនជាគាត់មិនអាចចោទសំណួរបាននោះ ពីព្រោះថាសាក្សីមិនអាចឆ្លើយដាក់បន្ទុកខ្លួនឯងនោះទេ ដូច្នេះមិនត្រូវភ្លេចអំពីសិទ្ធិរបស់ជនជាប់ចោទ ហើយយើងមិន-- យើងយល់ ថាសិទ្ធិរបស់ជនជាប់ចោទដែលថាគាត់មានសិទ្ធិនៅស្ងៀមស្ងាត់។ អ៊ីចឹងយើងមិនត្រូវថា ធ្វើឲ្យ-- យើងមិនត្រូវបង្វែរបញ្ហា ពីបញ្ហាដែលថាការពារការយល់សិទ្ធិរបស់សាក្សី ហើយនិងបង្វែរពីហ្នឹងទៅតែនិយាយតែអំពីសិទ្ធិជនជាប់ចោទនោះទេ។

[០៩:៥៤:00]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:00:៥៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ផេសមិន អង្គជំនុំជម្រះសូមជម្រាបលោកមេធាវីថា លោកមានសិទ្ធិពេញទី ពេញលេញ បរិបូរនៅក្នុងការសួរដេញដោលដើម្បីឲ្យមានភាពជំនឿទុកចិត្តបាន លើភស្តុតាង លើសាក្សីរូបនេះ ដែលនៅបច្ចុប្បន្ននេះ គឺសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ នេះ ជាសិទ្ធិរបស់លោក ប៉ុន្តែសិទ្ធិនេះត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនឹងការសួរដេញដោលចំពោះសាក្សី។ ទីពីរ ឯកសារដែលលោកយកមកដេញដោលត្រូវជា-- ត្រូវតែឯកសារដែលមាននៅក្នុងសំណុំរឿង០០២។ ទីបី គឺឯកសារដែលលោកនឹងយកមកប្រើប្រាស់ នៅក្នុងការដេញដោលត្រូវអនុវត្តទៅតាមការណែនាំរបស់អង្គជំនុំជម្រះ គឺត្រូវជូនមកភាគីឲ្យបានដឹងជាមុន យ៉ាងតិច២៤ម៉ោង។ ទីបួន គ្មានហេតុផលអ្វីប្រយោជន៍អ្វីទេ ដែលការសួរដេញដោលនូវអង្គហេតុទាំងឡាយ ដែលនៅក្រៅអំពីដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ ដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើការពិភាក្សាដេញដោលសម្រាប់វគ្គដំបូងនេះ គឺសំណុំរឿង០០២/០១។

[១០:0២:៤៩]

នៅក្នុងនោះដែរ គឺមានទាំងលោកផងដែរ មិនត្រឹមត្រូវតែភាគីដទៃទេ តែងតែមានការតវ៉ាជំទាស់ជាញឹកញាប់នៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោលកន្លងមកនេះ។ ជាពិសេស សំណួរដែលមិនពាក់ព័ន្ធ សំណួរនាំមុខ សំណួរច្រំដែល សំណួរបែបឧបមាណវិធី ជាដើម។ ដូច្នេះ នៅក្នុងការបំពេញ

មុខងាររបស់លោកក្នុងការសួរសាក្សីរូបនេះ គប្បីត្រូវបានអនុវត្តឲ្យបានត្រឹមត្រូវ ដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនលោករួចហើយនេះ។

ហើយដើម្បីបញ្ជាក់បញ្ហានេះ ឲ្យកាន់តែច្បាស់ថែមទៀត ក្រែងលោមានការនិយាយទៅមិនពេញលេញ ឬក៏មានការឆកល្វែង ដោយសារការបកប្រែភាសាជាដើម អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់បញ្ហានេះ បន្ថែមឲ្យកាន់តែច្បាស់ថែមទៀត ដើម្បីដោះស្រាយបញ្ហានេះ ឲ្យបានជ្រះស្រឡះនៅពេលនេះតែម្តង។

សូមអញ្ជើញលោកស្រីចៅក្រម!

[១០:០៤:២២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់អំពីសេចក្តីសម្រេចរបស់លោកប្រធានរួចហើយ ថាមេធាវីការពារជនជាប់ចោទមានសិទ្ធិក្នុងការសួរសំណួរទាំងឡាយ ដែលធ្វើតេស្តអំពីភាពជឿជាក់សាក្សីរូបនេះ ឬក៏សាក្សីផ្សេងទៀត ប្រសិនបើសំណួរទាំងអស់នោះ ផ្អែកទៅលើឯកសារណាមួយ ហើយឯកសារនោះ ត្រូវតែស្ថិតនៅក្នុងសំណុំរឿង។ ហើយត្រូវបានជូនដំណឹងទៅដល់ភាគីផ្សេងៗ និងអង្គជំនុំជម្រះផង យ៉ាងហោចណាស់២៤ម៉ោងមុន នឹងយកមកដេញដោល។

[១០:០៤:៥៩]

សំណួរទាំងឡាយណា ត្រូវតែគោរពទៅតាមវិធានផ្ទៃក្នុង ហើយមិនត្រូវតែសំណួរច្រំដែលមិនពាក់ព័ន្ធ ហើយនិងឧទាហរណ៍ផ្សេងទៀតដែលលោកប្រធានបានបញ្ជាក់អំមិញនេះ។ ហើយតាមពិតសាក្សីមានសិទ្ធិក្នុងការមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង។ ដូច្នេះលោកត្រូវតែទទួលស្គាល់ថា លោកសាក្សីគាត់មិនឆ្លើយសំណួរមួយចំនួនទេ។ ជាពិសេស គឺទាក់ទងទៅនឹងសំណួរទាំងឡាយដែលអាចនឹងដាក់បន្ទុក ឬក៏សំណួរផ្សេងៗ។ មេធាវីតើលោកយល់ទេ មេធាវី?

**លោក ម៉ៃខល ផេសមិន៖**

បាទ អរគុណច្រើនលោកស្រីចៅក្រម។ ខ្ញុំនឹងជូនឯកសារទៅដល់អង្គជំនុំជម្រះនៅពេលក្រោយ មុននឹងយើងខ្ញុំសួរទៅសាក្សី។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ហើយនិងភាគីផងដែរ។

**លោក ម៉ៃខល ផេសមិន៖**

បាទ ខ្ញុំនឹងធ្វើដូច្នោះ មុននឹងសួរដេញដោលខ្ញុំនឹងបញ្ជូនឯកសារគ្រប់ភាគីផងដែរ។ ខ្ញុំជឿជាក់ថា ឯកសារទាំងអស់ដែលខ្ញុំនឹងយកមកប្រើដើម្បីសួរដេញដោលសាក្សីរូបនេះ គឺស្ថិតនៅក្នុងសំណុំរឿងរួចហើយ។ ប៉ុន្តែយើងខ្ញុំសូមប្រកាន់ជំហរថា ប្រសិនបើមិនមានទេ ប៉ុន្តែឯកសារទាំងអស់នោះ វាមានភាពពាក់ព័ន្ធ ហើយនិងជួយបង្ហាញដល់ការពិត គប្បីតែអនុញ្ញាតឲ្យខ្ញុំប្រើដើម្បីនឹងខ្ញុំបន្តទៅបាន។ តាមពិតយើងគោរពសិទ្ធិរបស់សាក្សីថា គាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

ខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេង។

[១០:០៦:៤១]

**ប្រធានអង្គជំនុំ៖**

មុននឹងចូលទៅកុំឲ្យលោក-- បញ្ហាដែលលោកៗស្នើសុំអម្បាញ់មិញមានការភ័ន្តច្រឡំ។ ឯកសារថ្មីដែលមិនមាននៅក្នុងសំណុំរឿង អង្គជំនុំជម្រះមិនអនុញ្ញាតឡើយ។ មិនអនុញ្ញាតឲ្យមកលើក លោកយកសួរ ដាក់សួរដេញដោលឡើយ ព្រោះអំមិញលោកបាននិយាយភ្ជាប់នឹងបញ្ហាហ្នឹង គឺភ្ជាប់ទៅនឹងឯកសារថ្មីតាមដែលលោកចង់។ បញ្ហានេះអង្គជំនុំជម្រះគឺមិនអនុញ្ញាតទេណ៎ា! ចៀសវាងលោកច្រឡំដោយការស្ងៀមស្ងាត់របស់អង្គជំនុំជម្រះទៅ គឺលោកយកឯកសារថ្មីផ្សេងទៀតមកដាក់ពិភាក្សាដេញដោល ដូចស្ថានភាពដែលកើតឡើងអម្បាញ់មិញទៀតទៅថ្ងៃមុខ។

សូមអញ្ជើញ!

[១០:០៧:៣៦]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច នៅឆ្នាំ២០០៧ លោកបានជម្រាបសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ថាលោក

បានឮពាក្យ "ក្រុមក្ដៅ ក្រុមអង្កៀម ហើយនិងក្រុមត្រជាក់" នោះ លើកដំបូងគឺលោកបានឃើញនៅពេលដែលលោកបានឃើញខ្សែភាពយន្ត រិទ្ធី ប៉ាន់ អំពី ស-២១ ទេ មុនហ្នឹងលោកមិនបានដឹងទេ។ តើលោកនៅចាំថាលោកបាននិយាយអ៊ីចឹងទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ បើសិនជាលោកមេធាវីសួរខ្ញុំចាំ ឬមិនចាំ បង្ហាញឯកសារមក ស្រួលនិយាយគ្នាជាង។

[១០:០៨:៤០]

**ស៖** ឯកសារ D86/6 បាទ។ អង់គ្លេស ERN 001147105 ខ្មែរ ERN 0014663 សូមអភ័យទោសដែលខ្ញុំមិនមានអត្ថបទ ERN ជាភាសាបារាំងទេ។ បាទ នៅទំព័រទីប្រាំមួយ អំពីបទសម្ភាសន៍មួយនោះបាទ។ ខ្ញុំនឹងអានជូនលោកស្តាប់។ សហចៅក្រមស៊ើបអង្កេត ឡឺម៉ុងដ៍ បានសួរលោកថា “តើលោកធ្លាប់ឮពាក្យ ឬបានឃើញពាក្យ ការប្រើពាក្យ ក្រុមក្តៅ ក្រុមត្រជាក់ ក្រុមអង្កៀម ដែរឬទេ?” លោកឆ្លើយនៅកាលណោះថានៅឆ្នាំ២០០៧ “ខ្ញុំបានឮពាក្យនេះ បន្ទាប់ពីខ្ញុំបានមើលខ្សែភាពយន្តរបស់ រិទ្ធី ប៉ាន់”។

[១០:០៩:៥៩]

សំណួររបស់ខ្ញុំទៅលោកគឺ ហេតុអ្វីក៏បានលោកចៅក្រម ពេលនោះថាលោកមិនបានដឹងពីពាក្យហ្នឹងទេ លើកលែងតែក្រោយដែលលោកបានឃើញខ្សែភាពយន្ត រិទ្ធី ប៉ាន់ បានលោកដឹង?

**លោក កាំង ហ្កេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឲ្យលោកមេធាវីបង្ហាញឯកសារនេះចំពោះមុខខ្ញុំ ឬក៏លើអេក្រង់។

**ប្រធានអង្គជំនុំ៖**

មេធាវីមានត្រៀមបម្រុងទុកនូវឯកសារជាក្រដាសដូចភាគីដទៃ ដែលបានធ្វើទេ ដើម្បីបង្ហាញទៅមេធាវីរូបនេះ-- អ៎! ទៅសាក្សី ដើម្បីសាក្សីពិនិត្យជាមុនជាភាសាខ្មែរ ដែលគាត់យល់ច្បាស់ មុននឹងគាត់ឆ្លើយ ព្រោះយើងបានអនុវត្តរបៀបនេះច្រើនថ្ងៃហើយ។ មានដែរទេ ឥឡូវនេះ? ទីពីរបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការបញ្ចាំងឯកសារអម្បាញ់មិញលើកញ្ចក់អេក្រង់ទូរទស្សន៍ ជាពិសេស ត្រង់ចំណុចដែលពាក់ព័ន្ធនឹងការតាំងសំណួរ។

[១០:១១:២២]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសង្ឃឹមថា ខ្ញុំបានជូនឯកសារជាលេខហើយ។ ហើយខ្ញុំបានដកស្រង់ឯកសារមួយចំនួន សាក្សី

បានឆ្លើយពីមុនរួចមកហើយ គាត់មិនបានស្នើសុំឱ្យបង្ហាញនៅលើអេក្រង់ទេកាលពីមុននោះ។ បាទ បើសិនជាគាត់ទាមទារបែបនេះ ខ្ញុំស្ទើរតែមិនអាចបញ្ចប់ការតាំងសំណួររបស់ខ្ញុំនៅថ្ងៃនេះបានទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:១១:៥៧]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំយល់ថា ប្រសិនថាមេធាវីមិនបានត្រៀមបែបនោះទេ គឺថាអាចនឹងធ្វើឱ្យមានការលំបាក ឬក៏អាចនឹងធ្វើការ-- យើងដូចប្តូរបែបបទការងារហ្នឹងទៅពីរបីថ្ងៃខាងមុខទៀត។ សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី បាទយើងត្រូវបង្ហាញឯកសារជូនទៅសាក្សី ហើយនិងលើអេក្រង់ផងដែរ ដើម្បីឱ្យគាត់ឆ្លើយបាន។ ជាពិសេស លោកប្រធានជ្រាបហើយ គឺថាសំណួរទាំងឡាយដែលយើងសួរទៅសាក្សី ជាពិសេសអំពីចម្លើយរបស់គាត់នៅសហចៅក្រមស៊ើបអង្កេត គឺថាជាការសមស្របឱ្យសាក្សីបានមើលចម្លើយនោះ ដើម្បីឱ្យគាត់នឹកឃើញពីការចងចាំឡើងវិញ។ ដូចដែលលោកចៅក្រមជ្រាបហើយ គឺថាការផ្តល់សក្ខីកម្មហ្នឹងប្រហែលជា៣០០ម៉ោងឯណោះ ហើយអ្វីៗហ្នឹងគឺវាច្រើន។

[១០:១២:៥៨]

ដូច្នេះដើម្បីឱ្យគាត់ឆ្លើយពិស្តារបាននោះ គឺថាបើមានការប្រើចម្លើយរបស់គាត់ពីមុន គឺថាគប្បីបានផ្តល់ឱកាសឱ្យគាត់បានមើលឯកសារនោះ ដើម្បីឱ្យគាត់ឆ្លើយ ឬធ្វើក៏យោបល់។ ភាគីគប្បីតែគោរពកាតព្វកិច្ចនេះ។ យើងខ្ញុំជឿជាក់ថា មេធាវីការពារគប្បីតែធ្វើបែបនោះ។ ចំពោះដើម្បីធានានូវអត្ថប្រយោជន៍ដល់សាក្សី ដែលថាគាត់មានសៀវភៅតាំងពីចំណុចមួយដល់ទីប្រាំរយជាដើមនោះ គឺថាសៀវភៅទាំងអស់នោះ គឺថា សាក្សីគាត់មានសៀវភៅ ហើយយើងអាចនឹងផ្តល់ជូនជា *ភីឌីអេហ្វ* ទៅខាងមេធាវីការពារ។ ដូច្នេះដើម្បីឱ្យសាក្សីអាចឆ្លើយត្រឹមត្រូវទៅតាមឆ្លើយរបស់គាត់ត្រឹមត្រូវនោះ គឺថាត្រូវតែបង្ហាញឯកសារទៅគាត់ មិនត្រឹមតែមេធាវីលើកឡើងពីសម្តីពីខ្លឹមសារនោះទេ ហើយភាគីទាំងអស់គប្បីតែធ្វើដូច្នោះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំអាចសូមឆ្លើយតបទៅនឹងគាត់។ តាមពិតគឺថាវាមានភាពខុស

គ្មានវាងចម្លើយដែលមេ-- ដែលសាក្សីផ្តល់ទៅសហចៅក្រមស៊ើបអង្កេត មិនចាំបាច់ផ្តល់យថាភាពអ្វីទៀតនោះទេ បើឯកសារផ្សេងបាន-- ទើប យើងធ្វើដូច្នោះ។ ដូច្នេះចម្លើយដែលបាន-- គាត់ឆ្លើយទៅឲ្យសហចៅក្រមស៊ើបអង្កេតនោះ ខ្ញុំដកស្រង់តែមួយឃ្លាពីចម្លើយនោះទេ មិនចាំបាច់បង្ហាញគាត់ទេ។ បើសិនជាគាត់មិនយល់អ្វីដែលខ្ញុំនិយាយ គឺថាគាត់អាចសុំឲ្យខ្ញុំថាឡើងវិញ។ អ៊ីចឹងខ្ញុំមិនចាំបាច់បង្ហាញឯកសារចម្លើយទាំងស្រុងទៅដល់គាត់មើលទេ នូវអ្វីដែលគាត់បានឆ្លើយទៅចៅក្រមស៊ើបអង្កេតនោះបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីត្រូវការចាំបាច់មើលឯកសារជាក្រដាសទេឥឡូវនេះ?

[១០:១៤:៥៩]

**លោក កាំង ហ្កេកអ៊ាវ៖**

អរគុណលោកប្រធាន។ ខ្ញុំត្រូវការ។

**ប្រធានអង្គជំនុំ៖**

ឥឡូវសាក្សីត្រូវការឯកសារជាក្រដាស ដើម្បីគាត់មើលមុននឹងឆ្លើយ ពីព្រោះការអនុវត្តរបៀបនេះ គឺយើងធ្វើច្រើនហើយ ទាំងចម្លើយកំណត់ហេតុយកចម្លើយផង គឺយើងបានឯកភាពគ្នារួចហើយថាផ្តល់ឲ្យសាក្សីជាមុន អាន ដើម្បីរំឭកអំពីការចងចាំរបស់គាត់ ដែលគាត់បានផ្តល់សក្ខីកម្មក្នុងរយៈពេលកន្លងមក មុននឹងគាត់មក ចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

[១០:១៥:៤៩]

**លោក ម៉ៃខល ផេសមិន៖**

ឥឡូវនេះឯកសារនៅលើអេក្រង់ហើយ សាក្សីអាចមើលបាន។ លោកអាចមើលនៅលើអេក្រង់ បើសិនជាលោកមិនអាចអានទេ ខ្ញុំនឹង *ព្រីន* បោះពុម្ពចេញជូនលោកមួយទំព័រត្រង់ចំណុចនោះ។ បាទ

ដូច្នេះលោកអាចមើលនៅក្នុងអេក្រង់។

សូមអភ័យទោសលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ? សូមអភ័យទោសយ៉ាងម៉េចទៅ? រឿងអីទៅ?

**លោក ម៉ៃខល ផេសមិនៈ**

បាទសូមអភ័យទោស នេះមិនមែនជា ឯកសាររបស់ខ្ញុំទេ។ យើងមិនបានដាក់ឯកសារនេះទេនៅលើអេក្រង់។ យើងមានឯកសារ បាទមានខ្លឹមសារប្រយោគមួយ ដែលខ្ញុំបានលើកឡើងនោះបាទ។

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**សៈ** តើលោកអាចឆ្លើយសំណួរខ្ញុំបានហើយឬនៅ ពេលដែលលោកឃើញឯកសារលើអេក្រង់នេះ? ហេតុអ្វីបានជាលោកជម្រាបចៅក្រមស៊ើបអង្កេត កាលនោះថា លោកមិនបានដឹងថា មានពាក្យនេះទេនៅពេលដែល-- លោកបានដឹងពាក្យនេះ នៅពេលដែលបានឃើញកុនរបស់ រិទ្ធី ប៉ាន់ ។

**ផៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អំពីបញ្ហាក្រុមក្តៅ ក្រុមត្រជាក់ ក្រុមអង្កៀមនេះ វាមិនមែនមានត្រឹមតែមួយម៉ាត់នេះទេ។ វាមានហូរហែ បើនិយាយអំពីភាពសុចរិតរបស់អ្នកសួរ ខ្ញុំគិតថា គួរណាស់តែអ្នកសួរប្រមូលទាំងអស់ ពាក្យដែលខ្ញុំឆ្លើយនៅការិយាល័យសហចៅក្រមស៊ើបអង្កេតយកមក ហើយឲ្យខ្ញុំពន្យល់ថាម៉េចបានជាម្តងនិយាយអ៊ីចេះ ម្តងនិយាយអ៊ីចុះ? នេះបានៗវាច្បាស់ថាតើខ្ញុំវាមានភាពស្មោះត្រង់នឹងសភាពការណ៍កន្លងមកហើយឬអត់? ហើយខ្ញុំសូមបញ្ជាក់ថា ពាក្យនេះខ្ញុំឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេត នៅពេលដែល៣០ឆ្នាំក្រោយ ពីរឿងនេះវាកើតឡើង។ រួចលោកច្បិចយកតែមួយម៉ាត់នេះមក ខ្ញុំសូមប្តឹងតុលាការតែម្តងថា លោកចុចតែមួយកន្លែងមកដើម្បីសង្កត់ខ្ញុំរកពិរុទ្ធភាពរបស់ខ្ញុំ។ មិនល្អទេ ខ្ញុំគិតថា មិនជាសប្បុរសទេ សំណួររបស់លោកមានបំណងមួយច្បាស់លាស់ គឺដាក់ពិរុទ្ធភាពដល់ខ្ញុំ លាក់បិទបាំងពិរុទ្ធភាពរបស់កូនក្តីលោក។

[១០:១៩:៤៥]

**សៈ** តើលោកបានឮពាក្យទាំងបីនេះដំបូងនៅពេលណា? គឺពាក្យថា “ក្រុមក្តៅ ក្រុមត្រជាក់ ក្រុមអង្កៀម”?

**ផៈ** ដើម្បីនិយាយគ្នាឲ្យស្រួលស្តាប់ ហើយដើម្បីសម្តែងការស្មោះត្រង់រវាងគ្នាទៅវិញទៅមក សូមលោកប្រមូលឯកសារខ្ញុំនៅ ន៎ែ! ការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីបញ្ហាក្រុមត្រជាក់ ក្រុមក្តៅហ្នឹងឲ្យបានច្បាស់មក ទាំងអស់មក ហើយយើងប្រមូលទាំងអស់គ្នា ម៉េចក៏បានពេលនេះខ្ញុំឆ្លើយអ៊ីចេះ ពេលនោះ ខ្ញុំឆ្លើយអ៊ីចុះ! កុំច្បិចតែមួយម៉ាត់យកមកសួរខ្ញុំ។

**សៈ** លោកសាក្សី ខ្ញុំសូមជម្រាបលោកថា សូមលោកឆ្លើយសំណួរខ្ញុំផង។ ពីដំបូងបំផុតនោះ តើនៅពេលណាដែលលោកបានឮពាក្យថា “ក្រុមក្តៅ ក្រុមត្រជាក់ និងក្រុមអង្កៀម” តើលោកបានប្រើ

ពាក្យហ្នឹងដោយខ្លួនឯងទេ កាលលោកនៅស-២១ នោះ?

[១០:២០:៤៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនឆ្លើយនឹងសំណួរនេះទេ។ ឲ្យចម្លងទៅត្រង់នេះ ឲ្យចម្លងទៅត្រង់នោះ។ បញ្ហាអស់នេះ ខ្ញុំជម្រាបថាវាវិវឌ្ឍន៍ក្រោយពីសភាពការណ៍កើតមក ៣០ឆ្នាំ។ មើល! ពី៧៥ រហូតមកដល់ ២០០៧។ ឯកសារនេះ ដូចជា ២០០៧។ ប៉ុន្មានឆ្នាំលោកគិតមើល? ៣២ឆ្នាំ ដូច្នេះខ្ញុំវង្វេង។ នៅពេលសហចៅក្រមលោកសួរ ខ្ញុំឆ្លើយអ៊ីចេះ ដល់ក្រោយមកឃើញឯកសារនេះ ខ្ញុំនឹកទៅដល់រឿងចាស់។ ដូច្នេះលោកមកសួរឲ្យចដើម្បីបង្ហាញសាធារណជន និងតុលាការថាខ្ញុំមិនស្មោះត្រង់នឹងខ្លួនឯង ឬយ៉ាងម៉េច? ដូច្នេះ សូមលោកកុំសួរពាក្យហ្នឹងទៀត ខ្ញុំសូមប្តឹងតុលាការ។ ខ្ញុំសូមលោកកុំសួរពាក្យហ្នឹងទៀត ពាក្យហ្នឹង មិនសប្បុរសទេ។ លោកមានបំណង នែ៎! ទុច្ចរិតចំពោះខ្ញុំ។

[១០:២១:៥៣]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធានសូមលោកមេត្តាណែនាំសាក្សីឲ្យឆ្លើយនឹងសំណួររបស់ខ្ញុំបាទ។

[១០:២២:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២២:៤០]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ យើងបានប្រាប់អំពីកាតព្វកិច្ចរបស់សាក្សីហើយ ថាសាក្សីត្រូវតែឆ្លើយតបទៅនឹងសំណួរដែលភាគីពាក់ព័ន្ធបានសួរ ទៅនឹងអ្វីដែលសាក្សីបានឃើញ បានដឹង បានឮ មានបទពិសោធន៍ផ្ទាល់ផ្ទួនកាត់ ឬបានកត់សម្គាល់នូវបញ្ហា នូវព្រឹត្តិហេតុ ឬអង្គហេតុទាំងឡាយណា ដែលពាក់ព័ន្ធនឹងសំណួរ។ ដូច្នេះ សាក្សីត្រូវអនុវត្តកាតព្វកិច្ចក្នុងនាមជាសាក្សីត្រូវឆ្លើយតប លើកលែងតែបញ្ហាដែលជំទាស់មិនឆ្លើយតបនុ៎ងគឺ នាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង ចំពោះអង្គហេតុទាំងឡាយណាដែលតុលាការមិនទាន់បានវិនិច្ឆ័យសេចក្តីជាស្ថាពរ ដូចជាអង្គហេតុដែលកើតមានឡើងនៅ ម-១៣ ជាដើម។

[១០:២៣:៤៦]

ក្រៅពីនោះ គឺមានបញ្ហាផ្សេងទៀតដែលអាចមិនឆ្លើយបាន គឺដោយសារអង្គជំនុំសម្រេចដោយ

ឆន្ទានុសិទ្ធិថា មិនឲ្យឆ្លើយតបនឹងសំណួរដោយអង្គជំនុំជម្រះយល់ច្បាស់ថា សំណួរនោះ គឺជាសំណួរច្រំដែល សំណួរនាំមុខ សំណួរឧបមានវិធី សំណួរក្រៅអង្គហេតុជាដើម ដែលវានាំឲ្យអូសបន្លាយពេលវេលានៅក្នុងកិច្ចដំណើរការសវនាការ ហើយវាគ្មានប្រយោជន៍អ្វីឈានទៅដល់ការអង្គជំនុំជម្រះយកមកពិចារណាដើម្បីថ្លឹងថ្លែង ស្វែងរកការពិតនៅក្នុងរឿងក្តីនេះ។ ដូច្នេះចំពោះសំណួរនេះគឺមានការពាក់ព័ន្ធ។ ដូច្នេះសាក្សីត្រូវឆ្លើយតបនឹងសំណួរនេះ តាមលទ្ធភាពដែលសាក្សីបានដឹង បានឃើញ បានជួបប្រទះ។ ហើយបញ្ហានេះ គឺអង្គជំនុំជម្រះបានជម្រាបពីម្សិលមិញហើយ ថាឆ្លើយតបទៅនឹងអ្វីដែលបានប្រាប់នេះ គឺប្រសិនបើអត់ដឹង អត់ឃើញ អត់ឮទេ គឺសាក្សីមានបទពិសោធន៍ក្នុងការឆ្លើយរួចហើយថា មិនដឹងទេ។ មិនបានឃើញទេ។ អី៎ៗអ៊ីចឹង។ អានោះជារឿងផ្សេងទៀត ដែលមានការពាក់ព័ន្ធទៅនឹងកាតព្វកិច្ចក្នុងការផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះ បញ្ហានេះសូមសាក្សីផ្តល់នូវគំនិតបញ្ញា ដើម្បីឆ្លើយតបទៅនឹងសំណួរដែលបានសួរនេះ។

[១០:២៥:២៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន។ បើតាមខ្ញុំចាំមេធាវីរូបនេះសួរខ្ញុំថា ម៉េចបានលោកនិយាយអ៊ីចឹង?

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឱុច សូមអនុញ្ញាត ខ្ញុំរំឭកសំណួរឡើងវិញជូនលោក។ ខ្ញុំសួរថា តើលោកបានឮពាក្យថា "ក្រុមក្តៅ ក្រុមត្រជាក់ ក្រុមអង្កៀម" ពីដំបូងបំផុតហ្នឹងនៅពេលណា? ឬក៏លោកខ្លួនឯងជាអ្នកប្រើពាក្យទាំងអស់នោះ ដើម្បីអនុវត្តនូវវិធីសាស្ត្រធ្វើទារុណកម្មនៅស-២១?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ពាក្យនេះជាពាក្យដំបូងដែលចៅក្រមស៊ើបអង្កេតសួរខ្ញុំ។ ពេលនុ៎ងវាក្រោយព្រឹត្តិការណ៍វា៣៥ឆ្នាំរួចមកហើយ។ ហើយនិយាយឲ្យត្រង់ខ្ញុំព្យាយាមបំភ្លេចភាពល្ងីងល្ងរចត់ដែលខ្ញុំបានប្រព្រឹត្តនោះដែរ នៅពេលដែលឮដំបូងខ្ញុំនឹកឃើញថា អ៊ូ!ពាក្យហ្នឹងដូចចេញពីកុន រិទ្ធី ប៉ាន់ នៅពេលដែលបញ្ចាំងពីរឿងសាក្សីម្នាក់ដែលជាកម្មាភិបាលសួរចម្លើយចាស់របស់ខ្ញុំឈ្មោះ ប្រាក់ ខន។ ខ្ញុំថា អ៊ើ្ហ! ឮតែក្នុងរឿងកុន រិទ្ធី ប៉ាន់។ ដល់ក្រោយមក សហចៅក្រមស៊ើបអង្កេត ផ្តល់ឯកសារមកដល់ខ្ញុំទៀត បានខ្ញុំដឹងថា អ៊ូ! ពាក្យហ្នឹងខ្ញុំបង្រៀនមែន។ មិនមែនត្រឹមតែនេះទេ ខ្ញុំបង្រៀន។ ដូច្នេះ ហេតុម៉េចបានជាខ្ញុំឆ្លើយអ៊ីចឹង វារឿងវាភ្លេច។ ក៏ប៉ុន្តែដល់ក្រោយមក

ឯកសារវាមាន រឿងវានឹកឃើញឡើងវិញទាំងអស់។ ដូច្នេះ រឿងអស់នេះ វាច្បាស់លាស់អស់ទៅហើយ ខ្ញុំអត់គិតពីសភាពការណ៍ជាក់ស្តែងទេ។ ខ្ញុំសូមអត្ថាធិប្បាយវែងប៉ុណ្ណឹង។

[១០:២៧:៥០]

**ស៖** ឌុច ខ្ញុំសួរទៅលោកនោះ គឺថាដែលលោកថា សួរថាហេតុអ្វីបានជាលោកកុហកតុលាការ- - កុហកចៅក្រមស៊ើបអង្កេតបែបនេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី-- លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

មិនច្បាស់ពីសំណួរសោះថា តើការកុហកហ្នឹង គឺតើមេធាវីចង់សំដៅយកការកុហកបែបណា នៅក្នុងចម្លើយនោះ គាត់ឆ្លើយក្នុងកំណត់ហេតុថា នៅពេលនោះគាត់មិនបានដឹងទេ ក្រោយមកទើបបាន គាត់បានដឹង ប៉ុន្តែមិនច្បាស់ទេថា ពាក្យកុហកនោះមេធាវីយោងថាសាក្សីកុហកនោះ ពាក្យណាមួយ កន្លែងណា? ថាតើនៅក្នុងឯកសារណាមួយ? អ៊ីចឹងសូមឲ្យមេធាវីបញ្ជាក់ផងបាទ។

**លោក ម៉ៃខល ផេសមិន៖**

ឆ្លើយតបទៅសង្ខេប។ គាត់បានទទួលស្គាល់ថា គាត់បានបង្រៀនបុគ្គលិកនៅស-២១ អំពីវិធីសាស្ត្រនៃការសួរចម្លើយទាំងអស់នេះ។

**លោក វីល្លៀម ស្មីត៖**

គាត់បានទទួលស្គាល់ថា គាត់បានបង្រៀនវិធីសាស្ត្រអំពីការសួរចម្លើយមែន ប៉ុន្តែគាត់មិនបាន បញ្ជាក់អំពីវិធី ឬក៏ក្រុមមួយៗនោះទេ ដែលថាពាក្យហ្នឹងជាលក្ខណៈបច្ចេកទេស ហើយគាត់បាន បង្រៀនអំពីវិធីសាស្ត្រសួរចម្លើយ គាត់បានឆ្លើយ។ ប៉ុន្តែអាពាក្យដែលគេប្រើក្នុងក្រុមហ្នឹង គាត់មិនបាន បញ្ជាក់ទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី កាណាវាស!

[១០:២៨:៤៤]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម លោកប្រធាន ហើយនិងភាគីទាំងអស់ សាធារណជន

ផងដែរ។ ខ្ញុំមិនដឹងមូលហេតុអីបានសហព្រះរាជអាជ្ញាជំទាស់នឹងប្រព័ន្ធនេះទេ ពីព្រោះនៅក្នុងប្រព័ន្ធអង់គ្លូសាក់សុង គឺថាមេធាវីមានសិទ្ធិក្នុងការសួរសាក្សី។ ឥឡូវនេះគាត់សួរសាក្សី ដើម្បីបង្ហាញថាតើសាក្សីនេះស្មោះត្រង់ ឬមិនស្មោះត្រង់ ដោយផ្អែកលើព័ត៌មានដែលគាត់បានទទួល ហើយនិងផ្អែកលើសំណួរដែលគាត់នឹងសួរទៅសាក្សីនេះនៅពេលក្រោយ។ ដូច្នេះ វាដូចជាឆាប់ពេកក្នុងការសហព្រះរាជអាជ្ញាជំទាស់ ដើម្បីជំទាស់ការពារសាក្សី ហើយរំខានលទ្ធភាពរបស់មេធាវីការពារក្នុងការសួរសំណួរទៅសាក្សី។

ខ្ញុំសូមឲ្យតុលាការសម្រេច ថាតើសាក្សីនេះផ្តល់ព័ត៌មានដោយសុចរិត ឬមិនសុចរិតនៅពេលក្រោយ។ ប៉ុន្តែផលប្រយោជន៍នៃការជំទាស់សំណួរបែបនេះគឺថា មិនៗសមស្របទេ ដោយថា លោកផេសមិនគាត់បានសួរទៅតាមលំដាប់លំដោយ។ មូលហេតុដែលខ្ញុំជំទាស់នោះ គឺថាខ្ញុំមិនចង់ប្រឈមមុខនឹងស្ថានភាព ឬក៏ការជំទាស់ដូចគ្នានេះ នៅផ្លូវ-- តាមផ្លូវទៅមុខចំពោះសាក្សីរូបនេះទេ។

[១០:៣១:០៣]

ហើយខ្ញុំនឹងប្រឈមមុខនឹងសាក្សីនៅតាមវិធីបែបនេះទេ។ ប៉ុន្តែខ្ញុំនឹងមានវិធីផ្សេង ប៉ុន្តែខ្ញុំ-- យើងសូមជម្រាបតុលាការថា សាក្សីត្រូវតែបង្ហាញការពិត ពិតប្រាកដ ឬក៏កុហកនោះ អាហ្នឹងគឺជាវិធីសាស្ត្ររបស់ភាគីនីមួយៗនឹងត្រូវដេញទេ។

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំសូមឆ្លើយដោយសង្ខេប។ សហព្រះរាជអាជ្ញាមិនបានការពារសាក្សីនោះទេ។ សហព្រះរាជអាជ្ញាគ្រាន់តែធ្វើឲ្យច្បាស់ថា សំណួរដែលសួរដោយមេធាវីការពារនោះ គឺមិនមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ ហើយៗមេធាវីការពារលោកអៀង សារី មិនបានស្តាប់ត្រឹមត្រូវទេ។ ពីព្រោះថា សាក្សីឆ្លើយថាគាត់បានបង្រៀន ប៉ុន្តែវិធីសាស្ត្រដែលគេប្រើនោះគឺថា គាត់មិនបានចាំទេ។ ពីព្រោះវារយៈកាលយូរ។ ដូច្នេះ សូមតុលាការពិចារណាចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

ប្រហែលជាខ្ញុំតាំងសំណួរម្តងទៀត ដើម្បីបញ្ជាក់ចំណុចនេះ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច នៅពេលដែលលោកធ្វើការនៅ ស-២១ តើលោកធ្លាប់ឮពាក្យ "ក្រុមក្តៅ ក្រុមត្រជាក់ និងក្រុមអង្កៀម" ដែរឬទេ?

[១០:៣២:៤២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឆ្នាំនេះ២០១២ ក្រោយឆ្នាំ២០០៧ ប្រាំឆ្នាំហើយ ដូច្នេះរឿងដែលខ្ញុំភ្លេច៣០ឆ្នាំ វារំឭកឡើងក្នុងរយៈកាលសួរចម្លើយនេះ។ ហើយជាពិសេសរយៈកាលដោយឃើញឯកសារអំមិញ។ ហើយស្រាប់តែលោកមេធាវីមកយកសំណួរពីឆ្នាំ២០០៥ មកសួរខ្ញុំពេលនេះ ឱ្យខ្ញុំឆ្លើយយ៉ាងម៉េច? ការយល់ដឹងរបស់ខ្ញុំ ការចងចាំរបស់ខ្ញុំវាទៅផ្សេង។ រួចឱ្យខ្ញុំឆ្លើយយ៉ាងម៉េច? ខ្ញុំមិនចេះឆ្លើយទេសំណួរបែបនេះ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមិនដឹងថា តើលោកប្រធានគួរសម្រេចឈប់សម្រាកសិន សឹមសួរបន្តក្រោយពីឈប់សម្រាក ព្រោះដល់ម៉ោងហើយ។

[១០:៣៣:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនៅស្តាប់ការជជែកតវ៉ាគ្នាឱ្យវាច្បាស់លាស់ ចៀសវាងបញ្ហាដែលហ្នឹងចូលមកសម្រេចហើយ លើកបញ្ហាដដែលទៀត។ ដល់ពេលចុងម៉ោង ដល់ពេលអស់ពេល សុំបន្ថែមពេល។ អ៊ីចឹងហើយបង្អង់បន្តិច ក្រែងលោអា-តជំទាស់ជាមួយនឹងព្រះរាជអាជ្ញាជាមួយអីហ្នឹងឱ្យវាអស់ចិត្តមើល៍ តើវាត្រូវប្រើពេលប៉ុន្មាន ដើម្បីឱ្យការជំទាស់តវ៉ាហ្នឹងអង្គជំនុំជម្រះមកសម្រេចឱ្យវាទៅមុខ។ ហើយចៀសវាងកុំដល់ពេលតវ៉ាចុះឡើង ដល់ពេលអស់ម៉ោងសុំបន្ថែមម៉ោង។ ពីព្រោះអង្គជំនុំជម្រះកត់សម្គាល់ឃើញអ៊ីចឹង។ ទំនងជាលែងបន្ថែមទៀតហើយ ដើម្បីសន្សំពេលវេលា ដំណើរការក្តីនេះឱ្យបានឆាប់រហ័ស និងយុត្តិធម៌នោះ ដែលជាធាតុនៃយុត្តិធម៌នេះគឺមានការឆាប់រហ័សផងដែរ។

[១០:៣៤:៥១]

បើមិនមានការជំទាស់ចុះឡើងលើការតបតរបស់សហព្រះរាជអាជ្ញាទេ អង្គជំនុំជម្រះសម្រេចថាសម្រាកត្រឹមប៉ុណ្ណោះ ២០នាទី រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ

សវនាការ។ អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់មួយ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្ដម៖**

សូមអរគុណ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅថ្ងៃពេញតែម្ដង តែសូមចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម ដោយសារមូលហេតុសុខភាព ជាពិសេសបញ្ហាឈឺខ្នង ចង្កេះ និងជើង។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

[១០:៣៦:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់តាមដានកិច្ចដំណើរការសវនាការ នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ផ្ដល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក អៀង សារី និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់កិច្ចដំណើរការសវនាការចាប់ពីពេលនេះទៅ រហូតដល់រសៀល ចប់រសៀលនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោម

ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៧ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០០:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តនេះ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក ឌុច តើអ្នកណាជា ប្រាក់ ខន? បាទ ប្រាក់ ខន គាត់ធ្វើអ្វី?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ប្រាក់ ខន ជាអ្នកសួរចម្លើយម្នាក់។

**ស៖** នៅក្នុងឆ្នាំ២០០៧ លោកបានជម្រាបអ្នកបក--អ៎!អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា លោកបានសួរចម្លើយដោយផ្ទាល់នៅ-- អ្នកទោសបរទេសទាំងបួននាក់។ ក្នុងចំណោមនោះលោកសម្លាស-- សួរចម្លើយម្នាក់ ហើយលោកបានទាត់អ្នកទោសនោះដោយផ្ទាល់ខ្លួននៅស-២១ នៅពេលដែលលោកសួរចម្លើយនោះ។ តើលោកនៅចាំហេតុការណ៍នោះទេ?

**លោក វីល្លៀម ស្មីត៖**

នៅក្នុងការបកប្រែនោះ គឺថាមេធាវីការពារយកចម្លើយរបស់សាក្សីមួយផ្សេងទៀត មកឲ្យសាក្សីរូបនេះគាត់បញ្ជាក់។ ដូច្នេះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះគឺថា លក្ខណៈពិសេសនៃចម្លើយនោះ

ក៏មិនគប្បីសួរទេ ប៉ុន្តែអាចសួរបានពីលក្ខណៈទូទៅ។ ហើយសាក្សីរូបនេះ គឺមិនត្រូវឲ្យគាត់ថ្លឹងថ្លែងភាពត្រឹមត្រូវ ឬភាពជឿជាក់បានរបស់សាក្សីផ្សេងនោះទេ។ ខ្ញុំសូមជម្រាបតុលាការថា វិធាននោះគឺបែបនេះហើយ បើសិនបើៗសួរគាត់ថា តើគាត់បានធ្វើទារុណកម្មអ្នកជាប់ឃុំនោះដែរឬអត់? ហ្នឹងជាសំណួរមួយដែលថាអង្គជំនុំជម្រះបានសម្រេចហើយថា មិនគប្បីតាំងសំណួរជាក់លាក់ទៅរកខ្លឹមសារនោះទេ លើកលែងតែសួរជាសំណួរទូទៅវិញ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតជម្រាបតុលាការថា នេះជាចម្លើយរបស់សាក្សីមួយ ដែលសាក្សីរូបនេះបានដឹងហើយចម្លើយនោះក៏នៅក្នុងសំណុំរឿងដែរ។ ខ្ញុំរីករាយនឹងសួរឡើងវិញនូវសំណួរដែលខុសពីខាងដើម ប៉ុន្តែខ្ញុំនៅតែជឿជាក់ថា ខ្ញុំមានសិទ្ធិដើម្បីនឹង *ខន់ហ្វ្រន់ត៍* បានន័យថាតទល់ជាមួយសាក្សីនេះ ដោយប្រើចម្លើយរបស់សាក្សីផ្សេងទៀត ដែលថាចម្លើយនោះវាផ្ទុយពីអ្វីដែលសាក្សីនេះឆ្លើយបាទ។

[១១:០៤:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៥:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីការពារក្តីយកចម្លើយសាក្សីផ្សេងយកមក ដកស្រង់យកមកសួរដេញដោលចំពោះសាក្សីមួយផ្សេងទៀតទេ។ ហើយមេធាវីអាចចោទសំណួរជាទូទៅដោយផ្អែកលើខ្លឹមសារដែលខ្លួនបានយល់ដឹង ដោយការអាន ការមើលឯកសារនោះបាន។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច នៅពេលដែលលោកនៅស-២១ តើលោកបានសួរចម្លើយអ្នកទោសប្អូននាក់ ម្នាក់ក្នុងចំណោមអ្នកទោសបរទេសបួននាក់ដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនសួរចម្លើយទេ ខ្ញុំបានទៅមើល តើអ្នកបកប្រែហ្នឹងចេះអង់គ្លេសល្មមប្រើការបានឬអត់។ រឿងលម្អិតខ្ញុំបានរាយការណ៍ជូនតុលាការនៅពេលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរខ្ញុំម្សិលមិញហើយ។ ដូច្នេះខ្ញុំមិនទៅសួរទេ តែខ្ញុំទៅមើលសមត្ថភាពរបស់អ្នកបកប្រែ។

[១១:០៧:០៦]

**ស៖** តើលោកបាន១ទាត់អ្នកទោសម្នាក់ដែលក្នុងចំណោមបួននាក់ហ្នឹងដែរឬទេ? អ្នកទោសបរទេសនៅស-២១។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំគ្មានរឿងរ៉ាវអីសួរចម្លើយអ្នកផ្សេងទៀតទេ។ ក្រៅពី កុយធួន ម្នាក់ ដែលមេបញ្ជាដាច់ណាត់មកឲ្យខ្ញុំសួរ។ ដូច្នេះ ខ្ញុំគ្មានរឿងរ៉ាវអីទៅទាត់អ្នកទោសការងារខ្ញុំមួយគរគោក។

**ស៖** តើលោកចាំឬទេថា លោកបានសួរចម្លើយ ហើយនិងធ្វើទារុណកម្មអ្នកទោសស្រីម្នាក់នៅក្នុងស-២១ ដោយប្រើវិធីឆក់ខ្សែភ្លើង?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រឿងនេះអត់មានកើតនៅស-២១ ទេ។ ខ្ញុំមិនដែលទៅសួរចម្លើយអ្នកណាទេ ខ្ញុំសូមបញ្ជាក់ម្តងទៀត។

[១១:០៨:៣៣]

**លោក ម៉ៃខល ផេសមិន៖**

លោកចៅក្រម នៅចំណុចនេះខ្ញុំសូមរំឭកការចងចាំសាក្សីរូបនេះ ដោយដកស្រង់ខ្លឹមសារមួយផ្នែកនៃចម្លើយ ដែល១ ប្រាក់ ខន គាត់បានឆ្លើយ នៅក្នុងរឿងក្តីរបស់សាក្សីរូបនេះ ហើយខ្ញុំសូមបន្ថែមថា ហើយសាក្សីរូបនេះគឺមិនស្ថិតនៅក្នុងបញ្ជីសាក្សីទេ។ ដូច្នេះយើងមិនអាចសួរ ប្រាក់ ខន នៅលើបញ្ហានេះទេ។ អ៊ីចឹងហើយខ្ញុំសូមអនុញ្ញាតស្រង់ ហើយសូមរំឭកការចងចាំរបស់សាក្សី ដើម្បីឲ្យគាត់អាចឆ្លើយបានបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាត អង្គជំនុំជម្រះបានសម្រេចរួចហើយបញ្ហានេះ។ ហើយយើងព្យាយាមការចងចាំរបស់លោក គឺចាំជារហូតនូវអ្វីដែលយើងបានសម្រេចបែបនេះរួចហើយ។

[១១:០៩:៣១]

**លោក ម៉ៃខល ផេសមិន៖**

ប៉ុន្តែខ្ញុំយល់ថា ការសម្រេចនោះគឺថាយើងអាចសួរសាក្សីនោះ ប្រសិនបើកោះសាក្សីរូបនោះមកបំភ្លឺ។ ប៉ុន្តែយើងមិន គឺថាសាក្សីរូបនោះមិនមកបំភ្លឺទេ ដូច្នេះហើយខ្ញុំនឹងប្រើចម្លើយរបស់គាត់។ បើមិនខ្ញុំមិនប្រើនៅលើកំណត់ហេតុទេ ខ្ញុំមិនសួរសាក្សីនេះបានទេ។ នេះគឺជាចម្លើយរបស់សាក្សីនោះនៅក្នុង

សំណុំរឿង ហើយៗសាក្សីរូបនេះក៏ដឹងអំពីចម្លើយសាក្សីម្នាក់ទៀតនោះដែរ។ បើសិនជាតុលាការមិនអនុញ្ញាតឲ្យខ្ញុំប្រើឯកសារនេះដើម្បីប្រឈមតទល់មួយនឹងសាក្សីរូបនេះថា តើខ្ញុំអាចនឹងបញ្ជាក់ការពិតមិនពិតដែលគាត់ឆ្លើយនោះដូចម្ដេច? ដោយសារថា យើងខ្ញុំមានឱកាសដើម្បីនឹងជំទាស់តទល់ទៅនឹងសាក្សីរូបនេះអំពីភាពពិតប្រាកដ ឬក៏ការពិតនៅក្នុងចម្លើយរបស់គាត់ប្រៀបធៀបនឹងចម្លើយរបស់អ្នកផ្សេង។ ដូច្នេះសូមតុលាការពិចារណា។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សម្រេចរួចហើយៗ យើងមិនសម្រេចផ្សេងពីនេះទេ។

សូមអញ្ជើញលោកមេធាវី-- អ៎ លោកតំណាង-- លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:១០:៤៦]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ សហព្រះរាជអាជ្ញាជឿជាក់ថា វាមានសារៈសំខាន់ហើយដែលមេធាវីការពារអាចតាំងសំណួរបាន។ ប៉ុន្តែនៅក្នុងសេចក្ដីលម្អិតចំណុចជាក់លាក់ពិសេសពិស្ដារនៅក្នុងចម្លើយសាក្សីផ្សេងទៀត គប្បីតែឲ្យសាក្សីរូបនេះអាចសម្ដែងអំពីបញ្ហាមួយ ប៉ុន្តែបើឲ្យសាក្សីរូបនេះទៅបង្ហាញថា ជឿជាក់បាន មិនជឿជាក់បាន លើចម្លើយរបស់អ្នកផ្សេងនោះ អាហ្នឹងគឺរឿង-- ជាបញ្ហាមិនត្រឹមត្រូវ។ ប៉ុន្តែបើយើងយកខ្លឹមសារមកឲ្យសាក្សីពិចារណាឲ្យគាត់ឆ្លើយ អង្គជំនុំជម្រះទេ ជាអ្នកពិចារណាពីភាពថ្លឹងថ្លែង ពីតម្លៃនៃភស្តុតាងទាំងអស់នោះ។ ប៉ុន្តែ សាក្សីរូបនេះមិនគប្បីឲ្យសាក្សីរូបនេះទៅធ្វើការសម្រេច ឬក៏វាយតម្លៃចម្លើយរបស់សាក្សីផ្សេងៗទៀត ប្រឆាំងនឹងចម្លើយរបស់គាត់នោះទេ។

[១១:១១:៤៧]

ហើយសំណួរគឺអាចសួរ គឺសួរយកតែខ្លឹមសារតែប៉ុណ្ណោះ បើមិនដូច្នោះទេគឺអាចនឹងក្លាយទៅជាការប្រឆាំងគ្នា ខ្វែងគំនិតគ្នា ជាបុគ្គលនិងបុគ្គល រវាងសាក្សីនិងមេធាវីការពារទៅហើយ។ ដូច្នេះហើយដើម្បីកុំឲ្យមានស្ថានភាពបែបនេះនៅក្នុងតុលាការនេះជាមតិរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[១១:១២:១៧]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឯកភាពមួយផ្នែកទៅលើមតិរបស់សហព្រះរាជអាជ្ញា នៅក្នុងករណីនេះសាក្សីត្រូវផ្ដល់ចម្លើយទៅមេធាវីការពារ ហើយផ្អែកទៅលើខ្លឹមសាររបស់ចម្លើយរបស់គាត់ដើម្បីបង្ហាញពីមូលដ្ឋានដែលថា តើបុគ្គលផ្សេងដែលត្រូវនឹងបង្ហាញ បញ្ជាក់ ដើម្បីប្រៀបធៀបដែរឬទេ? សហព្រះរាជអាជ្ញាឆ្លើយបញ្ជាក់ថា ត្រូវហើយ គឺថាមួយផ្នែកគាត់ប្រកាន់ជំហរពីដើមរបស់គាត់។ សាក្សីមិនអាចនឹងត្រូវបានប្រឈមជំទាស់ដោយសាក្សីផ្សេងគេអះអាងនោះទេ អ្វីដែលគាត់សង្កេតនោះ។ គឺអាស្រ័យលើសាក្សីរូបនេះទេ ក្នុងការសម្រេច ដើម្បីឆ្លើយសំណួរថាបដិសេធ ឬក៏យល់ស្រប។ ហើយមិនមានអ្វីអាចរារាំងភាគីណាមួយថាមិនឲ្យបញ្ជាក់អ្វី មិនឲ្យសួរអ្វីនោះទេនៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតសួរគាត់នូវចម្លើយបែបនេះ បែបនោះគឺ-- បើធ្វើបែបនោះ គឺថាដូចជាចាក់សោ ឌុចមិនឲ្យនិយាយ។ ហើយគឺថា ឌុច គាត់បាននិយាយ គាត់ថា មិនបានធ្វើទារុណកម្មទេ ប៉ុន្តែសាក្សីផ្សេងថាមែន ឌុច បានធ្វើអ្វី បានទារុណកម្ម។ ឧទាហរណ៍៖ ឌុច និយាយថាមិនមានបុគ្គលណាមួយទេដែលធ្វើការនៅស-២១។ ដូច្នេះហើយគឺមិនមានអ្វីដែលរារាំងមិនឲ្យភាគីណាមួយសួរទៅសាក្សីថាតើថាខ្លឹមសាររបស់ចម្លើយនោះត្រឹមត្រូវ ឬមិនត្រឹមត្រូវទេ។ គាត់អាចឆ្លើយថា ត្រឹមត្រូវ មិនត្រឹមត្រូវ គាត់អាចបដិសេធ។ នេះហើយជាវិធីសាស្ត្រដែលចៅក្រម-- សហចៅក្រមស៊ើបអង្កេតប្រើនៅក្នុងអំឡុងកិច្ចស៊ើបសួររបស់ពួកគាត់។

[១១:១៤:០៧]

នេះហើយគឺជាការជំទាស់តទល់ជាគំរូខ្នាតតាំងពីយូរយារមកហើយ ដែលតុលាការប្រើ។ ដូច្នេះនេះគឺជាគំរូត្រឹមត្រូវ។ សូមអរគុណតុលាការ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ គឺបែបនេះឯង។ អំមិញគាត់សុំដកស្រង់យកខ្លឹមសារនៃឯកសារចម្លើយរបស់សាក្សីដទៃយកមកសួរ។ អង្គជំនុំជម្រះបានសម្រេចហើយថា មិនអាចធ្វើដូច្នេះបានទេ ដោយយកខ្លឹមសារទូទៅដែលខ្លួនបានអាន បានមើល បានយល់ដឹង ឯកសារនុ៎ងដែលខ្លួនគិតថាមានផលប្រយោជន៍សម្រាប់ខ្លួនឯង អាចរៀបចំតាំងសំណួរទូទៅចំពោះសាក្សីពាក់ព័ន្ធនឹងបញ្ហាដែលខ្លួនយល់ថាចាំបាច់។ ដូចជាគ្រប់គ្រាន់ហើយ។

[១១:១៥:០៧]

**លោក ម៉ៃខល ផេសមិន៖**

ប្រហែលជាដើម្បីការពារណែនាំសម្រាប់រូបខ្ញុំ ថាតើវិធាននេះអនុវត្តគ្រប់សាក្សីទាំងអស់ដែរឬទេ? ឬក៏ចំពោះតែសាក្សី ឌុច នេះ? ថាតើទាល់តែសាក្សីណាដែលយល់ដឹង ឬក៏ដឹងរឿងហេតុរបស់សាក្សីផ្សេងៗទៀត។ អ៊ីចឹង ខ្ញុំគ្រាន់តែចង់បានការណែនាំពីតុលាការដែរ។ ថាតើការសម្រេចនេះអនុវត្តចំពោះសាក្សីទាំងអស់តទៅទៀតដែរឬទេ?

[១១:១៥:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២០:៣៦]

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្កេកអ៊ាវ តាមសំណួរដែលប៉ុនប៉ងសួរដោយមេធាវីការពារក្តីអម្បាញ់មិញនេះ គឺសួរថា នៅក្នុងអំឡុងពេលនៃការដំណើរការដែលខ្លួនលោកជាប្រធានមន្ទីស-២១ហ្នឹង តើលោកដែលមានធ្វើទារុណកម្មចំពោះអ្នកទោសនៅក្នុងមន្ទីរស-២១ ដែរឬទេ? ពីព្រោះគាត់ គេ បង្អែកថាមានសាក្សីម្នាក់ដែលបានឆ្លើយកន្លងមកនេះថា លោកធ្លាប់បានធ្វើទារុណកម្មចំពោះអ្នកទោសនៅក្នុងមន្ទីរស-២១។

**លោក កាំង ហ្កេកអ៊ាវ៖**

អរគុណលោកប្រធាន។ ខ្ញុំបានឆ្លើយជម្រាបតុលាការរួចមកហើយ ថាខ្ញុំនៅក្នុងមន្ទីរស-២១ សួរចម្លើយតែមនុស្សម្នាក់គត់ គឺ កុយ ធួន។ ដោយឡែក ពេលដែលខ្ញុំដើរជាមួយ ណាត។ ខ្ញុំឃើញ ឈិត អ៊ីវ រកប្រតិកម្មដាក់ ម៉ា ម៉េងឃាង ហៅ ម៉ុន ពេលនោះខ្ញុំដើរជាមួយ ណាត។ គាត់រកវ៉ៃខ្លាំង ប៉ុន្តែខ្ញុំមិនទុកឲ្យគាត់វ៉ៃទេ ព្រោះគាត់ប្រធានអង្គាល់នុំង ហ្នឹងខ្ញុំសុខចិត្តសម្លុតៗ ឈិត អ៊ីវ មួយម៉ាត់ពីរហើយខ្ញុំចេះកម្ទេច គោះបន្តិចទៅ ដូច្នេះមានតែប៉ុននុង៎ឯងទេ។ ខ្ញុំគ្មានបានពេលទៅសួរអ្នកណាទេ។ ការងារខ្ញុំផ្សេង រវល់មួយថ្ងៃៗហ្នឹងអាមើលឯកសារចម្លើយសារភាពនុំង។ ដូច្នេះ អត់បានសួរអីណា។ ដូច្នេះរឿងទាំងអស់ដែលនិយាយនេះ ដែលសាក្សីផ្សេងនិយាយនេះ ខ្ញុំមិនយល់ អ៎!មិនជឿថាកើតមាន។ ខ្ញុំផ្ទាល់ខ្លួនខ្ញុំអត់បានធ្វើទេ។

[១១:២២:៣៤]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី នួន ជា អាចមានសំណួរអីផ្សេងទៀត?

**លោក ម៉ែខល ផេសមិន៖**

ខ្ញុំមានវិប្បដិសារី ដោយសារខ្ញុំមិនអាចបន្តសួរបែបនេះតទៅទៀត ហើយក៏វាមានសារៈសំខាន់ក្នុងការលាតត្រដាងនូវការពិតនោះផងដែរ។ ដូច្នេះ ខ្ញុំសូមឆ្លងចូលទៅប្រធានបទមួយផ្សេងទៀត។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ឌុច លោកបានបញ្ជាក់ជាញឹកញាប់ថា កុយ ធួន មានតែ កុយ ធួន ម្នាក់ទេដែលលោកបានសួរចម្លើយ។ តើត្រូវដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ត្រឹមត្រូវ។

**ស៖** នៅថ្ងៃទី០៩ មិថុនា ឆ្នាំ១៩៩៩ លោកបានជម្រាបតុលាការយោធាអន្តរជាតិ អ៊ំ! តុលាការយោធាកម្ពុជាថា នូវខ្លឹមសារមួយចំនួន។

**លោក ម៉ែខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញជូនតុលាការ មួយទំព័រ ចេញពីចម្លើយរបស់លោកនៅពេលនោះ។ បាទសូមអនុញ្ញាតអង្គជំនុំជម្រះដើម្បីបង្ហាញ។

**ប្រធានអង្គជំនុំ៖**

ឯកសារហ្នឹង ជាឯកសារនៅក្នុងសំណុំរឿងក្តី០០២? ហើយអត្តសញ្ញាណឯកសារហ្នឹងយ៉ាងម៉េចទៅ? លេខប៉ុន្មាន?

[១១:២៤:១៨]

**លោក ម៉ែខល ផេសមិន៖**

សូមអភ័យទោស D288/6.52/4.25, ERN អង់គ្លេស 00377326, ខ្មែរ ERN 00320787 ហើយទំព័រចុងក្រោយដែលខ្ញុំចង់បង្ហាញជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ស្វែងរកនិងបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍!

[១១:២៦:១១]

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកបានបញ្ចប់ការអានទៅលើចំណុចដែលបង្ហាញនេះហើយឬនៅបាទ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំបានមើលឃើញហើយ។

**ស៖** តើលោកចាំទេថា លោកបានឆ្លើយបែបនេះ?

**ឆ៖** អរគុណ។ ខ្ញុំបានឆ្លើយបែបនេះ។

**ស៖** សូមលោកអានប្រយោគចុងក្រោយនៅក្នុងចម្លើយដែលនៅក្នុងប្រអប់ពណ៌ក្រហម ចំពោះបុគ្គលិកដែលសួរចម្លើយ។ សូមលោកអានបន្តពីហ្នឹង ប្រយោគចុងក្រោយនៅក្នុងប្រអប់នោះ។

[១១:២៧:២៣]

**ឆ៖** អរគុណ។ ខ្ញុំសូមអាន៖ "ការសួរចម្លើយផ្ទាល់ គឺខ្ញុំរួមសួរជាមួយគេ តាមបញ្ជា សុន សេន គឺសួរ កុយ ធួន និង សៀត ឆែ"។ ហ្នឹងខ្ញុំសូមអានប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំពីការសួរចម្លើយ សៀត ឆែ ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានគិតគូរដល់រឿង សៀត ឆែ ហ្នឹងយូរហើយ ដូច្នេះខ្ញុំភ្លេចមួយរយៈដែរ។

**ស៖** ប៉ុន្តែនេះជាចម្លើយរបស់លោក។ តើចម្លើយនេះ ពិតជាត្រឹមត្រូវទេដែលថា តើលោកពិតជាបានសួរចម្លើយគាត់ដែរឬទេ?

**ឆ៖** អរគុណ។ និយាយពីរឿងជាមួយ សៀត ឆែ ខ្ញុំទៅតែមួយភ្លែតទេ ទៅពន្យល់ សៀត ឆែ តាមសំបុត្ររបស់ នែ៎! សុន សេន សរសេរមក។ បញ្ហាពេលនុ៎ង សុន សេន គាត់ចង់ឲ្យ សៀត ឆែ សារភាព។ គាត់ទាក់ទងខ្ញុំតាមទូរស័ព្ទ គាត់ថាគួរសរសេរសំបុត្រទៅឲ្យវាមួយ តើមិត្តយល់យ៉ាងម៉េច? "ខ្ញុំថា ស្រេចនឹងបងទេ។" គាត់ថា "អ្ហឺ! អីដល់សរសេរសំបុត្រដាក់ក្នុងនាមខ្ញុំ ដូចជាវាមិនត្រូវ។ ដូច្នេះខ្ញុំសរសេរសំបុត្រទៅមិត្ត ហើយមិត្តយកទៅឲ្យ ទុំ ទៅ"។ ដូច្នេះគាត់សរសេរមក "ជូនមិត្ត ឌុច ប្រាប់ទុំ ឲ្យច្បាស់" នេះខ្លឹមសារមានលក្ខណៈអ៊ីចឹង។

[១១:២៨:២៧]

"បើសិនជា ទុំ ហើយសុខចិត្តសារភាពឲ្យស្មោះត្រង់ហ្នឹង ខាងលើនឹងពិនិត្យពិចារណាអំពីការអនុគ្រោះដល់ នែ៎ ទុំ"។ នេះ សុន សេន គាត់សរសេរមកប៉ុណ្ណឹង ហើយឲ្យខ្ញុំយកទៅឲ្យ ខ្ញុំក៏នាំ មិត្តប៉ុនទៅ។ យកសំបុត្រនោះទៅប្រគល់ជូន សៀត ឆែ ហៅ ទុំ ហ្នឹង នៅកន្លែងសួរចម្លើយ។ ដូច្នេះ ខ្ញុំអត់មាននិយាយអីច្រើនទេ ជាមួយ សៀត ឆែ ហៅ ទុំ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

**ស៖** លោកបានជម្រាបតុលាការនេះថា កុយ ធួន គឺជាអ្នកទោសតែម្នាក់គត់ ដែលមិនរងអំពើទារុណកម្ម។ តើត្រឹមត្រូវឬទេ?

**ឆ៖** អរគុណ។ ត្រឹមត្រូវ។

**ស៖** នៅថ្ងៃទី៤ ទី៥ ទី៦ ខែឧសភា ឆ្នាំ១៩៩៩ គាត់-- លោកបានផ្តល់ចម្លើយ-- បទសម្ភាសន៍យ៉ាងវែងទៅឲ្យ គ្រីស្តូហ្វ័រ ប៉េស៊្វ តើលោកនៅចាំទេ?

**ឆ៖** អរគុណ។ ខ្ញុំបដិសេធ គ្រីស្តូហ្វ័រ ប៉េស៊្វ រួចទៅហើយ ហើយក៏ ខ្ញុំគិតថា ឯកសារ គ្រីស្តូហ្វ័រ ប៉េស៊្វ ដូចជាមិននៅក្នុងសំណុំរឿង។ នេះ សូមតុលាការមេត្តាវិភាគបញ្ហានេះ។

[១១:៣១:១០]

**ស៖** សូមទោសសាក្សី ខ្ញុំសូមរំខានលោកគឺថា ពីម្សិលមិញលោកបាននិយាយថា លោកបានប្រាប់ គ្រីស្តូហ្វ័រ ប៉េស៊្វ នៅការពិតដល់គាត់។ តើលោកបដិសេធចំពោះការសម្ភាស ដែលលោកបានផ្តល់ទៅឲ្យ នីក ដងឡុប ហើយនិង នេត ថាយ័រ ដែរឬទេ? ផ្នែកខ្លះនៃប្រតិចារឹក នៃចម្លើយដែលលោកផ្តល់ជូនទៅ គ្រីស្តូហ្វ័រ ប៉េស៊្វ នោះគឺថា ត្រូវបានថតជាសំឡេង ហើយក្រោយមកក៏បានវាយចេញជាអក្សរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

តើលោកអាចផ្តល់លេខឯកសារ លេខ ERN និងបង្ហាញអំពីទំព័រ ដែលចង់លើកឡើងបានទេ?

**លោក ម៉ែខល ផេសមិន៖**

ឯកសារនេះគឺ IS20.19 ERN ជាភាសាអង់គ្លេស 00185024។ ERN ជាភាសាខ្មែរ 00160904។ ហើយដើម្បីឲ្យច្បាស់លាស់មែនទែននោះ គឺមានលើកមកនិយាយនៅក្នុងលេខយោងជើងទំព័រ នៃដីកាបញ្ជូនរឿងទៅជម្រះលេខ 3--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន។ បាត់លេខ *ហ្វូតណូត* អម្បាញ់មិញ។ អ្នកបកប្រែសូមឲ្យគាត់រំឭកម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ផេសមិន ឲ្យលេខជើងទំព័រម្តងទៀត ពីព្រោះអត់មានការបកប្រែទេ។

[១១:៣៣:១៤]

**លោក ម៉ៃខល ផេសមិន៖**

3672។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ស្វែងរកឯកសារនេះ ហើយដាក់បញ្ចាំងនៅលើកញ្ចក់អេក្រង់ទូរទស្សន៍។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី នេះគឺជាប្រតិចារឹក ដែលបានវាយចេញពីខ្សែអាត់ថតសំឡេង ដែលលោកបានផ្តល់ការសម្ភាសទៅជាមួយនឹង គ្រីស្តូហ្វ័រ ប៉េស៊្វ។ សំណួររបស់ខ្ញុំគឺ សូមឲ្យលោកអានឃ្លានៅក្នុងប្រអប់ពណ៌ក្រហមនេះ។

[១១:៣៥:១១]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាចមើលស្វែងរកលេខនៅជើងទំព័រមើល៍ តើមានឯកសារនេះដូចលោកមេធាវីថាដែរទេ 3672?

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន នៅពេលដែលកំពុងពិនិត្យមើលលេខយោងជើងទំព័រ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រហែលជាលេខយោងជើងទំព័រខុសគ្នារហូតទៅដល់២០ ឯណោះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

នៅពេលដែលលោកនិយាយថានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លោកនិយាយអំពីសំណុំរឿង ០០២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២? ពីព្រោះអង្គជំនុំជម្រះមិនច្បាស់ មិនដឹងថាតើឯកសារនេះបានដាក់ចូលទៅក្នុងសំណុំរឿង០០២ ឬអត់នោះទេ។

[១១:៣៦:១៥]

**លោក ម៉ៃខល ផេសមិន៖**

លោកស្រីចៅក្រម ខ្ញុំសូមពិនិត្យមើលបន្តិចទៀតបាទ. សូមអរគុណ។

ខ្ញុំមិនដឹងថាពាក្យ *អ៊ិមផតធីត* នេះគឺថាមានន័យថាម៉េចទេ ប៉ុន្តែនេះគឺជាលេខជើងទំព័រយោងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

ចាំរកឯកសារនៅលើជើងទំព័រសិន បានទេ? រកឃើញទេ?

3672។

សូមអញ្ជើញលោកមេធាវី អាចបន្តការសួរដេញដោលបានហើយ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច លោកអាចសុំស្នើឲ្យលោកអានឃ្លានៅក្នុងប្រអប់ពណ៌ក្រហម!

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន សេចក្ដីសម្ភាសរបស់ខ្ញុំជាមួយ នីក ដងឡប ខ្ញុំបដិសេធតាំងពីដើមមក ព្រោះមិនដែលបានដាក់ឯកសារច្បាប់ដើមឲ្យតុលាការទេ។ យកឯកសារច្បាប់ចម្លង យកមកដាក់ឲ្យខ្ញុំ នេះបញ្ហាមួយ។ បញ្ហាមួយទៀត ខ្សែ អំន៉ែ ថាសដែលថតសំឡេងខ្ញុំ ខ្ញុំយកមកស្ដាប់ច្របូកច្របល់ មានបញ្ហាជាច្រើនដែលមិនទំនង។ ដូច្នេះសូម--

[១១:៣៨:២៦]

**ស៖** លោកសាក្សីខ្ញុំសូមកាត់លោក ខ្ញុំសូមឲ្យលោកអានឃ្លានៅក្នុងប្រអប់ពណ៌ក្រហម។

**ឆ៖** ខ្ញុំសូមតវ៉ាជូនតុលាការអំពីយថាភាពនៃឯកសារ ដែលលោកបង្ហាញខ្ញុំ។ ដូច្នេះមុននឹងឆ្លើយជូនលោក ខ្ញុំសូមជម្រាបតុលាការអំពីយថាភាពនៃឯកសារនេះសិន។ ក្នុងសំណុំរឿងលេខ០០១ មិនដែលបានបញ្ចូលឯកសារនេះទៅក្នុងសំណុំរឿងទេ។

**ស៖** លោកប្រធាន ខ្ញុំសូមកាត់សាក្សីម្ដងទៀត។ លោកប្រធាន ឌុច ជាសាក្សី ឌុច មិនមែនជាជនជាប់ចោទទេ។ សុំឲ្យអង្គជំនុំជម្រះមេត្តាបង្គាប់ឲ្យ ឌុច ឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ សូមអរគុណ។

[១១:៣៩:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៣:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ មុននឹងបន្តកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសូមប្រគល់វេទិការ ប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់ជូនទៅមេធាវីការពារក្ដី នួន ជា អំពីបញ្ហាឯកសារចំពោះមុខអង្គជំនុំជម្រះ-- អ៎! ដែលមេធាវីបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ឯកសារជាក់លាក់មួយនេះ គឺមេធាវីការពារក្តី គឺថាត្រូវបានយកមកប្រើប្រាស់នៅក្នុងសំណុំរឿង០០១ ក៏ប៉ុន្តែអង្គជំនុំជម្រះមិនទាន់កំណត់អំពីយថាភាពនៃឯកសារនេះទេ។ ដូច្នេះ មិនមានតម្លៃជាភស្តុតាងទេ។ លោកអាចតាំងសំណួរទៅលើសាក្សី ដោយយោងទៅលើឯកសារនេះ គឺដោយសារតែលេខយោងជើងទំព័រ មិនបានបញ្ជាក់អំពីយថាភាពនៃឯកសារនេះទេ។ ដូច្នេះសាក្សីត្រូវបានអនុញ្ញាតឲ្យជំទាស់តវ៉ា ក្នុងមធ្យោបាយណាមួយដែលសាក្សីយល់ថាសមស្របសម្រាប់ខ្លួន។ តើត្រឹមត្រូវ--

[១១:៤៥:០៩]

**លោក ម៉ៃខល ផេសមិន៖**

លោកស្រីចៅក្រមនេះគឺជាគោលបំណងនៃសំណួររបស់ខ្ញុំ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

*(គ្មានសំឡេង)*

**សួរដោយលោក ម៉ៃខល ផេសមិន៖**

ហើយខ្ញុំយល់ស្រប។ តើខ្ញុំអាចបន្តបានទៀតទេ?

**ស៖** ឌុច សូមលោកអានឃ្លានៅក្នុងប្រអប់ដែលមានគូសបន្ទាត់ក្រហមពីក្រោមនេះ។

**ឆ៖** សូមគោរពលោកប្រធាន តាមប្រសាសន៍របស់លោកជំទាវ ខាតវ៉ាយថ៍ អម្បាញ់មិញខ្ញុំជឿថា ឯកសារនេះតុលាការមិនទាន់ទទួលស្គាល់យថាភាពនៅឡើយទេ។

**លោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី សូមៗអានទៅ! ឌុច សូមឆ្លើយនឹងសំណួរខ្ញុំសិនមក។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ខ្ញុំសូមរក្សាសិទ្ធិមិនអាន។

[១១:៤៦:១០]

**ស៖** ឌុច អ្នកឯងមិនមានសិទ្ធិមិនអានឃ្លានៅក្នុងប្រអប់នេះទេ។ អានឃ្លានៅក្នុងប្រអប់ដែលមានអូសបន្ទាត់ពីក្រោមនេះទៅ។

**ឆ៖** អរគុណ។ ខ្ញុំមកទីនេះ ខ្ញុំស្តាប់ចៅក្រម មិនមែនស្តាប់អ្នកឯងទេ។

**ស៖** ខ្ញុំសួរសំណួរទៅលោកហើយតើ សូមឲ្យលោកអានឃ្លានេះទៅ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ឌុច លោកអាចឆ្លើយសំណួររបស់មេធាវីការពារក្តី ក៏ប៉ុន្តែលោកមានសិទ្ធិអាចលើកឡើងពីយថាភាពនៃឯកសារបាន។ ក៏ប៉ុន្តែ ទីមួយលោកត្រូវផ្តល់ជាគំនិតយោបល់ណាមួយ មតិយោបល់ណាមួយទៅលើឯកសារសិនទៅ ហើយមេធាវីការពារក្តីនឹងតាំងសំណួរដោយយោងទៅលើឯកសារនុ៎ង។ ច្បាស់ទេសម្រាប់-- ច្បាស់សម្រាប់លោកទេ?

[១១:៤៧:២១]

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកជំទាវ បើតាមខ្ញុំស្តាប់អម្បាញ់មិញគឺលោកស្រី-- លោកជំទាវអនុញ្ញាតឲ្យខ្ញុំលើកហេតុផលមួយចំនួនអំពីការតវ៉ារឿងយថាភាពនៃឯកសារ។ ឯកសារនេះខ្ញុំសូមតវ៉ាអំពីយថាភាព។ ទីមួយ របស់ដែលប្រគល់ឲ្យខ្ញុំមិនមែនជាច្បាប់ដើម។ ទីពីរ ច្បាប់ចម្លងនេះវាខុសថ្ងៃខែ កាលបរិច្ឆេទដែលខ្ញុំសម្ភាសជាមួយ គ្រីស្តូ ប៉េស្ស៊ូ។ ខ្ញុំសម្ភាសជាមួយ គ្រីស្តូ ប៉េស្ស៊ូ ពីថ្ងៃ៣០ រហូតដល់ថ្ងៃបី ថ្ងៃ-- ស្រាប់តែក្នុងច្បាប់ជាលាយលក្ខណ៍អក្សរសរសេរថា “សេចក្តីសម្ភាសរបស់ខ្ញុំពីថ្ងៃបួនដល់ថ្ងៃប្រាំមួយ”។ នេះជាភស្តុតាងទីពីរ។

[១១:៤៨:១៣]

ហើយភស្តុតាងទីបី ខ្ញុំយកមកឯកសារជាអក្សរនុ៎ងមកអាន វាមានរឿងខុសឆ្គងច្រើនដែលខ្ញុំមិនដែលបានដឹង។ ហើយទីបួន ច្បាប់ដើមជា-- ច្បាប់ នែ៎ ច្បាប់ជានេះក៏ខ្ញុំយកទៅស្តាប់។ ច្បាប់ជាខ្សែអាត់ថតសំឡេងនោះ ជាថាសថតសំឡេងនោះក៏ខ្ញុំយកទៅស្តាប់។ ថាសថតសំឡេងនេះមិនមែនត្រឹមត្រូវទេ ម្ខាងហ្នឹងមាននិយាយពីស្អីទៅ។ ដូច្នេះ ចាប់ថតសំឡេងហ្នឹង ខ្ញុំជឿថានៅការិយាល័យសហព្រះរាជអាជ្ញា។ មិនមែនជាច្បាប់ត្រឹមត្រូវទេដែលប្រគល់ទៅឲ្យខ្ញុំ។ ដូច្នេះ បញ្ហាអស់នេះវាបង្ហាញឲ្យឃើញថាឯកសារនេះវាមិនមានយថាភាព ហើយនៅពេលដែលការិយាល័យសហចៅ-- នែ៎ ព្រះរាជអាជ្ញាដាក់ឯកសារនេះដេញដោល កាលនោះនៅសម័យ អាឡិចសាន់ឌឺ ប៊េត។ មេធាវីខ្ញុំ ហ្វ្រង់ស្វ័រ រ៉ូ តវ៉ា គ្មានមេធាវីនៅក្បែរ។ ដូច្នេះឯកសារនេះមិនអាចដាក់បានទេ។

[១១:៤៩:១៧]

ហើយម្យ៉ាងវិញ ប៉ុន្មានថ្ងៃមុននេះ ដូចជាលោកប្រធាន ឬក៏អ្នកណាទេនិយាយពីឯកសាររបស់ នីក ដងឡុប អ៊ំ ណេះសូមទោស ឯកសាររបស់ គ្រីស្ទ ប៉េស្ទ័ អត់មានតម្លាភាព ឬយថាភាព អាហ្នឹងស្របច្បាប់ទេ ព្រោះគ្មានមេធាវីនៅក្បែរ។ ដូច្នេះ បដិសេធឯកសារនេះរួចទៅហើយនៅក្នុងអង្គជំនុំជម្រះយើង។ នេះអំពីយថាភាពនៃឯកសារ។ ខ្ញុំសូមលើកបញ្ហាអស់នេះប៉ុណ្ណោះ ជូនតុលាការ។ ដូច្នេះ តាមបញ្ហារបស់លោកជំទាវ ខ្ញុំសូមអាន ហើយនិងពន្យល់អំពីបញ្ហានេះដូចតទៅ៖

[១១:៥០:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥១:២៩]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះយើងនៅតែជួបប្រទះនូវបញ្ហាយថាភាពនៃឯកសារ និងភាពជឿជាក់បាននេះ ទោះបីយើងបានជួបប្រទះ ហើយនិងបានដោះស្រាយជាច្រើនហើយក៏ដោយ ដោយសារហេតុផលនៃឯកសារនៅក្នុងសំណុំរឿងក្តីនេះមានចំនួនច្រើនលើសលប់។ ហើយមុននឹងបន្តទៅទៀត អង្គជំនុំជម្រះត្រូវតែសម្រេចអំពីយថាភាព និងភាពជឿជាក់បាននៃឯកសារនេះជាមុនសិន មុននឹងបន្តឲ្យមេធាវីការពារក្តី នួន ជា ដេញដោលចំពោះសាក្សីរូបនេះ ពាក់ព័ន្ធនឹងឯកសារនេះ។ ហើយដើម្បីបានព័ត៌មានបន្ថែមទៀត អង្គជំនុំជម្រះសួរទៅភាគីដទៃទៀត ថាតើមានមតិយោបល់អ្វីដែរទេ លើឯកសារនេះ? ប្រសិនបើមាន សូមអញ្ជើញ!

[១១:៥២:៣៩]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមានមតិយោបល់ បើសិនខ្ញុំអាចធ្វើបាន។ ទីមួយ គឺមិនមែនអាស្រ័យទៅលើសាក្សីដែលត្រូវជំទាស់តវ៉ាទៅលើយថាភាពនៃឯកសារនោះទេ។ ខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានប្រើឯកសារនេះនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។ ដូចដែលខ្ញុំបានលើកឡើងហើយ គឺថាសហចៅក្រមស៊ើបអង្កេតក៏បានប្រើឯកសារនេះដែរ។ ដូច្នេះខ្ញុំគិតថា អ្នកទាំងអស់គិតអំពី គិតឃើញអំពីយថាភាពនៃឯកសារនេះហើយ។ ដូច្នេះសាក្សីមិនអាចជំទាស់ចំពោះយថាភាពនៃឯកសារនោះទេ។ ខ្ញុំសូមឲ្យសាក្សីអានទៅលើបន្ទាត់ទាំងឡាយណាដែលខ្ញុំបានស្នើសុំ ហើយដើម្បីឆ្លើយមកវិញថា គាត់មិនបានឆ្លើយដូច្នោះទេ។ ហើយបន្ទាប់មកខ្ញុំនឹងសួរដេញដោលតទៅទៀត។ សូមអរគុណ។

[១១:៥៣:៤០]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សហព្រះរាជអាជ្ញាបានដាក់ឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះ អ្វីដែលយើងខ្ញុំអាចលើកឡើងនៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះបានសម្រេចថា អាចទទួលយកបាន ភាគច្រើនដោយសារថា សាក្សីនៅពេលនេះគាត់ជាជនជាប់ចោទ មិនបានផ្តល់សិទ្ធិទៅឲ្យគាត់នៅពេល សម្ភាសនោះទេ។ ហើយបញ្ហានៅជុំវិញកាលៈទេសៈនៅពេលនោះ គឺថាអង្គជំនុំជម្រះមិនអាចសម្រេច នូវដំណាក់កាលនោះទេ ទាក់ទងទៅនឹងការកោះហៅនៃសាក្សីនោះ។ ដូច្នេះ យើងកំពុងនិយាយអំពីការ ព្រួយបារម្ភទៅលើភាពជឿនលឿននៃដំណើរការនីតិវិធី។

[១១:៥៤:២៩]

ដូច្នេះខ្ញុំសូមរំឭកថា ការសម្ភាសនៅចំពោះមុខតុលាការនេះ គឺទាក់ទងទៅនឹងរឿងនេះ គឺសហ ព្រះរាជអាជ្ញាបានដាក់ឯកសារនៅចំពោះមុខតុលាការហើយ។ គ្រាន់តែថាមានជំហរខុសគ្នាខ្លះ ទាក់ទង ទៅនឹងចម្លើយដែលសាក្សីបានផ្តល់នាពេលនោះ ហើយដែលនោះ គឺថាគាត់ជាជនជាប់ចោទ។ ដូច្នេះ យើងខ្ញុំគ្មានអ្វីត្រូវជំទាស់ទៅនឹងមតិយោបល់ណារបស់សាក្សីនោះទេ។ ដូច្នេះ ខ្ញុំយល់ឃើញថាមានបញ្ហា ពាក់ព័ន្ធទៅនឹងយថាភាពនៃឯកសារនេះ ថាតើអង្គជំនុំជម្រះត្រូវបង្ហាញបន្ថែមទៀតចំពោះឯកសារនេះ ឬក៏យ៉ាងនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១១:៥៥:២៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំយល់ឃើញថាជាការបារម្ភណាស់ដែលថាមេធាវី នួន ជា បានធ្វើការប្រៀបធៀប គ្នារវាងឯកសារដើម និងឯកសារចម្លង។ ខ្ញុំ-- គាត់សុំឲ្យអានឯកសារ អ៊ីចឹងយើងគិតថា ជាការស្រួល យើងថាឲ្យគាត់អានឯកសារម្តងទៅ ព្រោះថាខាងយើងខ្ញុំនេះ មិនមានជំទាស់អីទេ។

**ប្រធានអង្គជំនុំ៖**

មេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ បញ្ហាមួយគឺថា បើសិនជាឯកសារនេះត្រូវបានប្រឡាក់ប្រឡូក ឬក៏កែប្រែ សំណួរថាតើវាមានយថាភាពហើយឬនៅ? តើយើងត្រូវជជីកសួរអំពីភាពគួរឲ្យជឿជាក់បាននៃឯកសារនេះដែរឬទេ? តាមដែលខ្ញុំយល់គឺថាសាក្សីកំពុងជំទាស់តវ៉ាទៅលើខ្លឹមសារនៅក្នុងឯកសារនេះ។ ដូច្នេះ គាត់យល់ស្រប ឬក៏មិនយល់ស្រប ឬក៏គាត់មានការផ្តល់មតិយោបល់? បើនិយាយថា ឯកសារនេះមិនមានយថាភាពដោយសារតែឯកសារនេះត្រូវបានកែប្រែ ប្រឌិត ឬក៏យ៉ាងណានោះ វាជារឿងមួយដែលត្រូវនឹងអាចលើកឡើងបាននោះ។ សាក្សី គឺថាគាត់បានជំទាស់តវ៉ាទៅលើខ្លឹមសារនៅក្នុងឯកសារនេះ។ ហើយក្នុងនាមជាសាក្សី គាត់អាចផ្តល់មតិយោបល់បាន ហើយបន្ទាប់មក គឺអាស្រ័យទៅលើលោក លោកស្រីចៅក្រមតែម្តង ថាតើសម្រេចទទួលយក ឬក៏មិនទទួលយក។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក ម៉ៃខល កាណាវាស ចង់មានមតិយោបល់អ្វីទេលើបញ្ហាយថាភាព ឬភាពអាចទទួលយកបាននៃឯកសារដែលពិភាក្សាអម្បាញ់មិញនេះ?

លោក ផេសមិន!

[១១:៥៧:៣៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែបញ្ជាក់ថា ឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះបានទទួលយកហើយ។ សំណួរបញ្ហាពាក់ព័ន្ធតែទៅនឹងយថាភាពនៃឯកសារប៉ុន្តែយើងអាចធ្វើបន្ទាប់តែពីពេលដែលសាកសួរសាក្សីរូបនោះហើយ។ ពីព្រោះប្រតិចារឹក គឺថាបានកត់ត្រាច្បាស់លាស់ហើយ។

**លោក វីណ្ស៊ៀម ស្មីត៖**

ខ្ញុំសូមលើកសង្ខេបទេ។ ឯកសារនេះមិនទាន់បានទទួលយកនៅឡើយទេ គឺនៅក្នុងឧបសម្ព័ន្ធ១២ និងឧសម្ព័ន្ធ១៣ គឺមិនមានឯកសារនេះទេ។ ដូច្នេះ យើងខ្ញុំកំពុងតែរងចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថា តើសាក្សីអាចឆ្លើយ ឬក៏អានទៅនឹងផ្នែកណាមួយនៃឯកសារជាក់លាក់ដែរឬទេនោះ ទាក់ទងទៅនឹងបញ្ហាយថាភាព គឺថាអាចនឹងពិភាក្សាគ្នានៅពេលបន្ទាប់បាន។

[១១:៥៨:៤៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ការចាប់អារម្មណ៍របស់អង្គជំនុំជម្រះលើបញ្ហានេះ ដោយសារបញ្ហានេះ បានកើតឡើងនៅក្នុងសំណុំរឿង០០១ម្ដងរួចហើយ ហើយនៅក្នុងសំណុំរឿង០០១នោះ អង្គជំនុំជម្រះ បានសម្រេចមិនដាក់ឯកសារនេះលើកយកមកពិភាក្សាដេញដោលទេ។ អ៊ីចឹងហើយ ស្រាប់តែមករឿង ០០២ វាមានវត្តមានអត្ថិភាពនៃឯកសារនេះសាជាថ្មីម្ដងទៀត ហើយក៏វាមានការមតិយោបល់ផ្សេងៗ ខុសគ្នាដែលមានការជំទាស់តវ៉ា។ ជាពិសេសលើកនេះ គឺមានការជំទាស់តវ៉ាពីសាក្សីដែលជាលក្ខណៈ ដោយឡែកខុសធម្មតា គឺមានការតវ៉ាជំទាស់ពីភាគី។

[១១:៥៩:២៨]

ឥឡូវនេះដោយពេលវេលាសមល្មមនឹងសម្រាក ដើម្បីពិសារថ្ងៃត្រង់ផង ហើយដើម្បីដោះស្រាយ បញ្ហាដែលស្មុគស្មាញនេះ ដើម្បីទម្លាយឲ្យបានដំណើរការទៅមុខ មានប្រសិទ្ធភាព និងបានឆាប់រហ័ស នោះ អង្គជំនុំជម្រះសម្រេចសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ត្រឹមនេះ ហើយសវនាការនឹងលើកទៅ បន្តធ្វើនៅរសៀលនេះចាប់ផ្ដើមពីម៉ោងមួយសាមសិបនាទី ហើយមុននឹងចាប់ផ្ដើមនោះ អង្គជំនុំជម្រះនឹង សម្រេចលើបញ្ហានេះផង ដើម្បីឲ្យដំណើរការដេញដោលទៅមុននៅរសៀលនេះបានប្រព្រឹត្តិទៅឆាប់ រហ័ស។

អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សី កាំង ហ្កេកអ៊ាវ ទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅរសៀលនេះឲ្យបាននៅ ម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោក ម៉ៃខល ផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

ដោយសារថាមូលហេតុបញ្ហានេះដែលជម្រាបតុលាការថា កូនក្ដីរបស់ខ្ញុំសូមរក្សាសិទ្ធិតាមដាន ពីបន្ទប់នៅខាងក្រោម លោកប្រធាន។

[១២:០០:៥២]

**ប្រធានអង្គជំនុំ៖**

បាទបានស្ដាប់-- អង្គុយចុះ! បានស្ដាប់សំណើរសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើង តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅតាមរយៈ

ប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការនេះ។ ដោយគាត់លះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍ពេញមួយរសៀល ដោយគាត់លះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ តែអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅរសៀលនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងរសៀលនេះបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់សវនាការឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣៧ នាទី)*

[១៣:៣៧:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីអាចតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច។ អង្គជំនុំជម្រះសាលាដំបូង សូមដាក់នូវឯកសារ E43/4 ដែលជាសេចក្ដីសម្រេចមួយ ពាក់ព័ន្ធនឹងឯកសារដែលមេធាវីការពារក្ដី នួន ជា បានលើកយកមកដាក់ដេញដោលចំពោះសាក្សីរូបនេះ នៅក្នុងអំឡុងពេលមុនសម្រាកអាហារថ្ងៃត្រង់។ សេចក្ដីសម្រេចនេះ គឺមានចំណងជើងថា “សេចក្ដីសម្រេចស្ដីពីភាពទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង”។

ហើយអង្គជំនុំជម្រះនឹងផ្តល់វេទិកា ជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការសួរដេញដោលបន្ត ពាក់ព័ន្ធនឹង-- ពាក់ព័ន្ធនឹងឯកសារដែលមេធាវីការពារក្តីបានដាក់នៅចំពោះមុខសាក្សីកាលពីព្រឹកមិញ។ តែទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសូមជម្រាបថា បញ្ហានៃការវាយតម្លៃលើភស្តុតាង នៅក្នុងសំណុំរឿងគិតទាំងឯកសារដាក់ដេញដោលនេះផងដែរ គឺជាសិទ្ធិរបស់-- ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះដែលនឹងពិចារណាសម្រេច វាយតម្លៃសម្រេចនៅក្នុងអំឡុងពេលនៃការរៀបចំសេចក្តី-- ចេញសេចក្តីសម្រេច។

ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់ ហើយនិងជ្រះស្រឡះ សូមឲ្យលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បញ្ជាក់បន្ថែមអំពីបញ្ហានេះដល់ភាគី។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៣៩:៥៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ឲ្យមានការបំភ្លឺពីព្រោះថា ភាគីទាំងអស់នេះ ថាបានទទួលការបកប្រែមិនបានត្រឹមត្រូវ អ្វីដែលលោកបានជម្រាបជូនអម្បាញ់មិញនេះ គឺថាឯកសារលេខ E43/4 នេះគឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានធ្វើនៅក្នុងសំណុំរឿង០០១ ហើយដែលពាក់ព័ន្ធទៅនឹងសេចក្តីសម្អាសន៍ ដែលធ្វើឡើងដោយតំណាង នៃឧត្តមស្នងការអង្គការសិទ្ធិមនុស្ស ហើយដែលបានដាក់ចូលទៅក្នុងសំណុំរឿង០០២។

បញ្ហាការសួររបស់ខាងមេធាវីការពារក្តី អាចបន្តទៅបាន ហើយវាត្រូវតែមានភាពពាក់ព័ន្ធ ហើយយើងអាចវាយតម្លៃយថាភាព ឬក៏តម្លៃនៃសេចក្តីសម្អាសន៍នេះបាននៅពេលក្រោយ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក ឌុច តើលោកអាចអានបានទៅលើផ្នែក ដែលខ្ញុំបានគូសបញ្ជាក់ដែរឬទេ? សូមឲ្យលោកជួយអានបាទ។

**ឆ៖** អរគុណ។ ខ្ញុំសូមអាន៖ "នៅក្នុងករណីណាដែលប្រើវិធីក្តៅ ឧទាហរណ៍ នៅពេលវាអត់ឆ្លើយ។ វាឆ្លើយទៅៗ មិនពេញចិត្តនោះណា១។ ករណី កុយ ធួន យើងធ្វើទារុណកម្ម ដោយសាររឿងប្រតិកម្ម"។ នេះខ្ញុំសូមអានប៉ុណ្ណឹង។

[១៣:៤២:២៥]

**ស៖** សូមលោកអានបន្ត។

**ឆ៖** ខ្ញុំសូមបដិសេធ សេចក្ដីអម្បាញ់មិញ ដែលនិយាយថា វិធីក្ដៅប្រើនៅពេលដែលសេចក្ដីសារភាពមិនពេញចិត្តសារភាព។ ខ្ញុំអត់ទាន់បាននិយាយពាក្យនេះទេ ព្រោះខ្ញុំគិតថា និយាយពីករណី កុយ ធួន យើងប្រើវិធីក្ដៅនៅពេលដែលគាត់ធ្វើប្រតិកម្ម។

[១៣:៤៣:២៤]

**ស៖** ឌុច ហេតុអ្វីបានជាលោកប្រើវិធីក្ដៅលើ កុយ ធួន?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចំណុចនេះហើយ ដែលខ្ញុំបដិសេធឯកសារនេះ ព្រោះខ្ញុំចាំច្បាស់ណាស់ ការសួរចម្លើយ កុយ ធួន គឺខ្ញុំអ្នកធ្វើ មេអ្នកតាមដានដាច់ខាត។ ខ្ញុំនិយាយហូរហែតាំងពីពេល កុយ ធួន មកដល់ ខ្ញុំធ្វើយ៉ាងម៉េច ហើយដល់ក្រោយមក ខ្ញុំទុកគាត់នៅលើឡៅលេខ-- នៅលើឡៅប្អូនជាន់ ឲ្យកងពិសេសពីរនាក់ការពារ កុំឲ្យគាត់ធ្វើប្រតិកម្ម។ ដល់ពេលគាត់នៅស្ងប់ចិត្តមួយសន្ទុះ បានខ្ញុំចូលទៅជួបគាត់ និយាយថា ឥឡូវខ្ញុំសូមឲ្យបងនិយាយទៅ មិនមែនមកចំពោះខ្ញុំទេ ចំពោះទៅអង្គការ ចំពោះ ប៉ុល ពត នោះ ហើយខ្ញុំធ្វើទុកដូចជានីរសារបងអ៊ីចឹង។ ខ្ញុំហៅគាត់បងពេញមាត់។ ដល់ទៅគាត់សុខចិត្តជាមួយនឹងខ្ញុំ ថាគាត់សរសេរ ហើយគាត់ខំអង្គុយសរសេរ ដល់មួយសន្ទុះ គាត់កាច់ស្លាបប៉ាកា បោកអាកូនកៅអី កូនតូចៗដែលគេដាក់ស្បែកជើងនោះចោលនៅលើនោះ ហើយគាត់ថា អង្គការមួយនឹងគេដែរ។ ដល់ទៅខាងកងពិសេសហ្នឹង គេតេមកខ្ញុំថា បងប្រតិកម្មហើយ--

[១៣:៤៤:៤៨]

**ស៖** ខ្ញុំសូមកាត់សម្ដីសាក្សីលោកប្រធាន។ លោក ឌុច ខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកប្រើវិធីក្ដៅលើ កុយ ធួន។ សូមឲ្យលោកឆ្លើយសំណួរនេះ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើមិនឲ្យខ្ញុំអត្ថាធិប្បាយទេ ខ្ញុំសូមមិនឆ្លើយនឹងសំណួរអីតទៅទៀត ព្រោះឯកសារនេះ ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលណាស់។ ឯកសារផ្សេងទៀត ដែលនិយាយពីបញ្ហាហ្នឹងច្រើនណាស់ តើឯកសារមួយនេះ ម៉េចក៏ផ្ទុយពីគេ? ហើយរឿងហ្នឹង ដែលរឿងខ្ញុំយកចិត្តទុកដាក់ជាងគេ។ ឲ្យខ្ញុំឆ្លើយយ៉ាងម៉េច បើមិនឲ្យខ្ញុំអត្ថាធិប្បាយ ដើម្បីជូនអង្គប្រជុំសម្រេច។ តើឯណានិយាយពិត? អ្នកណានិយាយភរ? ហើយមកសួរខ្ញុំអ៊ីចឹង ខ្ញុំអត់ឆ្លើយទេ។

**ស៖** យើងជាការពិត ត្រូវរកអ្នកណានិយាយកុហក អ្នកណានិយាយតែការពិត។ ដូច្នេះហើយទើបខ្ញុំសួរសំណួរនេះ។ ហេតុអ្វីបានជាលោកអនុវត្តវិធីក្ដៅលើ កុយ ធួន?

**លោក វីល្លៀម ស្មីត៖**

សូមគោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៤៦:១៤]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន នេះលើកទីបីហើយ សំណួរនេះសួរលើកទីបីហើយ។ សាក្សីគាត់មិនដែលប្រើ ថា គាត់ប្រើវិធីក្ដៅលើ កុយ ធួន នោះទេ។ ចំណុចនេះ គឺមាននៅក្នុងចម្លើយរបស់គាត់។ អ្វីដែលយើងព្រួយបារម្ភគឺមេធាវីការពារក្ដីមិនឲ្យសាក្សីពន្យល់ទៅលើចំណុចនេះ។ សំណួរដែលថាមានប្រើវិធីក្ដៅលើ កុយ ធួន ដែរឬទេ? គឺមិនមែនសាក្សីខ្លួនឯងនេះផ្ទាល់ជាអ្នកនិយាយនោះទេ ជាកិច្ចសម្ភាសន៍នេះ ដែលបានលើកឡើង។ ហេតុដូច្នេះ យើងគួរតែឲ្យសាក្សីរូបនេះពន្យល់ ហេតុអ្វីបានជាចំណុចនិយាយថាវិធីក្ដៅលើ កុយ ធួន នេះបានសរសេរនៅក្នុងកំណត់ហេតុ។ យើងគួរតែឲ្យសាក្សីធ្វើអត្ថាធិប្បាយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសូមអញ្ជើញមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន បើមើលទៅតាមអ្វីដែលបានសរសេរនេះ ហាក់ដូចជាមានលក្ខណៈច្របូកច្របល់មែនទែន។ ដូច្នេះ អ្វីដែលលោក ឌុច ស្នើសុំឲ្យមានការបកស្រាយអំពីបញ្ហានេះ គួរតែចាត់ទុកថាជាផ្នែកមួយនៃការឆ្លើយរបស់គាត់ ហើយអនុញ្ញាតឲ្យគាត់ឆ្លើយបន្តទៀត។

[១៣:៤៧:៣១]

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់មានប្រសិទ្ធភាព។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឌុច បានឆ្លើយរួចហើយ។ ដោយធ្វើការកត់សម្គាល់អំពីបញ្ហាឯកសារដែលគាត់បានជំទាស់តវ៉ា តាំងពីក្នុងសំណុំរឿង០០១មកម្ល៉េះ។ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយ ហើយអង្គជំនុំជម្រះបានដាក់ឯកសារដែលខ្លួនបានសម្រេចនៅក្នុងសំណុំរឿង នៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ គឺ E43/4។

ដូច្នេះ មេធាវីបើមានសំណួរអ្វីផ្សេងទៀត សូមបន្តទៅសំណួរថ្មីផ្សេងទៀត ជំនួសសំណួរ

អម្បាញ់មិញនេះ គឺចាត់ទុកថាបានសួរ និងបានឆ្លើយរួចហើយ។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ឌុច តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា អ្នកទោស កុយ ធួន ប្រតិកម្ម តើលោកមានន័យយ៉ាងម៉េច?

[១៣:៤៩:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥១:៣៨]

**ប្រធានអង្គជំនុំ៖**

សាក្សី តើសាក្សីដែលមានបាន ដែលបាននិយាយថា កុយ ធួន ហ្នឹងមានប្រតិកម្មតបតនៅក្នុងអំឡុងពេលដែលសួរចម្លើយដែរឬទេ? លោកដែលមាននិយាយភាសា ឃ្លាហ្នឹងដែរឬទេ កន្លងមកនេះ?

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ បញ្ហានេះខ្ញុំនិយាយច្រើន ពេលកាលណាខ្ញុំចូលលម្អិតរឿងសួរចម្លើយ កុយ ធួន ខ្ញុំតែងតែនិយាយ។ គាត់ប្រតិកម្មបីដង។ ហើយប្រតិកម្មម្តងៗ តើខ្ញុំធ្វើយ៉ាងម៉េចដើម្បីម្ចាស់ការលើ កុយ ធួន អាហ្នឹងក៏ខ្ញុំធ្លាប់និយាយ។ ហើយខ្ញុំសួរ កុយ ធួន ក្នុងលក្ខណៈពិសេសយ៉ាងម៉េច? ខ្ញុំរៀបចំពិសេសយ៉ាងម៉េច? ក៏ខ្ញុំនិយាយទាំងអស់។ ដូច្នេះបញ្ហានេះខ្ញុំចង់និយាយឲ្យបានហូរហែ បញ្ហានេះ។ ដូច្នេះសូមលោកប្រធានមេត្តាពិចារណា តើអនុញ្ញាតឲ្យខ្ញុំពន្យល់បញ្ហាហូរហែឲ្យច្បាស់លាស់ មានចុងមានដើមឬយ៉ាងម៉េច?

[១៣:៥២:៤៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកនិយាយឲ្យចប់មើល៍ បញ្ហារឿង កុយ ធួន នេះ!

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ សូមបញ្ជាក់ជូនតុលាការ និងជាតិប្រជាជនកម្ពុជាថា ខ្ញុំធ្លាប់នៅរស់ក្រោមការគ្រប់គ្រងរបស់ កុយ ធួន។ តាំងពីខែដប់ ១៩៦៧ នៅក្នុងបឹងធំ ក្រោយរោងចក្រតម្បាញកំពង់ចាម ថែវទូកបញ្ជៀសគាត់។ ខ្ញុំមានមនោសញ្ចេតនាគោរពគាត់ណាស់។ នៅក្រោយមក ពេលដែល កុយ ធួន មានបញ្ហាខ្ញុំមិនដឹងទេ ប៉ុន្តែមេខ្ញុំចេះតែសួរខ្ញុំ ពីរឿង កុយ ធួន ស្រួលយ៉ាងម៉េច? ល្អយ៉ាងម៉េច ពេល

ដែលខ្ញុំនៅជាមួយ? ខ្ញុំរាយការណ៍ជូនគាត់ដោយត្រង់។ ដល់ក្រោយមក បាន១បែករឿងពីរឿង កុយ ធួន មានបាតុភាព--

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទៅមេធាវី? សូមអញ្ជើញ!

[១៣:៥៣:៥៣]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំព្រួយបារម្ភ ប្រសិនបើឲ្យគាត់និយាយអត្ថាធិប្បាយបន្តដូច្នេះ។ ខ្ញុំសួរគាត់ជាក់លាក់អំពីសាក្សីដែលបានឆ្លើយប្រតិកម្មរបស់ កុយ ធួន។ ដូច្នេះខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញពាក់ព័ន្ធចំណុចនេះ។ ខ្ញុំសូមជំទាស់ការអនុញ្ញាតឲ្យសាក្សីធ្វើការអត្ថាធិប្បាយ និងរៀបរាប់ ដោយសារខ្ញុំគិតគូរពីពេលវេលារបស់ខ្ញុំ។ ខ្ញុំស្ម័គ្រចិត្តរៀបចំសំណួររបស់ខ្ញុំឡើងវិញ សួរអំពីបញ្ហាវិធីក្ដៅនេះ ប្រសិនបើអង្គជំនុំជម្រះចង់ឲ្យខ្ញុំធ្វើដូច្នេះនោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

[១៣:៥៤:៤៤]

**លោក វីណ្ដៀម ស្មីត៖**

ខ្ញុំមិនចង់កាត់សម្ដី និងលំហូរនីតិវិធីរបស់យើងនោះទេ។ ក៏ប៉ុន្តែបញ្ហានៅក្នុងសំណួរនេះ គឺថាសាក្សី គឺគាត់បាននិយាយ ឬក៏មិននិយាយ។ សាក្សីគាត់បានបញ្ជាក់ថា តើគាត់បាននិយាយអ្វីខ្លះ? ដូច្នេះជាជាងកុំឲ្យបញ្ហានេះកាន់តែយល់ច្រឡំ ខ្ញុំសូមឲ្យសួរវិញថាតើសាក្សីបាននិយាយសម្ដីនេះដែរឬទេ? ហើយប្រសិនបើនិយាយនោះ គឺបានន័យថាវាជាការពិត។ ហើយប្រសិនជាសាក្សីនិយាយថា គាត់មិនបានលើកសម្ដីដូច្នេះនោះទេ ដូច្នេះយើងនឹងយល់អំពីបញ្ហានេះ។ សំណួរដែលបានសួរឡើង គឺវាផ្អែក--ត្រូវផ្អែកទៅលើអង្គហេតុដែលនិយាយចេញមកពីមាត់សាក្សីផ្ទាល់។ ដូច្នេះយើងមិនដឹងថា តើបញ្ហានេះវាកើតឡើង ឬក៏មិនកើតឡើងក្នុងចំណុចសំណួរនេះ។

[១៣:៥៥:៣៦]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំឯកភាពជាមួយនឹងការលើកឡើងរបស់ខាងសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

ឌុច ឥឡូវបញ្ចប់នូវការអត្ថាធិប្បាយលើបញ្ហាពាក់ព័ន្ធជាមួយនឹង កុយ ធួន អម្បាញ់មិញនេះ ហើយចាំស្តាប់នូវសំណួរ ដែលនឹងសួរបន្តដោយមេធាវីការពារក្តី នួន ជា។

មេធាវីការពារក្តី នួន ជា ក៏ចៀសវាងផងដែរនូវសំណួរដែលច្បាប់ហាមឃាត់។ យើងនឹងប្រើឆន្ទានុសិទ្ធិនៅក្នុងការកាត់មិនឲ្យសាក្សីឆ្លើយទេ ប្រសិនបើសួរសំណួរដែលច្បាប់ហាមឃាត់មានតាំងសំណួរនាំមុខជាដើម។

[១៣:៥៦:៣០]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច តើលោកមានប្រាប់ គ្រីស្ទ ប៉េស្ទ ថាលោកបានប្រើវិធីក្តៅលើ កុយ ធួន ដែរឬទេ នៅពេលដែល កុយ ធួន ប្រតិកម្ម?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើសំណួរបែបនេះ ខ្ញុំសូមឆ្លើយ។ កុយ ធួន ប្រតិកម្មបីដង ក៏ប៉ុន្តែខ្ញុំអត់ប្រើវិធីក្តៅទេ ខ្ញុំប្រើនយោបាយទៅបង្ក្រប កុយ ធួន។

**ស៖** ខ្ញុំសូមត្រឡប់ទៅចំណុចការលើកឡើងកាលពីព្រឹកមិញ ដោយខ្លីៗឡើងវិញ។ នៅពេលខ្ញុំសួរថា តើនៅក្នុងអំឡុងពេលនោះ លោកបានដឹងអំពីវិធីក្តៅ វិធីត្រជាក់ និងវិធីអង្កៀមដែរឬទេ? ព្រឹកមិញលោកឆ្លើយមិនច្បាស់ជូនខ្ញុំសោះ។ តើលោក-- សូមបញ្ជាក់មក នៅពេលនេះថា នៅពេលដែលលោកបម្រើការងារពេលនោះ តើលោកដឹងអំពីវិធីក្តៅ វិធីត្រជាក់ វិធីអង្កៀមនេះដែរឬទេ? ហើយសំណួររបស់ខ្ញុំសួរនេះប្រហែលជាឲ្យលោកឆ្លើយបញ្ជាក់ទៅលើកាលពីព្រឹកមិញ។ តើលោកអាចជម្រាបបានដែរឬទេ ថាតើនៅសម័យនោះលោកបានដឹងអំពីវិធីក្តៅ វិធីត្រជាក់ និងវិធីអង្កៀមដែរឬទេ?

[១៣:៥៨:២៣]

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះខ្ញុំគិតថាជាសំណួរច្រំដែល។ ដូច្នេះខ្ញុំសូមយោបល់លោកប្រធាន តើឲ្យខ្ញុំឆ្លើយឬអត់?

**ប្រធានអង្គជំនុំ៖**

ឆ្លើយចុះ ពីព្រោះគេយល់ថា ព្រឹកមិញលោកឆ្លើយទៅគេស្តាប់មិនយល់ ដោយសារមិនទាន់

ច្បាស់ ពីព្រោះគាត់ចំណាយពេលវេលា ក្នុងពេលវេលាដែលយើងបែងចែកឲ្យគាត់ពីរថ្ងៃ។ គឺគាត់រហូតដល់ថ្ងៃស្អែក ខ្វះមួយម៉ោង បានន័យថាដកមួយម៉ោងចេញ។

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឥឡូវខ្ញុំសូមឲ្យ ផេសមិន សួរខ្ញុំម្តងទៀត ដើម្បីច្បាស់លាស់ទាំងអស់គ្នា។

[១៣:៥៩:០៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ហើយកត់ត្រាឲ្យបានត្រឹមត្រូវនូវសំណួរនេះ ចៀសវាងសួរច្រំដែលខាតពេលអត់ប្រយោជន៍។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច មិនមែនលោកជាអ្នកសម្រេចថាត្រូវឆ្លើយ ឬក៏មិនឆ្លើយ ហើយគិតថាសំណួរនោះជាន់គ្នាឬក៏យ៉ាងណានោះទេ។ វាអាស្រ័យទៅលើអង្គជំនុំជម្រះបង្គាប់ឲ្យលោកឆ្លើយ។ តើលោកដឹងដែរឬទេនៅក្នុងសម័យនោះ ពាក្យថា "វិធីក្តៅ វិធីត្រជាក់ វិធីអង្កៀម" ហ្នឹងវាមានន័យយ៉ាងម៉េចដែរ?

[១៣:៥៩:៥៦]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន "វិធីក្តៅ វិធីត្រជាក់ និងវិធីអង្កៀម" វិធីត្រជាក់ គឺវិធីដែលខ្ញុំប្រើជាមួយ កុយ ធួន ពេលដែល កុយ ធួន ប្រតិកម្ម។ ក៏ប៉ុន្តែនិយាយឲ្យហូរហែទៅជាមួយ កុយ ធួន ខ្ញុំប្រើវិធីត្រជាក់រហូត។ ខ្ញុំយកនយោបាយរបស់ខ្ញុំទៅបង្ក្រាប កុយ ធួន។ នេះវិធីត្រជាក់។ ចុះវិធីក្តៅ យ៉ាងម៉េច? គេមានចំណុចមួយគ្រប់គ្រាន់ ដើម្បីចាប់ថ្នាក់អ្នកឆ្លើយបានគេធ្វើទារុណកម្ម គេវ៉ៃមួយកម្រិតណា។ អានេះវិធីក្តៅ។ វិធីអង្កៀម ទាមទារឆ្លាស់ ម្តងក្តៅម្តងត្រជាក់ ហើយប្រឹងប្រែងយូរអង្វែង ដើម្បីឲ្យបានចម្លើយ។ ហ្នឹងខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

[១៤:០១:០៦]

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ ហេតុអ្វីបានជាលោកប្រាប់ចៅក្រមស៊ើបអង្កេតថា លោកមិនដែលឮពាក្យទាំងអស់នោះទេ ទើបតែក្រោយពីមើលកុន ខ្សែវីដេអូរបស់ រិទ្ធី ប៉ាន់ តែប៉ុណ្ណោះ ទើបលោកដឹងនូវពាក្យទាំងអស់នេះ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ព្រឹកមិញខ្ញុំឆ្លើយថា ពី៧៥ មកដល់-- ពី ១៩៧៥ មកដល់ ២០០៧ វា៣២ឆ្នាំ ដូច្នេះខ្ញុំវង្វេង។ ដល់ក្រោយមក ខ្ញុំឮការជួយសម្រួលរបស់សហព្រះរាជអាជ្ញាលោកថា ពេលនោះ ឌុច ឆ្លើយថា ដូចជាមិនមានបានចែងចែកជាក្រុមត្រជាក់ ក្រុមក្តៅអីទេ។ នេះគាត់ជួយសម្រួលប៉ុណ្ណឹង។ ដូច្នេះដំបូងដែលសហាចៅក្រមស៊ើបអង្កេត លោកសួរខ្ញុំ ខ្ញុំភ្លេច។ ដូច្នេះ ដល់ក្រោយមកបានៗសហព្រះរាជអាជ្ញាលោកជួយសម្រួលបញ្ហានេះតាមការដែលលោកចាំ។

[១៤:០២:៣២]

**លោក ម៉ៃខល ផេសមិន៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតចូលទៅប្រធានបទមួយផ្សេង ហើយខ្ញុំចង់បង្ហាញឯកសារមួយចំនួនចម្លើយសារភាពជូនសាក្សីមើល។ ហើយខ្ញុំសូមអនុញ្ញាតចាប់ផ្តើមចម្លើយសារភាពដែលសាក្សីបានឃើញរួចហើយនៅក្នុងការជំនុំជម្រះនេះ ហើយឯកសារ D43/114 ឧបសម្ព័ន្ធ៧៥។ គឺជាចម្លើយសារភាពរបស់ ទីវ។ ខ្មែរ ERN គឺ 00174754 សូមអនុញ្ញាតតុលាការដាក់បង្ហាញទៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការបញ្ចាំងដាក់ឯកសារនៅលើអេក្រង់ទូរទស្សន៍!

[១៤:០៣:៤៦]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធានឯកសារមិនទាន់បានបង្ហាញនៅក្នុងអេក្រង់សាធារណៈទេបាទ។ សាធារណជនមិនអាចមើលបានទេបាទ។ បាទ ភាគីនៅក្នុងសាលសវនាការទើបបានមើលបានបាទ។ បាទ ឥឡូវនេះបានឃើញដល់អេក្រង់សាធារណៈហើយ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក ឌុច តើលោកស្គាល់ឯកសារមួយនេះទេ? បើសិនជាលោកចង់បានឯកសារលើក្រដាសខ្ញុំនឹងជូនទៅលោក។

[១៤:០៤:២៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះខ្ញុំស្គាល់ ហើយក៏ប៉ុន្តែ-- ទន្ទឹមនឹង

នេះ ខ្ញុំសូមលោកប្រធានបញ្ជាឲ្យគេពង្រីកត្រង់ពាក្យ "ចំណារខ្ញុំ" ព្រោះខ្ញុំមើលមិនដាច់ អក្សរពីរបីតួ។ បានៗ។

**លោក ម៉ៃខល ផេសមិនៈ**

សូមអនុញ្ញាតលោកប្រធាន ប្រសិនជាគាត់បានឯកសារលើក្រដាសអាចនឹងងាយស្រួលគាត់មើល អ៊ីចឹងខ្ញុំសូមអនុញ្ញាតលោកប្រធានជូនទៅគាត់បាទ។

**ប្រធានអង្គជំនុំៈ**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកមកជូនសាក្សីពិនិត្យ!

[១៤:០៥:៤០]

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**សៈ** លោក ឌុច បានបញ្ជាក់រួចហើយ លោកបញ្ជាក់ថា ចំណារនេះ ជាចំណារផ្ទាល់ដៃរបស់លោក ហើយនៅខាងក្រោមឯកសារនេះ សូមៗលោកអានចំណារផ្ទាល់ដៃរបស់លោក ក្នុងប្រអប់ក្រហមកណ្តាលធំនេះបាទ។

**លោក កាំង ហ្គេកអ៊ាវៈ**

**ឆៈ** អរគុណ។ "បងទីគោរព! ឯកសារនេះ សុទ្ធតែមនុស្សសង្គមចាស់ទាំងអស់។ ដោយគោរព។ ឌុច ១០-១១-៧៧"។

**សៈ** សូមអរគុណ។ អ្នកណាជាបងទីគោរព ដែលលោកសរសេរជូនទៅ ក្នុងចំណារនេះ?

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បងជាទីគោរពនេះ ខ្ញុំសរសេរទៅទាំងពីរនាក់ អង្កាល់ដែលនៅជាមួយ សុន សេន ខ្ញុំសរសេរទៅ គឺសំដៅ សុន សេន។ ដល់កាលណា ខ្ញុំនៅជាមួយបងនួន គឺខ្ញុំសរសេរទៅសំដៅ បងនួន។

[១៤:០៧:០៤]

**សៈ** តើលោកអាចពន្យល់តុលាការបានទេ នៅពេលដែលថាខ្ញុំនៅជាមួយ សុន សេន ឬក៏នៅពេលដែលខ្ញុំនៅជាមួយ នួន ជា នោះ តើលោកចង់មានន័យដូចម្តេច?

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនៅជាមួយ សុន សេន គឺខ្ញុំទៅជួបរាយ-ការណ៍ជូន សុន សេន ផ្ទាល់មាត់។ ជួបមុខគ្នាប្រហែលជាកន្លះម៉ែត្រ។ ខ្ញុំនៅជាមួយ នួន ជា គឺខ្ញុំទៅជួបបង នួន ជា ហើយរាយការណ៍ផ្ទាល់មុខគាត់ ប្រហែលកន្លះម៉ែត្រពីខ្ញុំ។ មក យើងថាមួយម៉ែត្រទៅចុះ។

**ស៖** សូមអរគុណ។ ប៉ុន្តែពាក្យថា "បងជាទីគោរព" នៅកន្លែងនេះ តើសុន សេន ឬក៏ នួន ជា សូមលោកបញ្ជាក់ជូនតុលាការមើល៍!

**ឆ៖** អរគុណ។ ពាក្យ "បងជាទីគោរព" នេះ ខ្ញុំសរសេរមិនដឹងជាសំដៅ-- គឺសំដៅខាងលើ ដែលតំណាងអង្គការ តំណាង ប៉ុល ពត ចុះមកជួបខ្ញុំ។

[១៤:០៨:៣០]

**ស៖** តើខ្ញុំយល់ច្បាស់ទេ ពាក្យថា "បងជាទីគោរព" នៅក្នុងចំណារមួយនេះ យោងទៅរក ប៉ុល ពត បាទ តើអ៊ីចឹងឬទេ?

**ឆ៖** អរគុណ។ បងជាទីគោរពនេះ អត់យោងទៅរក ប៉ុល ពត ទេ។ គឺយោងទៅរកបងរូបណា ដែលមកដឹកនាំខ្ញុំផ្ទាល់។

**ស៖** ខ្ញុំយល់ពីចម្លើយ អ៊ីចុះពាក្យថា បងជាទីគោរពកន្លែងនេះ ដែលថាបងមកដឹកនាំខ្ញុំនោះ តើបងណា ដែលលោកសរសេរកន្លែងនេះ តែមួយហ្នឹងទេ?

**ឆ៖** បង តែមួយហ្នឹង ពេលហ្នឹងគឺខ្ញុំសំដៅ នួន ជា។ ពីព្រោះ នួន ជា មកគ្រប់គ្រងខ្ញុំផ្ទាល់។

**ស៖** តើលោកនិយាយថា លោកបានឃើញ-- និយាយបែបនេះដោយឃើញថា កាលបរិច្ឆេទថា ថ្ងៃទី១០ បាទ-- ថ្ងៃទី១០ ខែ១១ ឆ្នាំ១៩៧៧ ហេតុអ្វីបានជាលោកច្បាស់ថា ពាក្យថា "បងជាទីគោរព" នេះ ច្បាស់ជា នួន ជា លោកសំអាងលើកាលបរិច្ឆេទ ឬក៏លោកសំអាងលើអ្វី?

[១៤:១០:០៦]

**ឆ៖** ខ្ញុំសំអាងលើកាលបរិច្ឆេទដែលខ្ញុំសរសេរពីខាងក្រោមនេះ ១០-១១-៧៧ នេះឯកសារនេះ វាចេញពីខ្ញុំ ខ្ញុំស៊ីញ៉េនៅថ្ងៃហ្នឹង។

**ស៖** សូមអរគុណ។ សូមលោកអានចំណារនៅក្នុងប្រអប់មួយទៀត នៅខាងឆ្វេងខាងលើ ប្រអប់ពណ៌ក្រហម។

**ឆ៖** "ជូន បងនួន មួយច្បាប់ ១១-១១-៧៧"។

**ស៖** លោកបានជម្រាបអង្គជំនុំជម្រះនៅក្នុងសក្ខីកម្ម លោកថា ចំណារនេះជារបស់ សុន សេន តើត្រូវឬទេ?

**ឆ៖** អរគុណ។ ត្រឹមត្រូវ។

[១៤:១១:៤៥]

**ស៖** ហើយរឹង កាលបរិច្ឆេទនោះ គឺមួយថ្ងៃបន្ទាប់ពីចំណាររបស់លោក។ តើមែនឬទេ?

**ផ៖** អរគុណ។ មែន!

**ស៖** តើលោកច្បាស់ដែរឬទេ ថាឯកសារនេះមិនត្រូវបានបញ្ជូនទៅ សុន សេន នោះដោយលោកផ្ទាល់? ហើយលោកប្រាកដថា ចំណារខាងក្រោមនេះ គឺបញ្ជូនទៅ-- មិនបញ្ជូនទៅ សុន សេន នោះបាទ?

**ផ៖** អរគុណ។ ខ្ញុំច្បាស់ទាំងអស់។ ចំណាររបស់ខ្ញុំជូនទៅបងនួន ក៏ប៉ុន្តែចំណារខាងលើក្នុងប្រអប់ខាងលើ គឺជាអក្សររបស់បង សុន សេន។

**ស៖** សូមលោកពន្យល់តុលាការ ឬក៏ពន្យល់ខ្ញុំ។ ហេតុអ្វីបានជាច្បាប់ចម្លងនៃចម្លើយសារភាពនេះ គឺត្រូវតែបញ្ជូនដោយ សុន សេន ទៅ នួន ជា នៅពេលដែលលោកនិយាយថា ចម្លើយសារភាពទាំងអស់ បន្ទាប់ពី១៥-- ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ហ្នឹង គឺទាំងអស់ត្រូវជូនទៅឲ្យ នួន ជា។ ហេតុអ្វីក៏គាត់ត្រូវទទួលចម្លើយសារភាព ដែលគាត់បានរួចជាស្រេចទៅហើយនោះ?

[១៤:១៣:១៧]

**ផ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំស្ដាប់អំមិញ គឺមេធាវីទាមទារឲ្យខ្ញុំពន្យល់។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពន្យល់ដូចតទៅ៖

ខ្ញុំ ក្រោយពីដាច់ពី សុន សេន ក្នុងការធ្វើការងារទល់មុខជាមួយគ្នាមក ខ្ញុំពិតជានៅមាន ការទាក់ទងជាមួយនឹងគាត់តាមតេអូ នេះបញ្ហាមួយ។ ក៏ប៉ុន្តែឯកសារនេះ មិនមែនមានតែមួយសន្លឹកនេះទេ ដែលចុះថ្ងៃ១១ ខែ១១ ៧៧។ ហើយតួនាទី របស់គាត់ សុន សេន គឺអានឯកសារដើម្បីរាយការណ៍ជូនខាងលើ។

ដូច្នេះនៅពេលនុ៎ង! គាត់មកប្រជុំនៅភ្នំពេញ ខ្ញុំជឿអ៊ីចឹង បាន១ជាចំណារនេះ តាមខ្ញុំចាំនៅក្នុងសំណុំរឿងលេខ០០១ មានចំណារ សុន សេន មួយចុងក្រោយគេបំផុត គឺថ្ងៃ២៥ ខែ១១ ៧៧។ ចាប់ពីពេលនោះមក ខ្ញុំអត់មានឃើញចំណារ សុន សេន ទៀតទេ។ ដូច្នេះ ខ្ញុំសរុបមក ក្រោយពីបែកពីខ្ញុំទៅ សុន សេន នៅចុះឡើងមកធ្វើការជាមួយ ប៉ុល ពត។ ឯកសារស-២១ គាត់នៅមើលតទៅទៀត តាមភារកិច្ចចាត់តាំងនៅថ្ងៃ៩ តុលា ១៩៧៥ រហូតដល់ថ្ងៃ២៥ ខែ១១ ៧៧ ទើប សុន សេន គាត់រវល់នឹងសមរភូមិមុខពេក ខ្ញុំឃើញ អត់ឃើញមានឯកសារអ៊ីស៊ីញ៉េបែបនេះទេ។ នេះខ្ញុំសូមពន្យល់អ៊ីចឹង។

[១៤:១៥:១១]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន លោកចៅក្រម ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារមួយទៀត គឺចម្លើយសារភាពដែលខ្ញុំបានបញ្ជាក់ជូនសាក្សីកាលពីខាងដើមដែរ គឺនៅថ្ងៃទី២៩ ខែមីនា ឯកសារ D43/4 ហើយនិងឧបសម្ព័ន្ធ២៦ ខ្មែរ ERN 00173049។ ហើយសូមអនុញ្ញាតុលាការដាក់បង្ហាញនៅលើអេក្រង់ ហើយនិងស្នើសុំឲ្យយកឯកសារលើក្រដាស ជូនសាក្សីពិនិត្យផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវី ទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច តើលោកចាំថា លោកបានឃើញឯកសារនេះទេ នៅថ្ងៃទី២៩ ខែមីនា កន្លងទៅនេះបាទ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំបានឃើញ។

**ស៖** សូមលោកអានចំណារនៅក្នុងប្រអប់ក្រហមខាលើ ខាងឆ្វេងដៃនេះជូនតុលាការ និងខ្ញុំស្តាប់មើល៍។

**ឆ៖** អរគុណ។ ខ្ញុំសូមអានជូនដូចតទៅ "ខាងសង្គមកិច្ចដោះស្រាយអស់ហើយ"។

[១៤:១៧:២៤]

**ស៖** នៅថ្ងៃទី២៩ ខែមីនា លោកក៏បានបញ្ជាក់ដែរថា លោកស្គាល់អក្សរដៃនេះ។ តើអក្សរនេះជាអក្សររបស់អ្នកណា តាមដែលលោកស្គាល់លោកចាំនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អក្សរនេះគឺពិតជាអក្សរ បងនួន។

**ស៖** ឌុច នេះមិនមែនជាអ្វីដែលលោកប្រាប់ទៅចៅក្រមស៊ើបអង្កេតទេ នៅពេលដែលចៅក្រមសួរលោកនោះ តើលោកចាំទេលោកឆ្លើយ នៅក្នុងឯកសារ D95, ERN ភាសាអង់គ្លេស 00205159 ERN ខ្មែរ 00205150 ហើយបារាំង 00205167។ តើលោកចាំទេពីអ្វីដែលលោកជម្រាបសហចៅក្រមស៊ើបអង្កេតទេ អំពីចំណារមួយនេះដែលខ្ញុំបង្ហាញនេះបាទ?

[១៤:១៨:៥០]

**ឆ៖** អរគុណ។ ដំបូងមែន ខ្ញុំច្រឡំ ថាជាចំណាររបស់បង សុន សេន។ ដំបូង ខ្ញុំច្រឡំមែន ហើយដល់ក្រោយមក ខ្ញុំដូចជាមានឱកាសបានជម្រាបសហចៅក្រមស៊ើបអង្កេតម្តងទៀត ដើម្បីច្បាស់លាស់ មិនមែនតែម្តងហ្នឹងស្រេចទេ ដូចមានខ្ញុំជម្រាបបញ្ជាក់ចៅក្រមស៊ើបអង្កេតម្តងទៀត។

[១៤:១៩:២៥]

**ស៖** តើលោកបានកែតម្រូវចម្លើយរបស់លោកទេ នៅពេលដែលលោកដឹងថា មានការភ័ន្តច្រឡំ ជាពិសេសនៅខែកញ្ញា ឆ្នាំ១៩៧៨ ដែលថា លោកបានធ្វើការជាមួយ នួន ជា ហើយមិនមែន សុន សេន ទេនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការដែលកែតម្រូវលើកក្រោយនេះ មិនមែនដោយយោងលើកាលបរិច្ឆេទទេ នេះតាមខ្ញុំចាំ គឺយោងលើអក្សរហ្នឹងតែម្តង។ បង សុន សេន របស់ខ្ញុំ មិនដែលសរសេរ "ហើយ" របៀបនេះទេ។ មើលចុះ ចំណាររបស់គាត់ គ្រប់ចំណារ មិនដែលបង សុន សេន ណាសរសេរ "ហើយ" របៀបនេះទេ។

**ស៖** លោកបានចំណាយពេលជាច្រើននៅក្នុងផ្នែកស៊ើបការណ៍ តើលោកបានទទួលការបណ្តុះបណ្តាលអ្វីពីការសម្គាល់ ឬក៏ការពិនិត្យលើចំណារផ្ទាល់ដៃទេបាទ?

**ឆ៖** អរគុណ។ ខ្ញុំគ្មានបានទទួលការបណ្តុះបណ្តាលឯកទេសពីណាមកទេ។

[១៤:២០:៥៨]

**លោក ម៉ែខល ផេសមិន៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតបង្ហាញជូនចម្លើយសារភាពមួយទៀត។ ខ្មែរ 00174726 ឯកសារបកប្រែអង់គ្លេសនៅក្នុង ERN 00629418 បារាំង ERN គឺ 00280058 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មានឯកសារជាលាយលក្ខណ៍អក្សរទេ? មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារលាយលក្ខណ៍អក្សរពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

[១៤:២២:០៤]

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ខ្ញុំមានក្រឋនៃចម្លើយសារភាពដែលជាផ្នែកមួយ ខ្ញុំគ្រឋដណ្តប់។ ខ្ញុំដាក់បាំងចំណារដែលខ្ញុំរក្សាទុកសិននៅក្នុង នៅលើក្រឋចម្លើយសារភាព។

សំណួរខ្ញុំគឺខ្ញុំសួរដោយមើលចំណារផ្ទាល់ដៃនោះទេ។ ឌុច តើលោកស្គាល់ឯកសារមួយនេះដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថាឯកសារដែលឲ្យមកខ្ញុំនេះ ខុសនឹងឯកសារដែលនៅលើអេក្រង់។ តើលោកសួរអំពីឯកសារណាមួយ?

[១៤:២២:៥២]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបង្ហាញឯកសារណាមួយ ដែលលោកចង់សួរដេញដោលចំពោះសាក្សីនូវសំណួរដំបូងនេះ? ពីព្រោះឯកសារនៅដៃសាក្សី ហើយនិងឯកសារដែលដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ខុសគ្នា ខុសគ្នាលើការបាំង។

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន បើវាមាន-- ឯកសារត្រឹមត្រូវនោះ គឺបង្ហាញនៅលើអេក្រង់ ហើយលោកប្រធានបាទ។ ហើយខ្ញុំយល់ថានេះជាឯកសារដែលត្រូវ ដែលខ្ញុំសួរទៅ ឌុច ឲ្យគាត់ឆ្លើយបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:២៣:៥៦]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមិនដឹងថាគោលបំណងរបស់មេធាវីការពារដាក់បង្ហាញឯកសារដោយលុបកំបាំងខ្លះ ពីព្រោះឯកសារនេះត្រូវបានដាក់ក្នុងសំណុំរឿងហើយ។ ហើយបើសិនជាគាត់ចង់បានការពន្យល់ ហើយដោយមានការកែតម្រូវដែលថាសាក្សីបានមួយច្បាប់អ៊ីចឹងឲ្យគាត់ឆ្លើយដោយលាក់កំបាំងខ្លះអ៊ីចឹង គឺថាតើខ្ញុំសូមស្នើតុលាការថា សូមធ្វើម៉េចឲ្យបង្ហាញទាំងស្រុងជាជាងលាក់កំបាំងខ្លះបែបនេះបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៤:២៤:៤៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគាំទ្រទាំងស្រុងទៅលើការសង្កេតរបស់សហព្រះរាជអាជ្ញា។ យើងមិនមែនជាការទស្សន៍ទាយស្មានទេ យើងសុំឲ្យបង្ហាញឯកសារទាំងស្រុង កុំឲ្យមានលាក់បាំងផ្នែកណាមួយនៃឯកសារអ៊ីចឹង។ ហើយខ្ញុំគិតថាមិនអាចមានការកែប្រែឯកសារដើម្បីតែការពារអ្នកណាម្នាក់នោះទេ។ មិនមែនជាករណីនៅទីនេះទេ។ ដូច្នេះសូមមេត្តាបង្ហាញឯកសារនេះទាំងមូលតែម្ដងកុំឲ្យមានការលាក់បាំងដូច្នេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ផេសមិន!

[១៤:២៥:១៦]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំនឹងបង្ហាញឯកសារនេះទាំងស្រុង។ គោលបំណងនៃការដាក់បែបនេះ គឺចង់បង្ហាញតុលាការនិងភាគីទាំងអស់នៅក្នុងសាលសវនាការផងដែរ។ នៅពេលចំណារហ្នឹងធ្វើឡើងនៅពេលណា? ហើយតើសាក្សីបានឃើញចំណារនៅពេលណា? ហើយៗខ្ញុំនឹងបង្ហាញអំពីចំណារទីមួយ លាតត្រដាង ហើយនិងខ្ញុំសួរទៅលោកសាក្សី។ សាក្សី ថាតើឯកសារមើលទៅដូចនេះដែរឬទេ នៅពេលដែលគាត់បញ្ជូនទៅថ្នាក់លើរបស់គាត់នោះ? នេះសំណួរទីមួយ។ ហើយបន្ទាប់ទៅទៀត ខ្ញុំនឹងបង្ហាញអាកន្លែងផ្សេងទៀតនៃចំណារហ្នឹង ហើយនឹងសួរថា តើឯកសារនេះអ៊ីចឹងដែរឬទេ នៅពេលដែលលោកបង្ហាញទៅថ្នាក់លើរបស់លោក? ហើយចំណារផ្សេងៗទៀតនោះ គឺមិនទាន់មាននៅលើឯកសារនេះទេ នៅពេលដែលគាត់បញ្ជូនទៅ។ ហ្នឹងគោលបំណងខ្ញុំចង់បង្ហាញអ៊ីចឹង។ អ៊ីចឹង ដំបូងខ្ញុំសួរគាត់ថា តើលោកស្គាល់ឯកសារហ្នឹងទេ? ដើម្បីឲ្យលោកមានឱកាសនឹងឆ្លើយ។

[១៤:២៦:៣៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមជំទាស់ ខ្ញុំគិតថា យើងមិនអាចបង្ហាញឯកសារដោយលាក់បាំងផ្នែកណាមួយ ហើយបន្ទាប់មកបង្ហាញជាបន្តបន្ទាប់នោះទេ។ យើងមិនមែនជាការលេងល្បែងទស្សន៍ទាយអីនោះទេ។ ឯកសារ

យ៉ាងម៉េច គឺសូមឲ្យបង្ហាញអ៊ីចឹងតែម្ដងទៅ សូមកុំឲ្យមានការកែប្រែអីរបៀបនេះទៀត។

[១៤:២៧:០៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំព្យាយាមធ្វើម៉េចឲ្យមានសារប្រយោជន៍ដល់តុលាការ។ ខ្ញុំចង់បង្ហាញទៅលោកសាក្សី ហើយ និងលោកចៅក្រម លោកស្រីចៅក្រម អំពីរបៀបដែលថាឯកសារហ្នឹងវាចេញពីកន្លែងមួយទៅកន្លែងមួយហ្នឹង វាមានព័ត៌មានអ្វីខ្លះទៅតាមលំដាប់លំដោយកាលបរិច្ឆេទ គឺមិនធ្វើឲ្យមានការយល់ច្រឡំទេ ការបង្ហាញបែបនេះ។ ហើយខ្ញុំ ខ្ញុំនឹងបញ្ចប់ក្នុងរយៈពេលខ្លី ហើយនិងបង្ហាញ កាលណាទៅតាមជំហាននីមួយៗអំពីវិធីដែលឯកសារចេញពីបុគ្គលម្នាក់ទៅដល់បុគ្គលម្នាក់ទៀត ចេញពីបុគ្គលម្នាក់ទៀតទៅបុគ្គលទៀត ឲ្យឃើញខ្សែចង្វាក់ហ្នឹងទេ។ បាទ គឺមិនមែនអ្វីជាការ *ស្ពិចឃ្យូឡេតធីង* គឺជាការធ្វើសន្និដ្ឋានព្រាវនោះទេ។

[១៤:២៨:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៨:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា សេចក្ដីជំទាស់របស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជអាជ្ញាមានប្រសិទ្ធភាព។ មេធាវី នួន ជា ប្រសិនបើមានចេតនាក្នុងការដាក់ឯកសារនេះដេញដោលចំពោះមុខអង្គជំនុំជម្រះ ត្រូវបង្ហាញទាំងស្រុងនូវខ្លឹមសារដើម ដើម្បីឲ្យសាក្សីពិនិត្យបឋមជាមុន អំពីថាខ្លួនបានធ្លាប់ឃើញ ធ្លាប់បានអាន ធ្លាប់បានជួបនូវឯកសារនេះពីមុនមកដែរឬទេ បន្ទាប់មកទើបអាចតាំងសំណួរផ្សេងៗទៀតបាន។ បើពុំដូច្នោះទេ គឺអង្គជំនុំជម្រះសម្រេចឲ្យដកឯកសារនេះចេញ ហើយលោកអាចបន្តទៅនឹងសំណួរចំពោះបញ្ហាផ្សេងទៀត បន្ទាប់ពីនេះ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក ឌុច តើលោកឯកសារ ស្គាល់ឯកសារនេះទេ? លោកធ្លាប់បានឃើញពីមុនទេ?

[១៤:២៩:៥៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដករបាំងចេញឲ្យអស់ ឲ្យសាក្សីពិនិត្យមើលជាមុនសិនលើទម្រង់ឯកសារថាគាត់បានឃើញ បានមើល បានជួបប្រទះពីមុនដែរឬទេ? មិនអាចទុកផ្នែកណាមួយបានទេ បើទុកផ្នែកណាមួយ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យដេញដោលទេ ឲ្យលោកដេញដោលនូវបញ្ហាផ្សេង។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ឌុច តើលោកស្គាល់ឯកសារមួយនេះដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ស្គាល់។

**ស៖** សូមលោកអានចំណារៗផ្ទាល់ដៃនៅលើឯកសារនេះ។

**លោក ម៉ែខល ផេសមិន៖**

ហើយខ្ញុំមានឯកសារលើក្រដាសជូនលោកសាក្សី សូមអនុញ្ញាតលោកប្រធានជូនទៅលោកសាក្សីបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីមានហើយ មានឯកសារជាក្រដាសរួចហើយ សំខាន់លោកសួរត្រង់ចំណុចណាមួយឲ្យអាន ព្រោះមានចំណារច្រើនចំណុច។ លោកបញ្ជាក់ចំណុចផង ដើម្បីឲ្យច្បាស់លាស់ថា តើឲ្យសាក្សីហ្នឹងអាននៅត្រង់ចំណុច-- ចំណារត្រង់ចំណុចណាមួយនៃឯកសារ?

[១៤:៣០:៥៥]

**លោក ម៉ែខល ផេសមិន៖**

ខ្ញុំមានឯកសារទាំងស្រុងដែលមិនមានការកោសលុបនោះទេ។ គោលបំណងនៃការសួរនេះ គឺដើម្បីឲ្យលោកសាក្សីបានទាំងស្រុង។ ហើយសូមអនុញ្ញាតមន្ត្រីតុលាការ លោកប្រធានអនុញ្ញាតឲ្យយកជូនគាត់បាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ-- រដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ។

[១៤:៣២:២០]

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**សៈ** ឌុច តើលោកយល់ហើយអំពីចំណារមួយណាដែលខ្ញុំស្នើឲ្យលោកអាន តើមែនទេ? បាទ គឺចំណារមួយដែលជាចំណាររបស់លោកបាទ។

**លោក កាំង ហ្គេកអ៊ាវៈ**

**ឆៈ** អរគុណ។ ខ្ញុំសូមអានដូចតទៅៈ "បងជាទីគោរព! ១) កម្លាំងដែលវាវាយការណ៍ក្នុងនេះសុទ្ធតែពួកតំបន់២២ ទាំងពួកនៅក្នុងជួរបដិវត្តន៍ ទាំងខ្សែកុក ម៉េងតាំង ចាស់របស់ពាវាំង។ ២) កម្លាំងខ្ពស់បំផុត ដែលវានិយាយគឺអា ទុំ។ ៣) មិត្ត អ៊ាង ស៊ីផេង វានិយាយថាជាអ្នកបដិវត្តន៍។ និយាយជាចំហាតែម្តង។ ដោយគោរព។ ឌុច ១៥-១០-៧៧"។

[១៤:៣៣:៤០]

**សៈ** សូមអរគុណ។ បាទ ចង់សួរលោកថា "បងជាទីគោរព" នៅកន្លែងនេះ តើលោកសរសេរសំដៅទៅអ្នកណា?

**ឆៈ** អរគុណ។ ឯកសារនេះខ្ញុំសរសេរនៅថ្ងៃ១៥ ខែ១០ ១៩៧៧។ ខ្ញុំសរសេរសំដៅទៅបងនួន។

**សៈ** សូមលោកអានចំណារផ្ទាល់ដៃដែលមានកាលបរិច្ឆេទ ១៧ តុលា ឆ្នាំ១៩៧៧ ដែលមានគូសក្រហម-- ប្រអប់ក្រហមនេះបាទ។

[១៤:៣៤:៣១]

**ឆៈ** អរគុណ។ "១) អាចសំខាន់ដែរ។ ២) អានេះខ្សែអាណិកជនចិន បកប្រែ។ ខ្ញុំមិនទាន់បានអានទេ។ សូមជូនបងអានមុន។ ខៀវ"។

[១៤:៣៥:០៤]

**សៈ** បាទ សូមថាកាលបរិច្ឆេទផង។

**ឆៈ** អរគុណ។ ១៧ ខែ១០ ១៩៧៧។

**សៈ** បាទ សួរថា ខៀវ ជាអ្នកណា?

**ឆៈ** អរគុណ។ ខៀវ គឺបង សុន សេន។

**សៈ** តើលោកយល់ស្របជាមួយខ្ញុំទេ កាលបរិច្ឆេទនៅកន្លែងនេះ គឺពីរថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃចំណារផ្ទាល់ដៃរបស់លោក។ តើលោកឯកភាពដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំឯកភាព។

**ស៖** តើលោកប្រាកដទេ ដែលថាចម្លើយសារភាពនេះ គឺបានបញ្ជូនទៅ នួន ជា?

**ឆ៖** ប្រាកដ។

**ស៖** មានចំណារមួយទៀត នៅខាងឆ្វេង ខាងលើ។ យើងមើលទៅមិនច្បាស់ទេ ក៏ប៉ុន្តែប្រហែលជាលោកអាចជួយអានបាន។ តើលោកអាចបានដែរឬទេ សូមជួយអាន?

**ឆ៖** អរគុណ។ ខ្ញុំសូមអានដូចតទៅ៖ "ពិសេសខាងសមមិត្តខៀវ ទាក់ទងបូព៌ា"។

[១៤:៣៦:៥៨]

**ស៖** តើអ្នកណាគេជាអ្នកសរសេរចំណារនេះ?

**ឆ៖** អរគុណ។ យោងតាមខ្លឹមដែល សុន សេន គាត់សរសេរ សូមជូនបងអានមុន។ ហើយយោងតាមខ្លឹមសារនៃបទបញ្ជាពិសេស ខាងសមមិត្ត ខៀវ ទាក់ទងបូព៌ា។ ដូច្នេះ ខ្ញុំអាចសន្និដ្ឋានបានថា ពិសេសខាងសមមិត្ត ខៀវ ទាក់ទងខាងបូព៌ា ដូច្នេះ ខ្ញុំអាចសន្និដ្ឋានបាន គឺជាចំណាររបស់ ប៉ុល ពត។

**ស៖** នេះ ជាអ្វីដែលលោកបានជម្រាបសហចៅក្រមស៊ើបអង្កេត គឺថា សុន សេន បញ្ជូនទៅ ប៉ុល ពត ហើយបន្ទាប់មក ប៉ុល ពត បញ្ជូនត្រឡប់មកឲ្យសុន សេន វិញ។ តើនរណាគេបញ្ជូន ហើយនិងសរសេរចំណារនោះ? ហើយចំណារនោះ មានអក្សរតូចផងដែរ នៅខាងឆ្វេងដែលចុះថ្ងៃ១១/១១/៧៧ តើលោកអាចបានទេ ចំណុចហ្នឹង?

**ឆ៖** អរគុណ។ "ជូនហើយ ១១/១១/៧៧"។

[១៤:៣៨:៥២]

**ស៖** តើលោកស្គាល់អក្សរហ្នឹងដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំគិតថា ពីលើកមុន ខ្ញុំបកស្រាយខុសដែរ។ ពីលើកមុនខ្ញុំបកស្រាយថា ចំណារនេះ ជាចំណារ សុន សេន ដោយយោងលើថ្ងៃ១១ ខែ១១ ៧៧ សុន សេន ស៊ីញ៉េច្រើនណាស់។ ក៏ប៉ុន្តែឥឡូវដល់ឃើញអក្សរហើយ ខ្ញុំចាប់អារម្មណ៍ផ្សេងទៅវិញ។ ខ្ញុំសង្ស័យចំណារនេះ ចំណារបងនួន។ ដូច្នេះ ខ្ញុំចូលដល់លក្ខណៈមិនច្បាស់លាស់ហើយ។

**ស៖** ប្រសិនបើខ្ញុំយល់លោកមិនខុសនោះទេ គឺកំពុងតែ-- លោកកំពុងតែកាល់កែចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតកាលពីលើកមុន ដែលលោកបាននិយាយថា ចំណារនេះ គឺរបស់ សុន សេន។ ដោយលោកផ្អែកទៅលើការបរិច្ឆេទនៅក្នុងចំណារនេះ អ៊ីចឹងបានន័យដែរឬទេ

ថាលោកកែទៅលើអ្វីដែលលោកនិយាយនៅពេលចៅក្រម-- នៅក្នុងអំឡុងចៅក្រមស៊ើបអង្កេត?

[១៤:៤០:០៨]

**ឆ៖** អរគុណ។ ខ្ញុំបានបញ្ជាក់ហើយ ថាពេលដែលជាមួយសហចៅក្រមស៊ើបអង្កេត ខ្ញុំរាយ-ការណ៍ជូនគាត់ថាជាចំណាររបស់បងខៀវ សុន សេន បើតាមកាលបរិច្ឆេទ និងតួនាទីរបស់ សុន សេន ដែល ប៉ុល ពត ប្រគល់ឲ្យ។

**ស៖** ឌុច ចំណុចហ្នឹង គឺលោកប្រាប់ចៅក្រមអង្កេតដូច្នោះ ក៏ប៉ុន្តែនៅពេលនេះ លោកប្រាប់អង្គជំនុំជម្រះថាជាចំណាររបស់លោក នួន ជា ដោយផ្អែកទៅលើថ្ងៃ១១/១១/៧៧ តើលោកពិតជានិយាយចង់បានន័យថាអ៊ីចឹងដែរឬទេ? សូមលោកជួយពន្យល់។

**ឆ៖** អរគុណ។ សូមជម្រាបលោកប្រធាន ដោយឃើញអក្សរ "ហើយ" នេះ ខ្ញុំចាប់អារម្មណ៍ថាជាចំណាររបស់បង នួន ជា ទៅវិញ។ ដូច្នេះខ្ញុំស្ទាក់ស្ទើរហើយពេលនេះ ព្រោះមិនមែនជាចំណាររបស់ខ្ញុំ ជាចំណាររបស់ខាងលើ។ ដូច្នេះ ខ្ញុំសូមនិយាយថា ពេលនេះខ្ញុំស្ទាក់ស្ទើរ រារែក មិនដឹងជាកំណត់យ៉ាងម៉េចទេ។ ខ្ញុំគ្រាន់តែចាំបានថា ជាមួយសហចៅក្រមស៊ើបអង្កេត ខ្ញុំរាយការណ៍ជូនគាត់ថាជាចំណាររបស់បង សុន សេន។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១៤:៤១:៤៦]

**ស៖** ឌុច លោកជម្រាបចៅក្រមស៊ើបអង្កេតថា ចម្លើយសារភាពបានបញ្ជូនទៅថ្នាក់លើរបស់លោក ហើយមិនដែលបញ្ជូនត្រឡប់មក ស-២១ វិញទេ។ តើពិតជាដូច្នេះដែរឬទេ លោកបាននិយាយអ៊ីចឹង?

**ឆ៖** ត្រឹមត្រូវ!

**ស៖** ដើម្បីបញ្ជាក់ឲ្យបានកាន់តែច្បាស់ កុំឲ្យមានការយល់ច្រឡំគ្នា នៅពេលដែលលោកធ្វើការនៅ ស-២១ លោកបញ្ជូនចម្លើយ បញ្ជូនឯកសារទៅថ្នាក់លើ ដោយមិនមានចំណាររបស់បុគ្គលផ្សេងនោះទេ ហើយលោកក៏មិនដែលឃើញចំណារ ដែលធ្វើឡើងដោយមេរបស់លោកផងដែរ រហូតមកដល់ពេលដែលគេបង្ហាញឯកសារ ឃើញចំណារទាំងអស់នេះ ទើបលោកបានដឹង។ តើខ្ញុំធ្វើការសង្ខេបដូច្នេះត្រឹមត្រូវដែរឬទេ អ្វីដែលលោកចង់បានន័យហ្នឹង?

[១៤:៤៣:១២]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារ ស-២១ ដែលខ្ញុំបញ្ជូនទៅលើ មាន

តែចំណារខ្ញុំបន្ថែមពីលើអក្សររបស់អ្នកសួរ។ នេះច្បាស់លាស់ណាស់។ នៅពេលដែលខ្ញុំបញ្ជូនទៅ ខ្ញុំអត់បានទទួលឯកសារដែលមានចំណាររបស់ខាងលើត្រឡប់មក ស-២១ វិញទេ នេះក៏នៅតែច្បាស់លាស់។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា សេចក្ដីសរុបរបស់ ផេសមិន អំមិញខ្វះបន្តិច។ នេត ថាយ៉រ នៅពេលដែលវាទៅជួបខ្ញុំរវាងខែមេសា ១៩៩៩ វាយកចម្លើយ គង់ គៀន ហៅ អ៊ឹង វ៉េត ទៅបង្ហាញខ្ញុំ ដើម្បីសួរខ្ញុំថាតើអក្សរអ្នកណា អីអ្នកណា? ពេលនុ៎ង ដែលខ្ញុំចាប់ផ្ដើមដឹងថា ឯកសារដែលផ្ញើទៅខាងលើ ខាងលើចារ។ មានទាំងអក្សរខ្ញុំ មានទាំងអក្សរនែ៎! សុន សេន មានទាំងអក្សរ នួន ជា នៅនុ៎ង។ នេះជាលើកទីមួយហើយ ដែលខ្ញុំឃើញឯកសារ ស-២១ ដែលមានចំណារថ្នាក់លើ។ នេះខ្ញុំសូមបញ្ជាក់សាឡើងវិញប៉ុណ្ណេះ។

**ស៖** ដើម្បីឲ្យច្បាស់ទៅលើកាលបរិច្ឆេទ តើនៅក្នុងពេលណា ឆ្នាំណាដែរ ដែលលោកចាប់ផ្ដើមឃើញចំណារដែលចារដោយមេរបស់លោក?

**ឆ៖** អរគុណ។ នៅខែមសា ១៩៩៩។

[១៤:៤៥:២៥]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំសូមចូលទៅដល់ចម្លើយសារភាពមួយទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន មុនពេលដែលមេធាវីចូលទៅដល់ចំណុចមួយទៀត នៅពេលនេះថាតើលោកសាក្សីនោះ គឺលើកឡើងអំពីចម្លើយមួយណា? ហើយលោកមេធាវីនោះបញ្ជាក់ទៅលើចម្លើយសារភាពមួយណាដែរ ដើម្បីឲ្យយើងបានដឹងច្បាស់ ថាតើគាត់នឹងលើកឡើងទៅលើចំណុចណា?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំដូចជាមិនច្បាស់ដែរ។

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំកំពុងតែនិយាយអំពីចម្លើយមួយ ដែលលោកយកមកតទល់ជាមួយនឹងសាក្សី ដែលថាគាត់សាក្សីបានឆ្លើយផ្សេងនៅពេលដែលជាមួយនឹងចៅក្រមស៊ើបអង្កេត ហើយនៅពេលនេះឆ្លើយផ្សឹងទៅ

វិញ។ ដូច្នេះ តើឯកសារចម្លើយចៅក្រមស៊ើបអង្កេតនោះមួយណាដែរ វាមានលេខឯកសារអ្វីដែរ?

[១៤:៤៦:៣១]

**លោក ម៉ៃខល ផេសមិន៖**

សូមអធ្យាស្រ័យ ខ្ញុំនឹងផ្ដល់ ERN ជាភាសាអង់គ្លេសគឺ អង់គ្លេស 0080--

**អ្នកបកប្រែ៖**

បាទ លោកប្រធាន សូមឲ្យគាត់ជួយបញ្ជាក់ ERN ជាភាសាអង់គ្លេសឡើងវិញ។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់លេខឯកសារឡើងវិញ!

[១៤:៤៦:៥៧]

**លោក ម៉ៃខល ផេសមិន៖**

អង់គ្លេសគឺ 00398164 ខ្មែរគឺ 00398157 បារាំងគឺ 00398171។ ឯកសារលេខ D225។ សូមអធ្យាស្រ័យដែលខ្ញុំមិនបានផ្ដល់លេខ អត្តសញ្ញាណឯកសារនេះ គឺនៅក្នុងឯកសារនោះ សាក្សីបានឆ្លើយថា ចំណារដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ សរសេរដោយ សុន សេន។

ដោយខ្ញុំនៅពេលនេះ មានពេលវេលា ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារមួយទៀត D43/IV/77 ខ្មែរ ERN គឺ 0017--

**ប្រធានអង្គជំនុំ៖**

សម្រាកសិនទៅ! ដល់ពេលត្រូវសម្រាកហើយ អង្គជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំង អញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំ ហើយនិងឲ្យអញ្ជើញគាត់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅម៉ោងបីដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៤៩ នាទី ដល់ម៉ោង ១៥:០៨ នាទី)*

[១៥:០៩:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសនាការ និងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរ បាទមួយចំនួនទាក់ទងទៅនឹងចម្លើយសារភាពមួយចំនួន ហើយនិងខ្ញុំពិនិត្យចំពោះសាក្សីនេះឲ្យបានលឿនជាងមុន។ ទីមួយ គឺD43/IV/77 ខ្មែរ ERN 00174764 ហើយខ្ញុំជូន ERN ដល់អ្នកបកប្រែដែរ គឺតើចាំបាច់ដែរឬទេ? ERN អង់គ្លេស 00223909 បារាំង 00280059។

សូមអនុញ្ញាតតុលាការដាក់បង្ហាញលើអេក្រង់ផងដែរបាទ។

[១៥:១០:៤០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់បញ្ចាំងឯកសារអម្បាញ់មិញនេះតាមសំណើសុំរបស់មេធាវី ហើយនិងទទួលយកឯកសារជាក្រដាសពីមេធាវីដាក់ជូនសាក្សីពិនិត្យភ្លាម។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច សូមលោកចំណាយពេលបន្តិចមើលលើឯកសារនេះ ហើយខ្ញុំនឹងសួរលោក។ ហើយសំណួរទីមួយ សួរថាតើលោកស្គាល់ឯកសារនេះដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្គាល់ឯកសារនេះ។

[១៥:១១:៣៧]

**ស៖** សូមអរគុណ។ បាទនៅក្នុងចម្លើយសារភាពនេះ គឺថាមានព័ត៌មានជាពីរ ដោយមិនចាំបាច់អានទាំងអស់ទេ ប៉ុន្តែសូមឲ្យអានទាំងស្រុងនូវចំណារដែលសរសេរពណ៌ក្រហម នៅបាទ ខាងហក--ពណ៌ក្រហមនៅខាងលើ ហើយនិងពណ៌ក្រហមទាំងអស់ខាងក្រោម រួមទាំងកាលបរិច្ឆេទនោះផងដែរ។

**ឆ៖** អរគុណ។ ពណ៌ក្រហមខាងលើ៖ “យកហើយ កំណត់ហេតុ”។ ពណ៌ក្រហមខាងក្រោម “បងជាទីគោរព! បាតុភាពដំបូងដែលនាំឲ្យចាប់ អាហ្វូង នេះ គឺវាតែងទាក់ទងកម្លាំង--

**ស៖** សូមអភ័យទោសលោកសាក្សី មិនចាំបាច់ទាំងអស់ទេអាខាងក្រោមនេះ។ ខ្ញុំចង់ឲ្យអានខាងលើ គឺថាលោកបានអានហើយ គឺថា “បងជាទីគោរព” នេះលោកបានអាន ហើយខាងក្រោមនេះបីបន្ទាប់នេះ ដែលមានមួយ, ពីរ, បីខាងក្រោម រាប់ពីកាលបរិច្ឆេទមកខាងលើបាទ។

[១៥:១៣:០៩]

**ឆ៖** អរគុណ។ “ដោយគោរព ឌុច ៩/១១/៧៧”។

**ស៖** តើនេះជាអក្សររបស់លោកមែនឬទេ?

**ឆ៖** អរគុណ។ នេះជាអក្សរដៃរបស់ខ្ញុំ។

**ស៖** តើអ្នកណាជា “បងជាទីគោរព” នៅកន្លែងនេះបាទ ដែលលោកធ្វើចំណារនេះ ចំណារជូនទៅបងជាទីគោរពនោះ គឺបងមួយណា?

**ឆ៖** អរគុណ។ ចំណារបងជាទីគោរពនេះ គឺជូនបង-- គឺខ្ញុំជូន បងនួន។

**ស៖** សូមលោកអានចំណារផ្ទាល់ដៃ ប៉ុន្តែសរសេរជាពណ៌ខ្មៅ។ បាទ សូមឲ្យលោកអានចំណារនេះទាំងស្រុងបាទ។

[១៥:១៤:២០]

**ឆ៖** អរគុណ។ “ចម្លើយនេះទាក់ទងខាងអគ្គិសនី ផ្នែកខាងសមមិត្ត ដន។ ដន ហ្នឹង វន មិនដឹងទេ។ ពីរ សល់ខ្សែ អាសុខ (ក្រុង) ដែលបន្តធ្វើសកម្មភាពប្រឆាំង មានរកឃើញគ្រប់បែកនៅផ្ទះវា”។ ពីរម៉ាត់ខាងដើម ខ្ញុំអានមិនទាន់ដាច់ទេ។ ឃើញតែបីៗ “ចម្លើយចាប់បីប្អូននាក់ទៀត ជាខ្សែអាសុខដដែល-- អ៎ ជាខ្សែ អាសុខ ដែលយើងមិនទាន់មានវិធានការ។ ឌៀវ ១០/១១/៧៧”។

**ស៖** សូមអភ័យទោស! ខ្ញុំដូចជាចាប់មិនទាន់បានគ្រង់មានហត្ថលេខាមួយ តើហត្ថលេខារបស់អ្នកណា?

**ឆ៖** អរគុណ។ ហត្ថលេខានេះ ហត្ថលេខារបស់បង សុន សេន។

[១៥:១៦:០៨]

**ស៖** សូមអរគុណ។ កាលបរិច្ឆេទគឺមួយថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទរបស់លោក តើលោកអាចពន្យល់តុលាការបានទេ ថាតើហេតុអ្វីបានជាឯកសារនេះបង្ហាញថា ត្រូវបង្ហាញទៅ សុន សេន នៅពេល

ដែលកាលបរិច្ឆេទនេះបង្ហាញបែបនេះ គឺដែលហេតុថា លោកបញ្ជាក់ថា សុន សេន លែងនៅជាមេលោកហើយ បន្ទាប់ពីថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ទៅនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះ ខ្ញុំបានពន្យល់អំមិញគ្រួសៗហើយ ពេលនេះខ្ញុំគិតឃើញថា ខ្ញុំក៏គប្បីចាំបាច់បញ្ជាក់បញ្ហានេះឲ្យច្បាស់ដែរ។ ពីថ្ងៃ១៥ ខែសីហា ១៩៧៧ សុន សេន លែងហៅខ្ញុំទៅធ្វើការមួយទល់មុខ មួយម៉ែត្រ ឬកន្លះម៉ែត្រពីគ្នាទៀតហើយ។ ខ្ញុំចាប់ផ្ដើមធ្វើការងារជាមួយនឹង បងនួន ម្ដង។ អង្គុយទាល់មុខគ្នាកន្លះម៉ែត្រ ទៅមួយម៉ែត្រ។ នេះជាក់ស្ដែង បញ្ហានេះ។ ទីពីរ ខ្ញុំសូមបញ្ជាក់ថា ក្រោយពីបង សុន សេន ដាច់ពីខ្ញុំទៅ ខ្ញុំនៅមានទាន់ទងនឹងគាត់ ប្អូនដប់ថ្ងៃ កន្លះខែ ឬក៏យូរ យ៉ាងយូរមួយខែម្ដង តាមរលកអាកាស នេះទីពីរ។ គាត់ណែនាំមកជាប់។ ហើយទីបី ខ្ញុំគ្មានអីត្រូវសរសេរឯកសារណាផ្ញើទៅបង សុន សេន ទេ ព្រោះគាត់ទៅអ្នកលឿង ទៅនៅប្រចាំការនៅអ្នកលឿង បោះទីតាំងថ្មីនៅអ្នកលឿង។ អ៊ីចឹងហើយបានជាខ្ញុំនិយាយថា ឯកសារនេះ ខ្ញុំជូនទៅ បងនួន ព្រោះជាភារកិច្ចរបស់ខ្ញុំត្រូវតែជូនទៅគាត់ឯកសារ តាមអ្នកណាក៏ដោយ គឺពិតជាជូនទៅ បងនួន។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[១៥:១៨:២៤]

ក៏ប៉ុន្តែនៅក្នុងសវនាការ ០០១ ខ្ញុំឃើញចំណារ បងខៀវ ភាគច្រើនដែរ ដែលសរសេរថ្ងៃ១១ ខែ ១១ ឆ្នាំ១៩៧៧។ ពេលនោះ ខ្ញុំដូចជាមិនទាន់បានសរុបសន្និដ្ឋានជូនអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ០០១ នៅឡើយទេ។ ក៏ប៉ុន្តែជំនាន់នុ៎ងដែរ ខ្ញុំនៅចាំថា ឯកសារចុងក្រោយបំផុតដែលមានស៊ីញ៉េបង សុន សេន គឺបងខៀវ នេះ គឺនៅថ្ងៃទី២៥ ខែ១១ ១៩៧៨-- អ៎!៧៧។ ដោយសារការឃើញកាលបរិច្ឆេទបន្តមកអ៊ីចឹង ហើយគិតដល់កាលបរិច្ឆេទដែល ប៉ុល ពត គាត់ចាត់តាំង សុន សេន ឲ្យទទួលការងារសន្តិសុខ។ ខ្ញុំគិតថា យើងអាចសន្និដ្ឋាន-- ខ្ញុំសូមសន្និដ្ឋានបណ្ដោះអាសន្នពេលនេះជូនតុលាការថា បងខៀវ ត្រូវ ប៉ុល ពត ចាត់ទាំងឲ្យរៀបចំកិច្ចការសន្តិសុខ ដើម្បីសម្រាលបន្ទុកគាត់ចាប់តាំងពីថ្ងៃ៩ ខែតុលា ១៩៧៧ ហើយដល់គាត់ចេញទៅនៅអ្នកលឿងក៏ដោយ ក៏ពេលគាត់មកពេលប្រជុំនៅជាមួយ ប៉ុល ពត ម្ដងៗ គាត់ត្រូវបង្ហើយការងារនេះ។

[១៥:១៩:៤៧]

ដូច្នេះហើយ បានខ្ញុំឃើញឯកសារនេះរហូតដល់ថ្ងៃ២៥ ខែ១១ ១៩៧៧។ ហើយខ្ញុំអាចគិតថា ក្រោយនោះ មិនមានចំណារជាលាយលក្ខណ៍អក្សរអីសុំយោបល់ បងប៉ុល អីទៀតទេ។ ខ្ញុំឃើញអក្សរ

បងនួន ខ្លីៗ។ ដូច្នេះ នាំឲ្យខ្ញុំសន្និដ្ឋានថាអត់ពី សុន សេន ទៅ ជាពិសេសក្រោយថ្ងៃ២៥ តុលា ១៩៧៧ សូមទោស! ២៥ វិច្ឆិកា ១៩៧៧ បងនួន មិនបាច់សុំយោបល់ ប៉ុល ពត ទេ។ គាត់ចាប់ខ្លួនគាត់អីខ្លួនគាត់ក្នុងឋានៈជាអ្នកមានអំណាចសម្រេច។ ដូច្នេះ ខ្ញុំសូមសន្និដ្ឋានប៉ុណ្ណេះ។ នេះជាការសន្និដ្ឋានរបស់ខ្ញុំ ដោយឈរលើឯកសារប៉ុន្មានដែលខ្ញុំបានឃើញនេះ ហើយនិងខ្ញុំដឹងព្រឹត្តិការណ៍យ៉ាងនេះ។ នេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំទេ។ សូមគោរពជូនតុលាការពិចារណា។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតពិនិត្យមើលឯកសារមួយទៀតបាទ D108/50/1.5 បកប្រែទៅជាភាសាអង់គ្លេស ERN 548892 មិនមានជាបកប្រែជាភាសាបារាំងទេ លោកចៅក្រម។ ដូច្នេះសំណើរបស់ខ្ញុំៗសូមឲ្យ សូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ ហើយនិងសូមឲ្យសាក្សីផ្តល់ការសង្កេតបាទ ពិនិត្យមើលឯកសារនេះផងដែរ។

[១៥:២១:៤០]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលជំនួយការបញ្ជាក់បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ ហើយនិងទទួលយកឯកសារពីមេធាវីជូនសាក្សីពិនិត្យ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ចំពោះលោក ឌុច គឺថាតើលោកស្គាល់ឯកសារនេះដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្គាល់ឯកសារនេះ។

**ស៖** ជាបឋមសូមលោកពន្យល់ថាតើអត្ថបទនៅខាងឆ្វេងដែលសរសេរដៃ និងនៅខាងស្តាំហ្នឹងសរសេរមានខ្លឹមសារដូចនឹងអត្ថបទវាយអង្គុលីលេខដែរឬទេ? ខ្លឹមសារ ខ្ញុំចង់និយាយអីខ្លឹមសារ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដូចគ្នាសុទ្ធសាធ។

**ស៖** សូមលោកអានឯកសារមួយនេះបាទ។

[១៥:២៣:២៣]

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអានដូចតទៅ៖ “ជម្រាបសមមិត្ត ឌុច ជាទីស្នេហា! ១) អំពីក្រដាសត្រូវសំចៃ តែសំខាន់គឺត្រូវយកចិត្តទុកដាក់អំពីខ្លឹមសារ។ ចម្លើយត្រូវឲ្យម៉ត់ចត់

និងទទួលខុសត្រូវ គ្រវីសគ្រវាសប្រថុយប្រថានមិនបានទេ។ ២) ឯវិធីធ្វើចំពោះពួកអាសំខាន់ ឯវិធីគឺចំពោះពួកអាសំខាន់ៗ អាសំខាន់ត្រូវ ១-ឲ្យវាសរសេរ ឬថតខ្សែអាត់ ហើយចម្លង។ តាមពិសោធ បើវានិយាយដាក់ខ្សែអាត់ខ្លីជាងវាសរសេរ។ អាល្មមៗអាចជាកំណត់ហេតុបាន។ អាល្មមៗខ្លះវាឆ្លើយដាក់តែពាសវាលដែរ ត្រូវប្រយ័ត្ន។ ៣) ទោះយ៉ាងណាចម្លើយនីមួយៗត្រូវពិនិត្យឲ្យម៉ត់ចត់ ព្រោះអាខ្លះវាឆ្លើយវាយយើងដែរ។ អាខ្លះដោយចេតនា អាខ្លះទៀតវាខ្លាចចេះតែនិយាយ។ ដូច្នេះត្រូវម៉ត់ចត់ ថ្លឹងថ្លែងមែនទែន។ ភាតរភាព-- ភាតរៈបដិវត្តន៍កក់ក្តៅបំផុត ខៀវ ថ្ងៃ៥ ខែតុលា ១៩៧៧"។

[១៥:២៥:២២]

**ស៖** ចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកក៏បានបញ្ជាក់ពីលិខិតដែលលោកទទួលពី សុន សេន។ នៅក្នុងឯកសារ D86/11 ERN ជាភាសាអង់គ្លេស 00159558 ខ្មែរ ERN 00158841 បារាំង ERN 00158849។ ខ្ញុំសូមដកស្រង់ខ្លឹមសារខ្លីៗនៅក្នុងកថាខណ្ឌមួយចំនួន។ នៅពេលដែលលោកនិយាយអំពីសំបុត្រដែលលោកបានទទួលពី សុន សេន។ ខ្ញុំសូមដកស្រង់៖ "នៅចុងឆ្នាំ១៩៧៧ ខ្ញុំបានសរសេរនៅ សុន សេន ហើយសុំឲ្យគាត់ជួយ។ ចម្លើយសារភាពដែលឆ្លើយដាក់មនុស្សមួយចំនួនច្រើននោះ។ គាត់ឆ្លើយមកខ្ញុំថា អ្នកសួរចម្លើយត្រូវតែប្រុងប្រយ័ត្នមិនត្រូវទទួលយកការសារភាពដែលឆ្លើយដាក់មនុស្សច្រើនពេកទេ។ ហើយខ្ញុំក៏បានឲ្យគេវាយអង្គុលីលេខ ហើយបានចែកទៅឲ្យអ្នកសួរចម្លើយទាំងអស់នោះ"។ សំណួររបស់ខ្ញុំទៅលោកនោះ គឺតើនេះជាលិខិតដែលលោកសំដៅនៅពេលនោះឬ? ដែលលោកឲ្យគេវាយអង្គុលីលេខ ហើយចែកទៅអ្នកសួរចម្លើយរបស់លោកនោះបាទ។

[១៥:២៧:១៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នេះជាលិខិតដែលខ្ញុំតែងទន្ទឹងមើលផ្លូវ ហើយខ្ញុំនិយាយនៅក្នុងកំណត់ហេតុសួរចម្លើយហ្នឹងមែន។

**ស៖** ហេតុអ្វីបានជាជូនផ្ញើសំបុត្រទៅលោក សុន សេន នៅចុងឆ្នាំ១៩៧៧នោះ។ នៅពេលដែលលោកបញ្ជាក់ពីមុនថា ពេលនោះលោកមិនត្រូវរាយការណ៍ទៅឲ្យ សុន សេន ទៀតទេ គឺរាយការណ៍ទៅលោក នួន ជា សូមលោកពន្យល់មើលបាទ?

[១៥:២៨:១០]

**ឆ៖** អរគុណ។ ជម្រាបប្រសាន៍លោកប្រធាន។ សំបុត្រដែលខ្ញុំសរសេរទៅបង សុន សេន គឺនៅពេលដែលគាត់គ្រប់គ្រងនៅឡើយ មិនទាន់ផ្លាស់ទៅនៅអ្នកលឿងទេ។ យូរណាស់ ទើបខ្ញុំឃើញ

សំបុត្រឆ្លើយតប។

**ស៖** ដូច្នេះ នៅពេលដែលលោកនិយាយថា នៅចុងឆ្នាំ១៩៧៧នោះ លោកនិយាយថាមុនថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៧៧ តើត្រូវទេ?

**ឆ៖** អរគុណ។ ត្រឹមត្រូវហើយ។

**ស៖** ហើយនៅសំបុត្រនោះ គឺសរសេរមកលោកដែល សុន សេន សរសេរគឺថ្ងៃទី៥ តុលា ឆ្នាំ១៩៧៧។ សូមលោកពន្យល់ហេតុអ្វីបានជាសរសេរសំបុត្រនេះមកលោក ហេតុអ្វីក៏មិន នួន ជា?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមមិនឆ្លើយទេ ពីព្រោះកាលណា យើងឆ្លើយ ខ្ញុំចូលសន្និដ្ឋានទៀតហើយ។ ប៉ុន្តែបើលោកមេធាវីឲ្យខ្ញុំឆ្លើយ ខ្ញុំគ្រាន់តែបញ្ជាក់ថា សន្និដ្ឋាន។

[១៥:២៩:៥៦]

**ប្រធានអង្គជំនុំ៖**

សាក្សីត្រូវតែឆ្លើយតបទៅនឹងសំណួរ។ តាមបទពិសោធន៍ តាមកត់សម្គាល់ ឬក៏តាមការចងចាំរបស់លោក។

[១៥:៣០:០៦]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំគិតថា ឯកសារនេះ ខ្ញុំជូនទៅបងខៀវ-- សុន សេន នៅពេលដែលគាត់នៅធ្វើជាមេផ្ទាល់របស់ខ្ញុំ។ ហើយពេលនុ៎ងបន្ទាប់ប្រញាប់រៀប គាត់អញ្ជើញចេញទៅអ្នកលឿង ប្រហែលជាសំបុត្រហ្នឹងដោយទៅនឹងគាត់រហូត។ ដល់ពេលមួយនោះ គាត់រើទៅឃើញទើបគាត់សរសេរមកខ្ញុំវិញ នៅពេលដែលគាត់មកអញ្ជើញមកធ្វើការនៅភ្នំពេញ។ នេះខ្ញុំយល់តែប៉ុណ្ណឹង បានជាវាមិនទាក់ទងដល់បងនួន សរសេរមកខ្ញុំ។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ខ្ញុំសូមអរគុណ។ សូមអនុញ្ញាតចូលទៅដល់ចម្លើយសារភាពមួយផ្សេងទៀត ដែលឯកសារនោះ លេខ*អានណិច* D43/IV ឧបសម្ព័ន្ធ៩៦។ ERN 00175121 បារាំង ERN 00244529។ អង់គ្លេស ERN 00224132។

[១៥:៣១:៥០]

ឌុច តើលោកស្គាល់សំណេរនេះដែរឬទេ? ចំណារនេះដែរឬទេ? តើលោកចង់បានឯកសារនេះ

ជាក្រដាសដែរឬទេ? ប្រសិនបើមានឯកសារក្រដាស ប្រហែលជាលោកអាចងាយមើលជាង។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីដាក់ជូនសាក្សីពិនិត្យ!

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមអានចំណារដែលនៅក្នុងប្រអប់៖ “ជូនអង្គការពីរច្បាប់ហើយ មិនទាន់អាន, ២/៨/៧៧, +សង្ខេបជូនអង្គការមួយច្បាប់ ១៤/១០/៧៧”។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** តើលោកចាំអក្សរនេះដែរឬទេ?

**ឆ៖** តាមខ្ញុំចំណាំ ខ្ញុំជឿថាអក្សរចំណារនេះ គឺជាអក្សរ បងនួន។

[១៥:៣៤:៥៤]

**ស៖** លោកចៅក្រម ខ្ញុំសូមដកស្រង់ឯកសារ D238 ដែលជាកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះផ្តល់ជូនចៅក្រមស៊ើបអង្កេត ERN ជាភាសាអង់គ្លេសគឺ 00403888 ខ្មែរគឺERN 00403877 បារាំងគឺ00403898។ ខ្ញុំសូមដកស្រង់សម្តីក្នុងនោះឆ្លើយដោយជនត្រូវចោទ នៅត្រង់ទំព័រ 00175121 “ខ្ញុំសរសេរ “ស” នៅក្នុងរង្វង់បួនជ្រុង” ដែលយើងឃើញហើយនៅក្នុងចំណុចកណ្តាលមានរង្វង់មូលជុំវិញ។ ឌុច គាត់បានឆ្លើយថា “ខ្ញុំសរសេរអក្សរ “ស” នៅក្នុងកូឡោនបួនជ្រុង ដែលមានន័យថាសម្ងាត់ ហើយក្រៅពីនោះ ចំណារគឺ សុន សេន សរសេរទាំងអស់”។ “ជូនអង្គការពីរច្បាប់ មិនទាន់អាន ពីរ ខែសីហា ៧៧ សង្ខេបជូនអង្គការមួយច្បាប់ ថ្ងៃ១៤ ខែ១០ ៧៧ អានសង្ខេប”។

តើលោកអាចពន្យល់ជូនយើងខ្ញុំនិងអង្គជំនុំជម្រះបានដែរឬទេ? ហេតុអ្វីបានជាលោកផ្តល់ចម្លើយនៅមុខចៅក្រមស៊ើបអង្កេត លោកបានលើកឡើងថា ចំណារអក្សរនេះជារបស់ សុន សេន។ ក៏ប៉ុន្តែនៅថ្ងៃនេះលោកបែរជានិយាយថា ជាអក្សររបស់ នួន ជា ទៅវិញ?

[១៥:៣៧:០០]

**ឆ៖** អរគុណ។ ចម្លើយដែលខ្ញុំឆ្លើយនៅសហាចៅក្រមស៊ើបអង្កេត ខ្ញុំយល់ស្របតាមការអានអម្បាញ់មិញ។ ហើយលើកមុននេះខ្ញុំក៏នៅបានបញ្ជាក់ថា ខ្ញុំពីលើមុន ខ្ញុំសន្និដ្ឋានថា ឯកសារនេះ ចំណារនេះជាចំណាររបស់ បងនួន ពីព្រោះអាខាងក្នុងវាសង្កត់ខ្ញុំអង្គាល់នុ៎ង។ ចំណារខាងក្នុងនេះៗ វាមានន័យសង្ខេប។ ដូច្នេះ យើងមើលទៅយើងឃើញហើយអក្សរនេះ។ ដូច្នេះ ខ្ញុំមានហេតុផលជម្រាបតែប៉ុននុ៎ង

ការសន្និដ្ឋានរបស់ខ្ញុំពីលើកវាមិនច្បាស់អ៊ីចឹង វាច្រឡំអ៊ីចឹងមែន។ ឥឡូវនេះ ខ្ញុំងាកមកសន្និដ្ឋានអ៊ីចេះ យ៉ាងម៉េចយ៉ាងម៉ា អាហ្នឹងខ្ញុំគោរពជូនអង្គជំនុំជម្រះវិភាគនិងសម្រេច។

[១៥:៣៨:៣៣]

**ស៖** ឌុច តើលោកនៅពេលនេះ កំពុងតែសន្និដ្ឋានទៅលើអក្សរនេះហើយ ឬក៏យ៉ាងម៉េច? ឬក៏លោកកំពុងតែទាយអក្សរនេះហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** មែន អរគុណ។ មែន នៅសហចៅក្រមស៊ើបអង្កេត ក៏ខ្ញុំសន្និដ្ឋាន នៅទីនេះក៏ខ្ញុំសាកល្បងសន្និដ្ឋានដោយឃើញទម្រង់ប្លែក។ អ៊ីចឹងហើយបានជាចុងបញ្ចប់ ខ្ញុំថារឿងពិតយ៉ាងម៉េច គោរពជូនអង្គជំនុំជម្រះលោកពិចារណានិងវិភាគចុះ។

**ស៖** សូមអរគុណ។ មន្ត្រីរដ្ឋបាលបានផ្តល់ជូននូវឯកសារពីរច្បាប់ខុសគ្នា។ លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារមួយទៀត គឺឯកសារលេខ-- ចម្លើយសារភាពដូចគ្នា ក៏ប៉ុន្តែនៅទំព័រផ្សេង ឧបសម្ព័ន្ធតែមួយ លេខERN ខ្មែរ គឺ 00175172។ ការបកប្រែឯកសារនេះមានលេខ ERN ដូចគ្នា ដូចដែលខ្ញុំបានផ្តល់ខាងដើម។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តទៅទៀតលោកប្រធាន។

ឌុច តើលោកចំណាំឯកសារនេះដែរឬទេ? ស្គាល់ឯកសារនេះដែរទេ? ហើយលោកយល់ស្របថាវាចម្លើយសារភាពដូចគ្នាដែរឬទេ?

[១៥:៤០:៤៤]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះ លេខ១៧២នេះ ខ្ញុំចំណាំឯកសារ១២១ ក៏ខ្ញុំចំណាំ អា១២១ វាជាក្របពីខាងក្រៅ អាខាងក្នុងវាចាប់ផ្តើមពី១៧២ ទៅ។ ខ្ញុំស្គាល់ឯកសារនេះ។

**ស៖** ដើម្បីជាកំណត់ប្រតិចារឹកតើនរណា-- តើចម្លើយសារភាពជារបស់អ្នកណាដែរ?

**ឆ៖** អរគុណ។ ចម្លើយសារភាពនេះ ខ្ញុំសូមអាន៖ “អត្ថបទចម្លងចេញពីខ្សែអាត់ តាមចម្លើយពេជ-- ពេជ ផន ហៅ ម៉ៃ ផូ ប្រធានគមនាគមន៍ចម្ការកៅស៊ូ ២០៣។ ចម្លើយបឋមក្នុងខ្សែអាត់”។

**ស៖** សូមអរគុណ។ តើលោកអាចអានអក្សរដែលនៅក្នុងកូឡោន ពណ៌ក្រហមដែរឬទេ? គឺនៅខាងលើនៃឯកសារនេះ?

[១៥:៤២:៣៥]

**ឆ៖** អរគុណ។ កូឡោនតូចសរសេរថា “សម្ងាត់ណាស់”។ ក្នុងប្រអប់ធំ ពីខាងក្រោមនោះ

ជាប់នោះ "១) សូមជូនបងឯកសារសង្ខេបរបស់អា ម៉ៃ ផូ។ បងប្អូនសង្ខេបល្អិត ល្មមយល់សាច់រឿងរួម តែត្រូវអានឯកសារល្អិតទៀត។ ខ្ញុំកំពុងអាន។ សូមជូនបង"។

**ស៖** សូមអរគុណ។

*(គ្មានការបកប្រែ)*

[១៥:៤៣:២៧]

**ផ៖** "សូមៗជូនបងក្រោយ។ ២) វាឆ្លើយសង្កត់លើសមមិត្ត ភួង តាំងពីដើមដល់ចប់--"

**ស៖** ខ្ញុំសូមអភ័យទោស ដែលខ្ញុំកាត់សម្ដីលោកៗមិនចាំបាច់អានទាំងអស់នោះទេ ក៏ប៉ុន្តែនៅពេលនេះខ្ញុំសូមឱ្យលោកអានប្រអប់កូឡោនខាងក្រោមដែលមានឈ្មោះ និង-- ដែលមានហត្ថលេខា និងកាលបរិច្ឆេទ?

**ផ៖** អរគុណ។ នៅក្នុងប្រអប់ខាងក្រោមបំផុត តូច សរសេរថា "១៤ តុលា ១៩៧៧"។

**ស៖** ខ្ញុំសន្មតថា កាលបរិច្ឆេទនៅក្នុងកូឡោននេះ គឺដូចទៅនឹងកាលបរិច្ឆេទនៅក្នុងចំណារដែលលោកបានលើកឡើងអម្បាញ់មិញនៅក្នុងឯកសារមុន ថាជាចំណាររបស់ នួន ជា នោះ ថ្ងៃខែហ្នឹងគឺដូចគ្នាទេ ទាំងពីរហ្នឹង មែនដែរឬទេ? ឯកសារទាំងពីរអម្បាញ់មិញ គឺមានចុះកាលបរិច្ឆេទដូចគ្នា គឺ "១៤ តុលា ៧៧" តើលោកឯកភាពដូច្នេះដែរឬទេ?

**ផ៖** អរគុណ។ ខ្ញុំឯកភាព។

[១៥:៤៥:០២]

**ស៖** តើនរណាគេជាអ្នកសរសេរចំណារនេះ ចំណារដែលវែងនេះ?

**ផ៖** អរគុណ។ ចំណារដែលវែងនេះមានប្លូកថាខណ្ឌ ជារបស់ សុន សេន។

**ស៖** ដូច្នេះលោកប្រាកដហើយថាចំណារនេះជារបស់ សុន សេន?

**ផ៖** អរគុណ។ ខ្ញុំស្គាល់អក្សរ សុន សេន បានច្រើនជាងអក្សរ បងនួន។ ដូច្នេះ ខ្ញុំឃើញលទ្ធភាពជាអក្សរ សុន សេន ច្រើនជាងលទ្ធភាពជាអក្សរ បងនួន។

**ស៖** សូមអរគុណ។ ល្អត្រង់ចំណុចនេះ។ ថាតើកថាខណ្ឌទីមួយ ចំណុចដែលលោកទើបតែបានអានកូឡោនភ្ជាប់ពីលើមកទីពីរនោះ តើគាត់សរសេរជូនទៅនរណាដែរ?

**ផ៖** អរគុណ។ តាមការសង្កេតរបស់ខ្ញុំ ដោយឃើញឯកសារច្រើនហើយ ដែលបានបង ខៀវ សរសេរ តែកាលណាជូនបង ដាច់ប៊ិតមួយម៉ាត់អ៊ីចឹងគឺសំដៅ ប៉ុល ពត។ បើគាត់សរសេរទៅ នួន ជា

ជូន បងនួន ឬគោរពជូន បងនួន។ នេះការសង្កេតរបស់ខ្ញុំ។

[១៥:៤៧:១៦]

**ស៖** សូមអរគុណ។

ខ្ញុំមានឯកសារចំនួនពីរទៀតដែលត្រូវដេញដោល គឺខ្ញុំសូមចូលឯកសារមួយទៀត គឺឯកសារនេះគឺជាចម្លើយសារភាព ឯកសារមានលេខ D43/IV ឧបសម្ព័ន្ធ៦៣។ ERN ជា 00174502 បកប្រែជាភាសាអង់គ្លេសមានលេខ ERN 00224130 បកប្រែជាភាសាបារាំងមានលេខERN 00269783។

**ប្រធានអង្គជំនុំ៖**

មានរៀបចំឯកសារជាក្រដាសសម្រាប់សាក្សីពិនិត្យទេ? មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីដើម្បីដាក់ជូនទៅសាក្សីពិនិត្យ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើលោកស្គាល់ឯកសារនេះដែរឬទេ?

[១៥:៤៩:២១]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំស្គាល់ឯកសារនេះ។

**ស៖** តើលោកអាចអានចំណារក្រហមនៅខាងក្រោមនេះដែរឬទេ? សូមអញ្ជើញអាន!

**ឆ៖** អរគុណ។ លោកប្រធានជាទីគោរព ខ្ញុំសូមអានដូចតទៅ៖ “បងជាទីគោរព! ឯកសារនេះមានប្លែកខ្លះ ត្រង់ខ្សែវានៅក្រុងកំពង់ធំចាស់ ពួកនេះយើងរកមិនឃើញភ្លាមទេ តែបងប្អូនវា ដែលជាប់ខ្សែនឹងវាតាំងពី៥៥-- ៦៥-៦៦ តាំងពីវានៅកំពង់ធំរហូត ១៧ មេសា ១៩៧៥ វានៅតំបន់៥។ អ៎ៗ សូមទោស តាំងពីវានៅកំពង់ធំរហូត។ ក្រោយ ១៧ មេសា ១៩៧៥ វានៅតំបន់៥។ ពួកនេះទៅពីកប់រស់ស្រុកស្ទោង កំពង់ធំ។ វាទៅទាក់ទងពួកនេះ យើងស្រួលរក ហើយនៅមូលគ្រួសារនោះ។ល។ មូលគ្រួសារនេះ។ ពួកនេះធ្លាប់ស្គាល់អាហ៊ីង ពួកនេះតាម--” សូមទោស ខ្ញុំអានបន្តទៅទៀតតតិបតុបណាស់ ខ្ញុំសូមអានសាថ្មី។

[១៥:៥១:១៣]

“...តាមធ្លាប់ស្គាល់ ពួកនេះ ដែលអាហ៊ីង ឆ្លើយប្រហែលពិត ម៉្យាងបងប្អូនវា ម៉្យាងវណ្ណៈភាពដើមជាម្ចាស់ដីគឺ គ្រួសារព្រុំពូ ដោយគោរព! ឌុច ៦/១១/១៩៧៧”។

**ស៖** សូមអរគុណ។ តើនរណាគេជាអ្នកសរសេរចំណារនេះ?

**ឆ៖** ខ្ញុំ។

**ស៖** តើ "បង" នេះ សរសេរទៅ "បង" ណាដែរ?

**ឆ៖** អរគុណ។ ក្នុងឯកសារនេះ គឺឯកសារថ្ងៃ៦ ខែ១១ ៧៧ គឺសរសេរទៅ បងនួន។

**ស៖** នៅពេលនេះ សូមលោកអានចំណារជាអក្សរខ្មៅ។

**ឆ៖** អរគុណ។ អក្សរខ្មៅនៅខាងលើខាងឆ្វេង សរសេរថា "មានបញ្ហាថ្មី" នៅខាងស្ដាំ ហើយច្រើនសរសេរថា "១-ជូនបងមួយច្បាប់ មានថ្មីត្រង់ខ្សែវាខាង១។ ៣- ស្នើបងពិនិត្យសិន។ ជូនក៏បានព្រោះមិនមានអីខាងពាយ័ព្យថែម។ សំខាន់ តាំងពីនៅភ្នំពេញ។ ៩/១១/៧៧"។

**ស៖** តើពាក្យថា "បង" នោះគឺជានរណាដែរ? បាទ ខ្ញុំសួរជាបឋមសិន។ តើនរណាគេជាអ្នកសរសេរចំណារ?

**ឆ៖** អរគុណ។ ចំណារនេះ ចំណារបន្ថែមជាខ្មៅនេះ ជាចំណាររបស់ សុន សេន។

**ស៖** សូមអរគុណ។ តើពាក្យថា "បង" នេះ ជានរណាដែរ បញ្ជូនទៅ "បង" ណាដែរ?

**ឆ៖** អរគុណ។ បងនេះគឺ សុន សេន សរសេរទៅ ប៉ុល ពត។ បងនេះ គឺ ប៉ុល ពត។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:៥៥:០២]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ចំណុចមួយ សាក្សីអានចំណារខាងឆ្វេងមួយ និងខាងស្ដាប់មួយ ហើយយើងខ្ញុំមិនច្បាស់នៅពេលដែលសាក្សីនិយាយថា តើចំណារទាំងពីរនេះសំដៅទៅលើបុគ្គលតែមួយ ឬក៏ចំណារខាងឆ្វេងជាចំណាររបស់អ្នកផ្សេង ពីចំណារដែលសរសេរខាងស្ដាំ។ ដូច្នេះ យើងខ្ញុំសូមឱ្យមេធាវីការពារក្ដីសួរបញ្ជាក់ទៅលើចំណុចនៃចំណារពីរផ្សេងគ្នានេះ តើជាមនុស្ស-- របស់មនុស្សតែមួយ ឬផ្សេងគ្នា?

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ លោកមេធាវីអាចយល់បានពីបំណងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយគឺ គាត់ចង់ឱ្យបញ្ជាក់ពីព្រោះបញ្ហាចំណារនេះ គឺពិតមែនតែមានពណ៌ខុសគ្នា ប៉ុន្តែ ឌុច បាន

និយាយហើយថា ចំណារពណ៌ខ្មៅហ្នឹងមានពីរ។ គាត់អានទាំងពីរ។ អ៊ីចឹង ក្នុងការសួរហ្នឹងបញ្ជាក់ឲ្យបានច្បាស់លាស់ ញែកឲ្យច្បាស់រវាងចំណារទាំងពីរ។ រវាងចំណាខាងឆ្វេង ហើយនិងចំណារខាងស្តាំ ដើម្បីសួរដេញដោលទៅឲ្យវាច្បាស់ទាំងអស់គ្នា។

[១៥:៥៦:១៨]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ចំណារខ្លីនៅខាងឆ្វេង តើនរណាគេជាអ្នកសរសេរចំណារខ្លីខាងឆ្វេងនេះ? ហើយតើលោកអាចនិយាយយ៉ាងម៉េចដែរទៅលើចំណារថ្មី-- ខ្លីនេះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចំណារខ្លីនេះ យើងមើលពីទំហំដិតរបស់ប៊ិកតូចជាងចំណារខាងស្តាំ។ ចំណារខាងស្តាំ គាត់ចារហើយ គាត់គូសខាងក្រោមអត្ថបទរបស់ខ្ញុំ។ សេចក្តីរាយការណ៍របស់ខ្ញុំទៅទៀត។ ដូច្នេះ ចំណារថ្មីនេះ អ៎! ចំណារ នែ៎! ខាងឆ្វេងនេះ ខ្ញុំមិនទាន់ប៉ានថាអ្នកណាជាអ្នកចារទេ។ ព្រោះអក្សរនេះមិនមែនជាអក្សរ បងប៉ុល ហើយក៏មិនមែនជាអក្សរ បងខៀវ។ ទេ មិនមែនទេ! មានសង្កេតមើលអក្សរ មាន! ប្រហែលគ្នាទេ។ ដូច្នេះប្រហែលជាអាចគ្រាន់តែដូរប៊ិកទេ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា បើតាមវិភាគដំបូងក្នុងពេលនេះ ចំណារនេះតែមួយទេ។ គ្មានបញ្ហាថ្មីទេ គ្រាន់តែដូរប៊ិកប៉ុននុ៎ង។

[១៥:៥៨:០០]

**ស៖** សូមអរគុណ។ ឌុច ឯកសារទំនងជាដូចទៅនឹងឯកសារមួយទៀតដែលខ្ញុំបានបង្ហាញលោក។ ចម្លើយសារភាពនេះ គឺបានបញ្ជូនពីលោកទៅ សុន សេន ហើយបន្ទាប់មក សុន សេន បញ្ជូនទៅ ប៉ុល ពត។ តើលោកឯកភាពត្រង់ចំណុចនេះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនប៉ានឯកភាព តែក៏មិនប៉ានបដិសេធសេចក្តីសន្និដ្ឋានរបស់លោកមេធាវីដែរ ព្រោះខ្ញុំមិនងាយដែលនឹងឃើញមេខ្ញុំគាត់សរសេរពាក្យ "ហើយ" នៅខាងចុងសោះ។ នេះជាការសង្កេតរបស់ខ្ញុំ ដែលនាំឲ្យខ្ញុំទាក់ទើរ។ ហើយបើ បងនួន ហើយៗជាហូរហែ។

[១៥:៥៩:៤៩]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមើលឃើញម៉ោងបួនហើយ ហើយខ្ញុំនៅសល់ឯកសារមួយទៀតដែលខ្ញុំត្រូវបង្ហាញ ក៏ប៉ុន្តែខ្ញុំសូមបង្ហាញនៅព្រឹកស្អែកវិញ ដោយសារតែពេលបង្ហាញអាចចំណាយពេលយូរ។ ដូច្នេះហើយគឺ ខ្ញុំអាចសូមបន្ថែមដប់ប្រាំនាទីបានដែរឬទេ? បើមិនអ៊ីចឹងទេ ខ្ញុំអាចសុំបន្តទៅថ្ងៃស្អែកតែម្តងទៅ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ពេលវេលាសមល្មមនឹងសម្រាកហើយ ហើយដោយសារយើងធ្វើជារៀងរាល់ថ្ងៃ។ ដូច្នេះ គឺការដែលពន្យារពេលច្រើនលើកច្រើនសា ក៏ជាការប្រឈមមួយដែលលើបញ្ហាកម្លាំងទាំងអស់គ្នា។ ដូច្នេះ អង្គជំនុំជម្រះយល់ថាពេលវេលាដំណើការសវនាការនៅថ្ងៃនេះ សមល្មមនឹងសម្រាកហើយ។ អង្គនុំជម្រះផ្អាកកិច្ចដំណើរការសវនាការនេះ សម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការនឹងលើកបន្តទៅធ្វើនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ហើយៗអនុរក្សមន្ទីរឃុំឃាំង-- អ៎ៗ *សូរី*!

សូមអញ្ជើញលោកមេធាវី!

[១៦:០១:១៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំសូមលើកឡើងថា នៅព្រឹកស្អែក នៅថ្ងៃស្អែកយើងសូមពេលវេលាបន្ថែមច្រើនជាងអ្វីដែលយើងខ្ញុំបានស្នើសូមមុន។ ដោយសារតែនៅថ្ងៃនេះ យើងមានការរអាក់រអួលច្រើន ដូច្នេះហើយខ្ញុំសូមពេញមួយថ្ងៃស្អែកតែម្តង។ ដោយសារតែយើងខ្ញុំអាចបញ្ចប់ត្រឹមល្ងាចថ្ងៃស្អែក។ ដូច្នេះយើងខ្ញុំដាក់សំណើតែម្តង សូមបន្ថែមមួយម៉ោងទៀត សម្រាប់ពេលវេលារបស់ខ្ញុំដេញដោលសម្រាប់ថ្ងៃស្អែក។ ក៏ប៉ុន្តែទោះបីខ្ញុំត្រូវធ្វើសំណើនេះក៏ដោយ យើងខ្ញុំទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេច។

[១៦:០២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់លោកមេធាវីក្នុងការបន្ថែមម៉ោង គឺពេញមួយថ្ងៃស្អែក។ ដោយមានហេតុផលរអាក់រអួលខ្លះ នៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោលកន្លងមក ជាការ

លើកមូលហេតុហ្នឹងសមស្របហើយ។ ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកដល់មេធាវីផងដែរ ថាមិនមែនតែមេធាវីក្រុមមេធាវីការពារក្តី នួន ជា ទេ គឺក្រុមមេធាវីការពារក្តីផ្សេងទៀត សុំថាប្រសិនបើមានបំណងក្នុងការដាក់ឯកសារដើម្បីដេញដោល ចំពោះសាក្សី គឺសូមរៀបចំនូវឯកសារ ទាំងឯកសារក្រដាស ទាំងការរៀបចំការបញ្ចាំងនៅលើអេក្រង់ទូរទស្សន៍ ហើយនិងធ្វើសំណើសុំឲ្យបានច្បាស់លាស់ ដើម្បីអង្គជំនុំជម្រះហ្នឹងសម្រេចឲ្យបានជាក់ច្បាស់។ វាចៀសវាងការសម្រេចទៅ លើសនឹងសំណើសុំរបស់ភាគី។ ហើយអ៊ីចឹង គឺថាបើសិនជាយើងធ្វើឲ្យជាក់ច្បាស់ ហើយត្រឹមត្រូវទាំងអស់គ្នាហ្នឹង គឺរួមចំណែកក្នុងការបង្កើនល្បឿន នៅក្នុងកិច្ចពិភាក្សារបស់យើងដែរ។ ហើយពេលវេលាហ្នឹងមានប្រយោជន៍សម្រាប់ដល់ក្រុមមេធាវីការពារក្តីដែលនឹងមានឱកាសច្រើនក្នុងការដេញដោលចំពោះសាក្សី។ ដោយសាររឿងក្តីគឺយើងនៅមាននៅព្រំដែន មានពេលវេលាកំណត់។ អង្គជំនុំជម្រះសង្ឃឹមថា ក្រុមមេធាវីនឹងរៀបចំក្នុងការដាក់ឯកសារដើម្បីដេញដោលហ្នឹង គឺរៀបចំឲ្យល្អ។

[១៦:០៣:៣៩]

សូមអញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតែ--របស់លោកប្រធានតែប៉ុណ្ណោះ។ ប្រសិនបើមេធាវីប្រើប្រាស់ឯកសារណាមួយនោះ គឺមេធាវីគួរតែជូនដំណឹងដល់ភាគី និងអង្គជំនុំជម្រះឲ្យបានមុនថ្ងៃដែលខ្លួនធ្វើការដេញដោលបង្ហាញឯកសារទាំងអស់នោះ។ ការធ្វើដូច្នេះ នឹងជាការសន្សំពេលវេលារបស់យើង ហើយឲ្យភាគីទាំងឡាយបានពិនិត្យ និងឃើញឯកសារទាំងអស់នោះផង។ ជាពិសេស ក្នុងករណីដែលឯកសារទាំងអស់នោះ វាត្រូវការចាំបាច់ពិភាក្សាដេញដោល។

[១៦:០៤:២៩]

យើងខ្ញុំដឹងថា អង្គជំនុំជម្រះបានបង្កើតនៅក្នុងប្រព័ន្ធ ហ្សាយឡេប គឺ *អ៊ិនធីហ្វេស* នៃការជំនុំជម្រះ។ ដូច្នេះប្រព័ន្ធនេះអាចជូនដំណឹងទៅដល់មេធាវីការពារក្តី ភាគី និងមន្ត្រីផ្នែកច្បាប់ផងបង្ហាញនូវឯកសារលម្អិត។ ដូច្នេះយើងដឹងថា យើងទាំងអស់យល់ច្បាស់ហើយ ហើយយើងអាចមិនចាំបាច់លើកឡើងឯកសារនេះ ទៅលើផ្ទាល់មាត់ ដោយផ្ទាល់មាត់នៅក្នុងតុលាការនោះទេ គឺយើងអាចធ្វើតាមរយៈប្រព័ន្ធនេះជាលាយលក្ខណ៍អក្សរ។ ហើយយើងខ្ញុំបង្គាប់សូមឲ្យមេធាវី និងភាគីទាំងអស់ផ្តល់ការជូន

ដំណឹងទៅលើឯកសារទាំងអស់នេះ ឲ្យមុន។ សូមអរគុណ។

[១៦:០៥:១១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ផ្អាកសវនាការថ្ងៃនេះត្រឹមនេះ ហើយលើកទៅសវនាការបន្តធ្វើនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក។ អនុរក្សមន្ទីរឃុំឃាំងនាំសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយឲ្យនាំគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅព្រឹកស្អែកឲ្យត្រឹមម៉ោងប្រាំបួន។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនប្រាំបួនម៉ោង។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*